កម្មវិធីពន្លកចំណេះ៖
ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា

# សៀវភៅណែនាំស្ដីពីការស្រាវជ្រាវប្រកប ដោយគុណភាព





Australian Aid
PONLOK CHOMNES
The Asia Foundation

# តារាងមាតិកា


ពាក្យកាត់ *i*
អំពីកម្មវិធីពន្លកចំណេះទី២៖ ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា *ii*

០១

## អំពីសៀវភៅណែនាំនេះ ១

១.១ គោលបំណង ១
១.២ ដំណើរការរៀបចំ ១
១.៣ អ្នកអានគោលដៅ ១
១.៤ របៀបប្រើប្រាស់សៀវភៅណែនាំនេះ ៣
១.៥ សារសំខាន់នៃការស្រាវជ្រាវដ៏ហ្មត់ចត់ ប្រកបដោយក្រមសីលធម៌ និងបរិយាបន្ន ៥

០២

## ដំណើរការស្រាវជ្រាវ ៧

០៣

## ការរៀបចំគ្រោងការស្រាវជ្រាវ ១១

៣.១ កំណត់បញ្ហាចោទនៃការស្រាវជ្រាវ និងសំណួរស្រាវជ្រាវ ១១
៣.២ សំយោគបណ្ណាល័យសាស្ត្រ ឬការពិនិត្យលើឯកសារពាក់ព័ន្ធ ១៣
៣.៣ គ្រោងការស្រាវជ្រាវ ( Research Design ) ១៦
៣.៤ វិធីសាស្ត្រស្រាវជ្រាវ ២១
៣.៥ ការរៀបចំសំណាក ២៥

## ០៤

## ក្រមសីលធម៌សម្រាប់ការស្រាវជ្រាវ ២៧

៤.១ គោលការណ៍ណែនាំសម្រាប់ការស្រាវជ្រាវប្រកបដោយក្រមសីលធម៌ ២៧
៤.២ ការធ្វើការវាយតម្លៃហានិភ័យ ៣០
គន្លឹះសម្រាប់ការធ្វើការវាយតម្លៃហានិភ័យ ៣០
៤.៣ ការរៀបចំផែនការគ្រប់គ្រងទិន្នន័យ ៣០
គន្លឹះសម្រាប់ការរៀបចំផែនការគ្រប់គ្រងទិន្នន័យ (DMP) ៣១
៤.៤ ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ (IMFORMED CONSENT) ៣១
ដំណើរការនៃការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ ៣៣
អ្វីដែលត្រូវបញ្ចូលក្នុងពិធីសារស្តីពីការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ ៣៤
ការទទួលបានការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ពីកុមារ ៣៥
ការពិចារណាពិសេសសម្រាប់ការសុំការយល់ព្រម ៣៥
៤.៥ វិធីសាស្ត្រដែលផ្តោតជនរងគ្រោះជាចម្បង ៤០
គោលការណ៍នៃវិធីសាស្ត្រដែលផ្តោតជនរងគ្រោះជាចម្បង ៤១

## ០៥

## ការប្រមូលទិន្នន័យ ៤៣

៥.១ វិធីសាស្ត្រប្រមូលទិន្នន័យ ៤៣
៥.២ សម្ភាសន៍ ៤៥
៥.៣ ការពិភាក្សាក្រុមគោលដៅ ៤៧
៥.៤ ការស្ទង់មតិ ៤៩

០៦
## ការវាយតម្លៃគុណភាពទិន្នន័យ ៥១

៦.១ ធ្វើការវាយតម្លៃគុណភាពទិន្នន័យ (DQA) ៥១

០៧
## ការវិភាគទិន្នន័យ ៥៥

៧.១ ការវិភាគទិន្នន័យបរិមាណវិស័យ ៥៥
៧.២ ការវិភាគទិន្នន័យគុណវិស័យ ៥៧
ការបង្កើតក្របខ័ណ្ឌ សម្រាប់វិភាគទិន្នន័យគុណវិស័យ ៥៧
ជំហាន ដើម្បីធ្វើការវិភាគទិន្នន័យគុណវិស័យ ៥៩

០៨
## ការសរសេរបាយការណ៍ស្រាវជ្រាវ ៦១

៨.១ ធាតុសំខាន់នៃរបាយការណ៍ស្រាវជ្រាវ ៦១
ការត្រួតពិនិត្យដោយអ្នកជំនាញដូចគ្នា (peer review) និងមូលហេតុ ដែលការពិនិត្យបែបនេះមានសារសំខាន់ ៦៣
៨.២ ការផ្សព្វផ្សាយការរកឃើញនៃការស្រាវជ្រាវ ៦៥
ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយ ៦៥
ឧទាហរណ៍នៃការផ្សព្វផ្សាយការស្រាវជ្រាវ ៦៦
គន្លឹះនៃការសរសេរការផ្សព្វផ្សាយការស្រាវជ្រាវ ៦៦
គន្លឹះសម្រាប់ការរៀបចំការផ្សព្វផ្សាយការស្រាវជ្រាវ ៦៦

## ០៩
## ការតាមដាន និងវាយតម្លៃផលជះនៃការស្រាវជ្រាវ ៦៧

## ១០
## ឧបសម្ព័ន្ធ ៦៩

ឧបសម្ព័ន្ធ កៈ ស្តង់ដារគុណភាពនៃការស្រាវជ្រាវ ៦៩
ឧបសម្ព័ន្ធ ខៈ បញ្ជីត្រួតពិនិត្យការវាយតម្លៃគុណភាពស្រាវជ្រាវ ៧៣
ឧបសម្ព័ន្ធ គៈ បញ្ជីត្រួតពិនិត្យសម្រាប់ការពិភាក្សាក្រុមគោលដៅ ប្រកបដោយបរិយាបន្ន ៧៦
ឧបសម្ព័ន្ធ ឃៈ បញ្ជីត្រួតពិនិត្យសម្រាប់កិច្ចសម្ភាសន៍ ប្រកបដោយបរិយាបន្ន ៧៨
ឧបសម្ព័ន្ធ ងៈ បញ្ជីត្រួតពិនិត្យការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់របស់អង្គការមូលនិធិអាស៊ី (ភាសាខ្មែរ) ៨០
ឧបសម្ព័ន្ធចៈ គំរូការយល់ព្រមបន្តពីជ្រាបព័ត៌មានសព្វគ្រប់របស់អង្គការមូលនិធិអាស៊ី (ភាសាខ្មែរ) ៨២
ឧបសម្ព័ន្ធឆៈ បញ្ជីត្រួតពិនិត្យការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់របស់អង្គការមូលនិធិអាស៊ី(ភាសាអង់គ្លេស) ៨៥
ឧបសម្ព័ន្ធ ជៈ គំរូការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់របស់អង្គការមូលនិធិអាស៊ី(ភាសាអង់គ្លេស) ៨៧
ឧបសម្ព័ន្ធ ឈៈ ឯកសារយោង ៨៩

# ពាក្យកាត់

| | | |
|---|---|---|
| ADB | Asia Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CSO | Civil Society Organisations | អង្គការសង្គមស៊ីវិល |
| DQA | Data Quality Assessment | ការវាយតម្លៃគុណភាពទិន្នន័យ |
| DMP | Data Management Plan | ផែនការគ្រប់គ្រងទិន្នន័យ |
| FGDs | Focus group discussions | ការពិភាក្សាក្រុមគោលដៅ |
| GBV | Gender-Based Violence | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| GEDSI | Gender Equality, Disability, and Social Inclusion | សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម |
| IRB | Institutional Review Board | គណៈកម្មការត្រួតពិនិត្យរបស់ស្ថាប័ន |
| NECHR | National Ethics Committee for Health Research | គណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខភាព |
| PCII | Ponlok Chomnes II | កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| UN | United Nations | អង្គការសហប្រជាជាតិ |
| WHO | World Health Organization | អង្គការសុខភាពពិភពលោក |

# អំពីកម្មវិធីពន្លកចំណេះទី២៖ ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា

កម្មវិធីពន្លកចំណេះទី២ (PCII)៖ ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា គឺជាគម្រោងវិនិយោគរយៈពេលបួនឆ្នាំ (២០២៣-២០២៧) ដែលទទួលបានការគាំទ្រថវិកាពីប្រទេសអូស្ត្រាលី ក្នុងគោលបំណងបង្កើនគុណភាព និងភាពពាក់ព័ន្ធនៃការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាលើគោលនយោបាយសាធារណៈ ។ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី១ (២០១៩-២០២៣) ផ្តោតលើការពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវនៅកម្ពុជា ដើម្បីធានាគុណភាពនៃការស្រាវជ្រាវសម្រាប់ការវិភាគ និងការពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា។ ផ្អែកលើសមិទ្ធផលនៃកម្មវិធីពន្លកចំណេះដំណាក់កាលទី១ នៅក្នុងដំណាក់កាលទីពីរ (២០២៣-២០២៧) នេះ កម្មវិធីផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការជំរុញការប្រើប្រាស់ទិន្នន័យ និងការពិភាក្សាប្រកបដោយបរិយាបន្ន ក្នុងដំណើរការរៀបចំគោលនយោបាយនៅកម្ពុជា។ ជាចុងក្រោយ កម្មវិធីនេះសង្ឃឹមថានឹងអាចបង្កើនបរិមាណនៃការស្រាវជ្រាវដែលអាចទុកចិត្តបាន ទាន់ពេលវេលា និងអាចទទួលយកបានសម្រាប់អ្នកតាក់តែងគោលនយោបាយ ព្រមទាំងជំរុញឱ្យមានការទទួលស្គាល់កាន់តែទូលំទូលាយអំពីសារសំខាន់នៃការរៀបចំគោលនយោបាយផ្អែកលើទិន្នន័យនៅកម្ពុជា។

ការស្រាវជ្រាវដែលមានគុណភាពខ្ពស់ មានសារសំខាន់ខ្លាំងណាស់នៅក្នុងដំណើរការ និងការពិគ្រោះយោបល់អំពីគោលនយោបាយសាធារណៈ ដ្បិតការស្រាវជ្រាវបែបនេះផ្តល់នូវទិន្នន័យ និងការវិភាគដែលចាំបាច់សម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្ត។ ស្ថាប័នស្រាវជ្រាវក្នុងស្រុក និងអង្គការសង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះប្រព័ន្ធអេកូស៊ីស្ដឹម (ecosystem) នៃការរៀបចំគោលនយោបាយ ដែលផ្អែកលើទិន្នន័យជាក់លាក់។ ទំនាក់ទំនងដ៏ជិតស្និទ្ធរវាងអង្គការទាំងនេះជាមួយសហគមន៍ និងបណ្តាញនានា និងការយល់ពីអាទិភាពក្នុងមូលដ្ឋាន ធ្វើឱ្យអង្គការទាំងនេះក្លាយតួអង្គសំខាន់បំផុត ក្នុងការបង្កើតការស្រាវជ្រាវ។

កម្មវិធី PCII ប្តេជ្ញាចិត្តពង្រឹងសមត្ថភាពរបស់អង្គការស្ថាប័ននានានៅកម្ពុជា ក្នុងការបង្កើតការស្រាវជ្រាវប្រកបដោយគុណភាព។ នៅពេលដែលស្ថាប័នក្នុងស្រុកត្រូវបានបំពាក់បំប៉នដោយជំនាញធនធាន និងការគាំទ្រផ្នែកស្ថាប័ន ដើម្បីដឹកនាំការស្រាវជ្រាវដែលមានគុណភាពខ្ពស់ ស្ថាប័នទាំងនេះនឹងមានសមត្ថភាពកាន់តែរឹងមាំ ក្នុងការឆ្លើយតបទៅនឹងតម្រូវការគោលនយោបាយដែលលេចចេញថ្មីៗ និងរួមចំណែកធ្វើឱ្យប្រព័ន្ធអេកូស៊ីស្ដឹមនៃ វិស័យស្រាវជ្រាវនៅកម្ពុជា កាន់តែរឹងមាំ និងកាន់តែមានភាពធន់ជាងមុន។ ការស្រាវជ្រាវដែលមានគុណភាពខ្ពស់ និងប្រកបដោយក្រមសីលធម៌ អាចបង្កើនតម្លាភាព គណនេយ្យភាព និងទំនុកចិត្តពីសាធារណជន។ ចាំបាច់ត្រូវមានការស្រាវជ្រាវប្រកបដោយបរិយាបន្នបន្ថែមទៀត ដើម្បីបង្កើតទិន្នន័យរឹងមាំ និងធានាថាកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍នានាធ្វើឡើងផ្អែកលើបទពិសោធក្នុងជីវិតជាក់ស្តែងរបស់ប្រជាជនកម្ពុជាគ្រប់រូប។



# ១. អំពីសៀវភៅណែនាំនេះ

## ១.១ គោលបំណង

សៀវភៅណែនាំនេះ មានគោលបំណងគាំទ្រដល់ស្ថាប័នស្រាវជ្រាវនៅកម្ពុជា និងអ្នកស្រាវជ្រាវពាក់ព័ន្ធរបស់ស្ថាប័នទាំងនោះ ក្នុងការធ្វើការស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់ បរិយាបន្ន និងឆ្លើយតបទៅនឹងបរិបទ ដែលរួមចំណែកដល់ការរៀបចំគោលនយោបាយ និងកម្មវិធី ផ្អែកលើទិន្នន័យ។ រៀបរៀងឡើងសម្រាប់បណ្ដាញស្រាវជ្រាវនៃកម្មវិធីពន្លកចំណេះ សៀវភៅណែនាំនេះផ្ដល់នូវការណែនាំជាក់ស្ដែងអំពីរបៀបធ្វើការស្រាវជ្រាវប្រកបដោយក្រមសីលធម៌ និងមានមូលដ្ឋានគ្រឹះវិធីសាស្ត្រត្រឹមត្រូវ។ សៀវភៅនេះត្រូវបានរៀបចំឡើងជាឯកសារយោងសម្រាប់ដៃគូនៃកម្មវិធីពន្លកចំណេះ ដើម្បីឱ្យការរៀបចំ និងការអនុវត្តការស្រាវជ្រាវរបស់ពួកគេកាន់តែមានភាពរឹងមាំ។

## ១.២ ដំណើរការរៀបចំ

ឯកសារនេះត្រូវបានរៀបចំឡើងដោយមានកិច្ចសហការជាមួយដៃគូកម្មវិធី ដូចជា ដៃគូយុទ្ធសាស្ត្រ[1] (ដែលពីមុនត្រូវបានគេស្គាល់ថាជាដៃគូស្នូលក្នុងដំណាក់កាលទី១) ក្រុមជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និង បរិយាបន្នសង្គម (GEDSI)[2] ក្រុមការងារពន្លកចំណេះ និងអង្គភាពវាយតម្លៃ និងរៀនសូត្រ របស់អង្គការមូលនិធិអាស៊ី។ ការទទួលមតិយោបល់ត្រលប់ និងមតិកែលម្អពីដៃគូយុទ្ធសាស្ត្រ ត្រឹមថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ និងពីក្រុមជំនាញផ្នែក GEDSI (CDPO, GADC, និង WPM) ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។ អង្គភាពវាយតម្លៃ និងរៀនសូត្រ របស់អង្គការមូលនិធិអាស៊ី បានធ្វើការកែសម្រួលឯកសារនេះបន្ថែមទៀត ក្នុងខែមិថុនា ឆ្នាំ២០២៥។ ឯកសារនេះអាចមានការកែសម្រួល និងធ្វើបច្ចុប្បន្នភាពបន្ថែមទៀត ផ្អែកលើបទពិសោធ និងការអនុវត្តជាក់ស្ដែង។



# ១.៣ អ្នកអានគោលដៅ

អ្នកអានគោលដៅនៃឯកសារនេះ គឺដៃគូនៃកម្មវិធីពន្លកចំណេះ ដែលមានដូចជា ដៃគូយុទ្ធសាស្ត្រ ដៃគូនវានុវត្តន៍[3] ដៃគូសហការ ក្រុមជំនាញផ្នែក GEDSI គណៈកម្មាធិការប្រឹក្សាផ្នែកបច្ចេកទេស[4] និងមន្ត្រីបង្គោលមកពីក្រសួងស្ថាប័ននានា[5]។ កម្មវិធីពន្លកចំណេះក៏សូមលើកទឹកចិត្តឱ្យអ្នកស្រាវជ្រាវ និងនិស្សិត ប្រើប្រាស់ឯកសារនេះ នៅពេលរៀបចំ ការស្រាវជ្រាវរបស់ខ្លួនផងដែរ។

---

1 ដៃគូយុទ្ធសាស្ត្ររួមមាន វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) មជ្ឈមណ្ឌលខេមរសិក្សា (CKS) មជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS) និងវេទិកាអនាគត (FF)។ សម្រាប់ព័ត៌មានបន្ថែមអំពីដៃគូជាយុទ្ធសាស្ត្រសូមចុចទីនេះ។

2 ក្រុមជំនាញផ្នែក (GEDSI) រួមមានអង្គការជនពិការកម្ពុជា (CDPO) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) និងអង្គការនារីដើម្បីសន្តិភាព (WPM)។ សម្រាប់ព័ត៌មានបន្ថែមអំពីដៃគូសហការ GEDSI សូមចុចទីនេះ។

3 ដៃគូផ្នែកនវានុវត្តន៍ទទួលបានថវិកាគាំទ្រពីមូលនិធិនវានុវត្តន៍វត្តពន្លកចំណេះ ដែលជាដំណើរការប្រកួតប្រជែងសម្រាប់អង្គការនៅកម្ពុជាដើម្បីស្នើ និងសាកល្បងគំនិតច្នៃប្រឌិតថ្មីរបស់ពួកគេជាការឆ្លើយតបទៅនឹងឱកាស/បញ្ហាគោលនយោបាយនៅកម្រិតជាតិឬថ្នាក់ក្រោមជាតិ។ សម្រាប់ព័ត៌មានបន្ថែមអំពីដៃគូផ្នែកនវានុវត្តន៍សូមចុចទីនេះ។

4 គណៈកម្មាធិការដឹកនាំនៅកម្រិតបច្ចេកទេស គឺជាស្ថាប័នពាក់កណ្ដាលផ្លូវការមួយដែលមានសមាជិកប្រមាណដប់ពីររូប ដើម្បីគាំទ្រដល់ការអនុវត្ត និងធានាបាននូវការចូលរួមយ៉ាងសកម្ម និងភាពជាម្ចាស់របស់រដ្ឋាភិបាល។សមាជិក រួមមានតំណាងមកមកពីក្រសួងស្ថាប័ននានាដែលចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំផែនការ ការអនុវត្ត និងការពិនិត្យឡើងវិញលើគោលនយោបាយ អ្នកជំនាញបច្ចេកទេស អ្នកផ្ដល់ព័ត៌មានសំខាន់ៗ និងតំណាងមកពីស្ថាប័នសិក្សាស្រាវជ្រាវ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធនឹងដំណើរការគោលនយោបាយចម្រុះ។ សម្រាប់ព័ត៌មានបន្ថែមអំពីគណៈកម្មាធិការប្រឹក្សាផ្នែកបច្ចេកទេសសូមចុចទីនេះ។

5 មន្ត្រីបង្គោលមកពីក្រសួងស្ថាប័ន គឺជាតំណាងរដ្ឋាភិបាលដែលត្រូវបានជ្រើសរើសឲ្យធ្វើការ ជាមួយកម្មវិធីពន្លកចំណេះលើការផ្លាស់ប្ដូរព័ត៌មាន ការចូលរួមក្នុងការពិភាក្សាគោលនយោបាយរបស់កម្មវិធី ការសម្របសម្រួលទំនាក់ទំនង និងការចូលរួមក្នុងសកម្មភាពកសាងសមត្ថភាពនានា។ សម្រាប់ព័ត៌មានបន្ថែមអំពី មន្ត្រីបង្គោលរបស់ក្រសួងសូមចុចទីនេះ។

# ១.៤ របៀបប្រើប្រាស់សៀវភៅណែនាំនេះ

សៀវភៅណែនាំនេះ ចាប់ផ្តើមជាមួយការបង្ហាញត្រួសៗអំពីដំណាក់កាលផ្សេងៗនៃដំណើរការស្រាវជ្រាវ។ បន្ទាប់មក សៀវភៅណែនាំនេះនឹងរៀបរាប់លម្អិតអំពីដំណាក់កាលនីមួយៗនៃដំណើរការស្រាវជ្រាវ។ សៀវភៅណែនាំនេះត្រូវបានរៀបចំជាប្រាំបួនផ្នែកធំៗ ដោយផ្នែកនីមួយៗគ្របដណ្តប់លើទិដ្ឋភាពសំខាន់ៗនៃការធ្វើការស្រាវជ្រាវប្រកបដោយគុណភាព។

## I

### អំពីសៀវភៅណែនាំ

ផ្នែកនេះរៀបរាប់អំពីគោលបំណង និងដំណើរការនៃការរៀបចំសៀវភៅណែនាំនេះ។ ផ្នែកនេះក៏បង្ហាញផងដែរដល់អ្នកអាន សៀវភៅណែនាំនេះ និងសារសំខាន់នៃការស្រាវជ្រាវដែលហ្មត់ចត់ប្រកបដោយក្រមសីលធម៌ និងបរិយាបន្ន។

## II

### ដំណើរការស្រាវជ្រាវ

ផ្នែកនេះរៀបរាប់អំពីជំហានសំខាន់ៗ ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តការស្រាវជ្រាវដែលមានគុណភាពខ្ពស់។ ការអនុវត្តតាមជំហានទាំងនេះជួយធានាថា ការស្រាវជ្រាវមានមូលដ្ឋានគ្រឹះវិធីសាស្ត្រត្រឹមត្រូវ មានការទទួលខុសត្រូវផ្នែកក្រមសីលធម៌ និងមានផលជះ។

## III

### ការរៀបចំគ្រោងការស្រាវជ្រាវ

ផ្នែកនេះរៀបរាប់អំពីជំហានជាមូលដ្ឋាន ពាក់ព័ន្ធនឹងការរៀបចំគ្រោងការសិក្សាស្រាវជ្រាវអ្វីមួយ។ ផ្នែកនេះចាប់ផ្តើម ជាមួយនឹងការកំណត់ចំណោទបញ្ហានៃការស្រាវជ្រាវ និងការបង្កើតសំណួរស្រាវជ្រាវឱ្យបានច្បាស់លាស់។ ផ្នែកនេះក៏ផ្តល់នូវការណែនាំអំពីសំយោគបណ្ណាល័យសាស្ត្រ ឬការពិនិត្យលើឯកសារពាក់ព័ន្ធ (literature review) ឱ្យបានគ្រប់ជ្រុងជ្រោយ និងការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវដែលសមស្រប។ លើសពីនេះ ផ្នែកនេះក៏បរិយាយអំពីការរៀបចំសំណាក (sampling) ឱ្យបានរឹងមាំ ដើម្បីធានាថាការស្រាវជ្រាវមានមូលដ្ឋានគ្រឹះវិធីសាស្ត្រត្រឹមត្រូវ និងស្របតាមវត្ថុបំណងរបស់ខ្លួន។

## IV

### ក្រមសីលធម៌នៃការស្រាវជ្រាវ

ផ្នែកនេះបង្ហាញពីគោលការណ៍ស្នូលនៃការស្រាវជ្រាវប្រកបដោយក្រមសីលធម៌។ ផ្នែកនេះរៀបរាប់ពីដំណើរការសុំការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ (informed consent) រួមទាំងកត្តាពិសេស ដែលត្រូវពិចារណា ដើម្បីធានាថាដំណើរការសុំការយល់ព្រមនេះមានអត្ថន័យ និងប្រកបដោយការគោរព។ ផ្នែកនេះក៏គូសបញ្ជាក់ផងដែរអំពីវិធីសាស្ត្រ សម្រាប់ធ្វើការស្រាវជ្រាវ ដែលគិតគូរលើយេនឌ័រ និងផ្តោតលើជនរងគ្រោះជាចម្បង។

## V

## ការប្រមូលទិន្នន័យ

ក្នុងផ្នែកនេះ អ្នកអាននឹងឃើញទិដ្ឋភាពទូទៅនៃវិធីសាស្ត្រប្រមូលទិន្នន័យបែបគុណវិស័យ និងបរិមាណវិស័យ រួមនឹងការណែនាំអំពីរបៀបធានាថាវិធីសាស្ត្រទាំងនេះមានលក្ខណៈបរិយាបន្ន និងបង្កភាពងាយស្រួល សម្រាប់អ្នកចូលរួមទាំងអស់។

## VI

## ការវាយតម្លៃគុណភាពទិន្នន័យ ( DQA )

ផ្នែកនេះណែនាំអំពីគោលគំនិតនៃការវាយតម្លៃគុណភាពទិន្នន័យ និងរៀបរាប់អំពីលក្ខណៈវិនិច្ឆ័យសំខាន់ៗសម្រាប់វាយតម្លៃគុណភាពទិន្នន័យ ដែលបានប្រមូលក្នុងអំឡុងពេលស្រាវជ្រាវ។

## VII

## ការវិភាគទិន្នន័យ

ផ្នែកនេះផ្ដល់នូវការណែនាំជាក់ស្ដែងអំពីការវិភាគទិន្នន័យទាំងគុណវិស័យ ទាំងបរិមាណវិស័យ ដែលជួយឱ្យអ្នកស្រាវជ្រាវអាចទាញសេចក្ដីសន្និដ្ឋានសុក្រិត និងប្រកបដោយអត្ថន័យ។

## VIII

## ការសរសេររបាយការណ៍ស្រាវជ្រាវ

ផ្នែកនេះកំណត់អំពីធាតុផ្សំសំខាន់ៗនៃរបាយការណ៍ស្រាវជ្រាវ និងផ្ដល់នូវគន្លឹះក្នុងការសរសេរលទ្ធផលស្រាវជ្រាវដែលច្បាស់លាស់ អាចទុកចិត្តបាន និងមានគុណភាពខ្ពស់។

## IX

## ការតាមដាន និងវាយតម្លៃលើផលជះនៃការស្រាវជ្រាវ

ផ្នែកចុងក្រោយនេះផ្ដោតលើរបៀបតាមដាន និងវាយតម្លៃផលជះទូទៅនៃការស្រាវជ្រាវ ដោយធានាថាការរកឃើញដែលបានពីការស្រាវជ្រាវ ពិតជារួមចំណែកដល់ការរៀនសូត្រ និងការផ្លាស់ប្ដូរប្រាកដមែន។

អ្នកអានត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់សៀវភៅណែនាំនេះដោយភាពបត់បែន។ លោកអ្នកអាចអានតាមលំដាប់លំដោយ ដើម្បីយល់ដឹងគ្រប់ជ្រុងជ្រោយ ឬអានផ្នែកនីមួយៗដោយផ្ទាល់ ទៅតាមតម្រូវការ ឬដំណាក់កាលបច្ចុប្បន្ននៃដំណើរការស្រាវជ្រាវរបស់លោកអ្នក។ ផ្នែកនីមួយៗមានបញ្ចូល៖

- ឧទាហរណ៍ជាក់ស្តែងដើម្បីបង្ហាញពីគោលគំនិតសំខាន់ៗ
- គន្លឹះមានប្រយោជន៍ដកស្រង់ចេញពីការស្រាវជ្រាវឈានមុខ និងបទពិសោធរបស់អ្នកជំនាញ
- បញ្ជីត្រួតពិនិត្យ និងឧបករណ៍ដើម្បីគាំទ្រដល់ការអនុវត្ត
- ធនធានបន្ថែមសម្រាប់ការសិក្សាស៊ីជម្រៅបន្ថែម

មិនថាលោកអ្នកកំពុងរៀបចំការសិក្សាលើកដំបូង ឬកំពុងសម្រិតសម្រាំងរបៀបរបបស្រាវជ្រាវរបស់ខ្លួននោះទេ សៀវភៅណែនាំនេះគឺជាដៃគូរបស់លោកអ្នក ក្នុងការបង្កើតការស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់ ក្រមសីលធម៌ និងសម្រេចបាននូវផលជះ។

## ១.៥ សារសំខាន់នៃការស្រាវជ្រាវដែលហ្មត់ចត់ ប្រកបដោយក្រមសីលធម៌ និងបរិយាបន្ន

ការស្រាវជ្រាវបែបអនុវត្ត (applied research) គឺមានន័យលើសពីការប្រមូលព័ត៌មាន និងការបោះពុម្ពផ្សាយឯកសារស្រាវជ្រាវ។ ការស្រាវជ្រាវបែបនេះដោះស្រាយបញ្ហា ដែលកំពុងកើតមានជាក់ស្តែងក្នុងពិភពលោក និងមានបំណងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការសម្រួចគោលនយោបាយសាធារណៈ និងកម្មវិធីនានា។ នៅកម្ពុជា កម្មវិធីពន្លកចំណេះប្តេជ្ញាចិត្តពង្រឹងវិស័យស្រាវជ្រាវក្នុងស្រុក ក្នុងការបង្កើតការស្រាវជ្រាវដែលហ្មត់ចត់ ប្រកបដោយក្រមសីលធម៌ និងបរិយាបន្ន ដើម្បីគាំទ្រដល់ការរៀបចំគោលនយោបាយ ដោយផ្អែកលើទិន្នន័យ និងជួយសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ។

របៀបវារៈស្រាវជ្រាវជាតិ (២០២៥-២០៣០) បានគូសបញ្ជាក់ពីភាពចាំបាច់ នៃការបង្កើនការស្រាវជ្រាវ ដឹកនាំដោយអ្នកស្រាវជ្រាវក្នុងស្រុក ពាក់ព័ន្ធនឹងគោលនយោបាយ និងមានលក្ខណៈបរិយាបន្ន ដើម្បីឆ្លើយតបចំពោះអាទិភាពបន្ទាន់របស់ជាតិ ចាប់ពីអាទិភាពក្នុងវិស័យអប់រំ និងសុខភាពសាធារណៈ រហូតដល់ភាពធន់នឹងអាកាសធាតុ និងបរិយាបន្នសេដ្ឋកិច្ច។

ការស្រាវជ្រាវទាំងឡាយ ដែលផ្តល់ព័ត៌មានជាមូលដ្ឋាន សម្រាប់ការរៀបចំគោលនយោបាយសាធារណៈ និងកម្មវិធី ត្រូវតែមានភាពហ្មត់ចត់ ដើម្បីធានាថាទិន្នន័យអាចទុកចិត្តបានត្រឹមត្រូវ និងសំខាន់បំផុត ជាទិន្នន័យដែលមានប្រយោជន៍។ នៅពេលដែលការស្រាវជ្រាវខ្វះភាពហ្មត់ចត់ វាអាចនាំទៅដល់ការសន្និដ្ឋានខុស គោលនយោបាយដែលមិនអាចឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន ឬកម្មវិធីដែលអាចបង្កគ្រោះថ្នាក់ និង/ឬខ្ជះខ្ជាយធនធានជាដើម។

ការស្រាវជ្រាវប្រកបដោយក្រមសីលធម៌ ការពារសេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់អ្នកចូលរួម។ ការស្រាវជ្រាវប្រកបដោយក្រមសីលធម៌ មានន័យថា បានទទួលការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ មានការការពារឯកជនភាព និងការសម្ងាត់របស់បុគ្គល និងកាត់បន្ថយគ្រោះថ្នាក់ឱ្យនៅតិចបំផុត។ នៅពេលការស្រាវជ្រាវត្រូវបានធ្វើឡើងប្រកបដោយក្រមសីលធម៌ វាអាចជួយកសាងទំនុកចិត្តជាមួយសហគមន៍មូលដ្ឋាន និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ដែលធ្វើឱ្យអនុសាសន៍ ដែលបានពីការស្រាវជ្រាវ កាន់តែត្រូវបានទទួលយក។ ការអនុវត្តការស្រាវជ្រាវប្រកបដោយក្រមសីលធម៌ មានសារសំខាន់យ៉ាងខ្លាំង ក្នុងការធានាថាការស្រាវជ្រាវផ្តល់អត្ថប្រយោជន៍ដល់អ្នកពាក់ព័ន្ធគ្រប់រូប មិនមែនត្រឹមតែអ្នកស្រាវជ្រាវ និង/ឬអ្នកផ្តល់មូលនិធិប៉ុណ្ណោះទេ។

កម្មវិធីពន្លកចំណេះផ្តោតការយកចិត្តទុកដាក់លើតម្រូវការ ដែលធ្វើយ៉ាងណាឱ្យការស្រាវជ្រាវនៅកម្ពុជាមានលក្ខណៈបរិយាបន្ន ពោលគឺមានភាពជាតំណាងពីក្រុមចម្រុះនៅទូទាំងប្រទេស។ គោលនយោបាយសាធារណៈដែលផ្តោតលើការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ត្រូវតែបញ្ចូលទស្សនៈ និងបទពិសោធរបស់មនុស្សគ្រប់រូប។ ជាប្រពៃណី ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយ សម្រាប់ និងជាមួយក្រុមដែលមានឥទ្ធិពល។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវបែបអនុវត្តដែលហ្មត់ចត់ ត្រូវតែគិតគូរពីទស្សនៈរបស់ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសអ្នកដែលកន្លងមកមិនសូវមានតំណាងនៅក្នុងការស្រាវជ្រាវ និងការពិភាក្សាជាសាធារណៈនានា ដូចជាស្ត្រី ជនមានពិការភាព និងជនជាតិភាគតិច ឬក្រុមភាគតិចក្នុងតំបន់ ជាដើម។



# ២. ដំណើរការស្រាវជ្រាវ

ផ្នែកនេះរៀបរាប់អំពីជំហានសំខាន់ៗដែលពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តការស្រាវជ្រាវដែលមានគុណភាពខ្ពស់។ ការអនុវត្តតាមជំហានទាំងនេះជួយធានាថាការស្រាវជ្រាវមានមូលដ្ឋានគ្រឹះវិធីសាស្ត្រត្រឹមត្រូវ មានការទទួលខុសត្រូវផ្នែកក្រមសីលធម៌ និងមានផលជះ។

## ១. រៀបចំគ្រោងការស្រាវជ្រាវ

- កំណត់ចំណោទបញ្ហានៃការស្រាវជ្រាវ
- ពិនិត្យសំយោគបណ្ណាល័យសាស្ត្រ ឬឯកសារពាក់ព័ន្ធឱ្យបានគ្រប់ជ្រុងជ្រោយ
- បង្កើតសំណួរស្រាវជ្រាវ គោលបំណង និងសម្មតិកម្ម (ក្នុងករណីចាំបាច់)
- ជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ នីតិវិធីនិងឧបករណ៍ប្រមូលទិន្នន័យ និងវិធីសាស្ត្រវិភាគដែលសមស្រប
- កំណត់ពីរបៀបរៀបចំសំណាក ទីតាំងសម្រាប់ចុះធ្វើការសិក្សា និងអ្នកចូលរួមគោលដៅ
- រៀបចំសំណួរលម្អិតសម្រាប់ការស្រាវជ្រាវ និងសាកល្បងប្រើប្រាស់សំណួរទាំងនេះ ដើម្បីសម្រិតសម្រាំងវិធីសាស្ត្រស្រាវជ្រាវ



## ២. ធានាថាការស្រាវជ្រាវគោរពតាមគោលការណ៍ណែនាំផ្នែកក្រមសីលធម៌

- ធ្វើការវាយតម្លៃលើហានិភ័យ ប្រសិនបើធ្វើការស្រាវជ្រាវជាមួយមនុស្ស
- រៀបចំទម្រង់បែបបទសុំការយល់ព្រម និងរៀបចំពិធីសារ ដើម្បីទទួលបានការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់
- ទទួលបានការឯកភាពពីគណៈកម្មាធិការត្រួតពិនិត្យក្រមសីលធម៌ ប្រសិនបើចាំបាច់ ( ឧ. ការយល់ព្រមពី IRB, ការយល់ព្រមពី NECHR, ការយល់ព្រមពីគណៈកម្មាធិការត្រួតពិនិត្យបច្ចេកទេស ។ល។ )
- ធានាថាការស្រាវជ្រាវនឹងអនុលោមតាមគោលការណ៍ណែនាំផ្នែកក្រមសីលធម៌ទាំងអស់ ទាក់ទងនឹងភាពជាតំណាង ឯកជនភាព និងការសម្ងាត់ សុវត្ថិភាពអ្នកចូលរួម ការកាត់បន្ថយទិន្នន័យ និងការប្រើប្រាស់ទិន្នន័យប្រកបដោយការទទួលខុសត្រូវ
- រៀបចំផែនការគ្រប់គ្រងទិន្នន័យ

## ៣. ប្រមូលទិន្នន័យ

- ប្រើប្រាស់ឧបករណ៍ និងនីតិវិធីជាប្រព័ន្ធដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួចសម្រាប់ការប្រមូលទិន្នន័យ
- ធានាសង្គតិភាព និងភាពត្រឹមត្រូវក្នុងការប្រមូលទិន្នន័យ (ឧ. ការវាយតម្លៃគុណភាពទិន្នន័យ)

## ៤. វិភាគទិន្នន័យ

- ប្រើប្រាស់វិធីសាស្ត្រវិភាគសមស្រប ដែលស្របតាមគ្រោងការស្រាវជ្រាវ
- ផ្ទៀងផ្ទាត់ប្រភពទិន្នន័យ ក្នុងករណីអាចធ្វើទៅបាន

## ៥. សរសេររបាយការណ៍ស្រាវជ្រាវ រួមទាំងសេចក្តីសន្និដ្ឋាន និងអនុសាសន៍

- ពិចារណាលើដែនកំណត់ និងភាពពាក់ព័ន្ធ ផ្នែកគោលនយោបាយ និងការអនុវត្ត

## ៦. ដាក់របាយការណ៍ស្រាវជ្រាវទៅក្នុងដំណើរការពិនិត្យដោយអ្នកជំនាញដូចគ្នា (peer-review)

- ធានាថារបាយការណ៍ស្រាវជ្រាវឆ្លងកាត់ដំណើរការពិនិត្យដោយអ្នកជំនាញដូចគ្នាយ៉ាងហ្មត់ចត់
- បញ្ចូលមតិកែលម្អ និងកែសម្រួលរបាយការណ៍ឡើងវិញ ដើម្បីបង្កើនភាពច្បាស់លាស់ ភាពត្រឹមត្រូវ និងគុណភាព

## ៧. ផ្សព្វផ្សាយលទ្ធផល

- រៀបចំផែនការផ្សព្វផ្សាយ
- ធានាថាលទ្ធផលនៃការស្រាវជ្រាវ ងាយស្រួលយល់ សម្រាប់អ្នករៀបចំគោលនយោបាយ អ្នកអនុវត្ត និងសាធារណជនទូទៅ
- គាំទ្រឱ្យមានការទទួលយកការរកឃើញនៃការស្រាវជ្រាវ តាមរយៈការពិភាក្សា និងសកម្មភាពពង្រឹងសមត្ថភាព
- ចែករំលែកលទ្ធផលក្នុងទម្រង់ងាយស្រួលយល់ ជាមួយអ្នកចូលរួមស្រាវជ្រាវ និងសហគមន៍គោលដៅ

## ៨. តាមដាន និងវាយតម្លៃផលជះនៃការស្រាវជ្រាវ

- កំណត់និយមន័យ "ផលជះ (impact)" នៅក្នុងបរិបទនៃការស្រាវជ្រាវរបស់អ្នក (ឧ. ការទទួលយករបកគំហើញនៃការស្រាវជ្រាវទៅប្រើប្រាស់ក្នុងការរៀបចំគោលនយោបាយ ការកែលម្អកម្មវិធី ការលើកកម្ពស់ភាពអង់អាចរបស់សហគមន៍)
- តាមដានពីរបៀប និងទីកន្លែងដែលលទ្ធផលស្រាវជ្រាវត្រូវបានប្រើប្រាស់ ដោយអ្នកណា និងសម្រាប់គោលបំណងអ្វី
- វាយតម្លៃលទ្ធផលរយៈពេលខ្លី និងរយៈពេលវែង តាមរយៈឧបករណ៍នានា ដូចជា មតិយោបល់ត្រលប់ពីអ្នកពាក់ព័ន្ធ ការតាមដានប្រព័ន្ធផ្សព្វផ្សាយ ឬការសិក្សាតាមដានបន្ត
- ពិចារណាលើមេរៀនដែលទទួលបាន ដើម្បីផ្តល់ព័ត៌មានដល់កិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវនាពេលអនាគត និងបង្កើនភាពពាក់ព័ន្ធ និងប្រសិទ្ធភាព ដល់កម្រិតអតិបរមា
- ចងក្រងឯកសារ និងចែករំលែកការយល់ដឹង ដើម្បីគាំទ្រការរៀនសូត្រក្នុងសហគមន៍អ្នកស្រាវជ្រាវទាំងមូល



# ៣. ការរៀបចំគម្រោង ការស្រាវជ្រាវ

## ៣.១ កំណត់ចំណោទបញ្ហានៃការស្រាវជ្រាវ និងសំណួរស្រាវជ្រាវ

**ចំណោទបញ្ហានៃការស្រាវជ្រាវ (research problem)** គឺជាបញ្ហាជាក់លាក់ ឬចំណុចខ្វះខាតក្នុងចំណេះដឹងដែលមានស្រាប់ ដែលការស្រាវជ្រាវមានគោលបំណងដោះស្រាយ។ វាអាចជាបញ្ហាជាក់ស្តែងដែលតម្រូវឱ្យមានដំណោះស្រាយក្នុងពិភពពិត ឬជាបញ្ហាទ្រឹស្តីដែលពង្រីកការយល់ដឹងរបស់យើងអំពីប្រធានបទមួយ។

ដើម្បីកំណត់ចំណោទបញ្ហានៃការស្រាវជ្រាវ ជារឿយៗ អ្នកស្រាវជ្រាវចាប់ផ្តើមដោយអានឯកសារដែលមានស្រាប់ ដូចជា ការសិក្សាតាមបែបសិក្សាធិការ (academic studies) របាយការណ៍ និងអត្ថបទផ្សេងៗ។ អ្នកស្រាវជ្រាវក៏អាចយោងលើកិច្ចពិភាក្សាជាសាធារណៈ ដើម្បីស្វែងយល់បន្ថែមអំពីអ្វីដែលត្រូវបានគេដឹងរួចហើយអំពីប្រធានបទណាមួយ ដែលអាចនៅមានចំណុចខ្វះខាត ឬសំណួរដែលមិនទាន់មានចម្លើយ។

ខណៈពេលដែលចំណោទបញ្ហានៃការស្រាវជ្រាវ គឺជាបញ្ហាធំទូលាយ ដែលការស្រាវជ្រាវមានគោលបំណងសិក្សាស្វែងយល់**សំណួរស្រាវជ្រាវ (research questions)** គឺជាសំណួរផ្តោតជាក់លាក់ និងកំណត់ទិសដៅច្បាស់លាស់សម្រាប់ការសិក្សា។



## សំណួរស្រាវជ្រាវដែលល្អ គឺជាសំណួរដែល៖

- ច្បាស់លាស់ និងផ្តោតលើប្រធានបទជាក់លាក់អ្វីមួយ
- អាចស្រាវជ្រាវបាន ដោយប្រើប្រាស់ទិន្នន័យពីប្រភពបឋម (primary) និង/ឬពីប្រភពដែលមានទិន្នន័យស្រាប់ (secondary)
- អាចធ្វើទៅបាន ជាមួយពេលវេលា និងធនធាន ដែលអ្នកមានសម្រាប់ការសិក្សារបស់អ្នក
- ជាក់លាក់ ជៀសវាងសំណួរដែលទូលំទូលាយពេក ឬចង្អៀតពេក
- ស្មុគស្មាញ និងអាចជជែកវែកញែកបាន (មិនអាចឆ្លើយថា បាទ-ចាស/ទេ)
- ពាក់ព័ន្ធ និងជាសំណួរដើម មិនចម្លងពីគេ (ឆ្លើយតបនឹងបញ្ហាដែលមិនទាន់មានចម្លើយ)

**សំណួរស្រាវជ្រាវរង** (sub-research questions) ជួយបំបែកសំណួរស្រាវជ្រាវចម្បងជាផ្នែកតូចៗ ដើម្បីឱ្យអ្នកស្រាវជ្រាវស្វែងយល់ប្រធានបទនោះក្នុងវិធីសាស្ត្រដែលមានរចនាសម្ព័ន្ធ និងហេតុផល។ ប្រធានបទកាន់តែស្មុគស្មាញ កាន់តែត្រូវការសំណួរស្រាវជ្រាវរង ដើម្បីជួយរកចម្លើយឱ្យសំណួរចម្បង។ ជាធម្មតា គេបញ្ចូលសំណួររងប្រហែល ៤ ទៅ៥ សំណួរ។ ទោះជាយ៉ាងណា ប្រសិនបើចំនួនសំណួរស្រាវជ្រាវរងមានច្រើនជាងនេះ គេប្រហែលជាត្រូវកំណត់សំណួរស្រាវជ្រាវចម្បងឡើងវិញ។

## ធ្វើឱ្យសំណួរស្រាវជ្រាវកាន់តែមានលក្ខណៈបរិយាបន្ន

វាជាការសំខាន់ និងចាំបាច់ណាស់ ដែលគេត្រូវគិតគូរលើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ទៅក្នុងគ្រប់ដំណាក់កាលនៃការសិក្សាដោយមិនគិតថាតើការសិក្សានោះផ្តោតលើបញ្ហា GEDSI ដោយផ្ទាល់ មានគោលបំណងបញ្ជ្រាប GEDSI ឬដោះស្រាយប្រធានបទដែលទូលំទូលាយនោះទេ។ ការបញ្ចូល GEDSI ទៅក្នុងដំណើរការស្រាវជ្រាវទាំងមូលជួយធានាឱ្យការសិក្សាមានលក្ខណៈបរិយាបន្ន និងឆ្លើយតបទៅនឹងតម្រូវការ និងបទពិសោធរបស់ក្រុមចម្រុះ។

សូមពិចារណាពី**បរិបទ (positionality)**ផ្ទាល់ខ្លួនរបស់អ្នកក្នុងនាមជាអ្នកស្រាវជ្រាវ។ តើសាវតារ អត្តសញ្ញាណ និងបរិបទ ស្ថាប័នរបស់អ្នក ជាកត្តាសម្រេចសំណួរដែលអ្នកសួរ និងការសន្មត់ដែលអ្នកនាំមក យ៉ាងដូចម្តេចខ្លះ? សួរថា៖តើសំណួរស្រាវជ្រាវត្រូវបានរៀបចំឡើង ផ្តោតលើក្តីកង្វល់ក្នុងមូលដ្ឋាន បទពិសោធជាក់ស្តែងនិងទស្សនវិជ្ជាចម្រុះដែរឬទេ?

**បរិបទផ្ទាល់ខ្លួន (positionality)** ក្នុងការស្រាវជ្រាវ សំដៅលើបរិបទសង្គម និងនយោបាយដែលសម្រេចអត្តសញ្ញាណរបស់អ្នកស្រាវជ្រាវ ដូចជា ពូជសាសន៍ យេនឌ័រ វណ្ណៈ និងប្រវត្តិវប្បធម៌ និងថាតើបរិបទផ្ទាល់ខ្លួននេះមានឥទ្ធិពលលើ ទស្សនយល់ឃើញ អន្តរកម្ម និងការបកស្រាយរបស់អ្នកស្រាវជ្រាវ ក្នុងដំណើរការស្រាវជ្រាវទាំងមូលយ៉ាងដូចម្តេច។ ការទទួលស្គាល់បរិបទផ្ទាល់ខ្លួន ជួយធានាបាននូវការត្រិះរិះពិចារណា តម្លាភាព និងការចូលរួមប្រកបដោយក្រមសីលធម៌ក្នុងការបង្កើតការស្រាវជ្រាវ។ វាពិតជាមានសារសំខាន់ណាស់ក្នុងការស្រាវជ្រាវបែបគុណវិស័យ និងការចូលរួមដែលអំណាចគ្របដណ្តប់កំពុងមានអានុភាព។

## ៣.២ សំយោគបណ្ណាល័យសាស្ត្រ ឬការពិនិត្យលើឯកសារពាក់ព័ន្ធ

សំយោគបណ្ណាល័យសាស្ត្រ ឬការពិនិត្យលើឯកសារពាក់ព័ន្ធ គឺជាដំណើរការនៃការកំណត់ វិភាគ និងសំយោគការស្រាវជ្រាវ និងស្នាដៃសិក្សាដែលមានស្រាប់ពាក់ព័ន្ធនឹងប្រធានបទជាក់លាក់ណាមួយ។ ការធ្វើដូចនេះជួយអ្នកស្រាវជ្រាវឱ្យយល់ពីអ្វីដែលត្រូវបានសិក្សារួចហើយ កំណត់ពីគម្លាតនៃចំណេះដឹង និងកសាងមូលដ្ឋានគ្រឹះសម្រាប់ការស្រាវជ្រាវផ្ទាល់ខ្លួនរបស់ពួកគេ។

### ដំណើរការពិនិត្យលើឯកសារពាក់ព័ន្ធ៖

ជំហានទី១

#### ស្វែងរកប្រភពពាក់ព័ន្ធ

ប្រើប្រាស់ម៉ាស៊ីនស្វែងរកឯកសារតាមបែបសិក្សាធិការលើអ៊ីនធឺណិត (online academic search engines) រកមើលសៀវភៅ និងទិនានុប្បវត្តិនៅបណ្ណាល័យ និងពិគ្រោះជាមួយបណ្តាញវិជ្ជាជីវៈ ឬបណ្តាញសិក្សារបស់អ្នក ប្រសិនបើឯកសារមួយចំនួនមិនងាយរកបាន

ជំហានទី២

#### កំណត់លក្ខណៈវិនិច្ឆ័យនៃការបញ្ចូល និងការដកចេញ

សម្រេចចិត្តពីប្រភពឯកសារដែលពាក់ព័ន្ធ ផ្អែកលើកាលបរិច្ឆេទបោះពុម្ពផ្សាយ ការផ្តោតលើទីតាំងភូមិសាស្ត្រ វិធីសាស្ត្រស្រាវជ្រាវដែលបានប្រើ និងទស្សនៈយល់ឃើញ ឬទស្សនវិស័យផ្សេងៗគ្នា។

ជំហានទី៣

### ជ្រើសរើសឯកសារដែលអាចទុកចិត្តបាន និងមានប្រយោជន៍

ផ្តោតលើប្រភពដែលមានគុណភាពខ្ពស់ ពាក់ព័ន្ធនឹងប្រធានបទរបស់អ្នក និងបោះពុម្ពផ្សាយដោយអ្នកស្រាវជ្រាវ ឬស្ថាប័នដែលទុកចិត្តបាន។

ជំហានទី៤

### រៀបចំការពិនិត្យឯកសារពាក់ព័ន្ធ

រៀបចំគ្រោងរចនាសម្ព័ន្ធនៃការពិនិត្យលើឯកសារពាក់ព័ន្ធ ( ឧ. តាមកាលប្បវត្តិ តាមប្រធានបទ តាមវិធីសាស្រ្ត ឬតាមទស្សន )។

ជំហានទី៥

### សំយោគព័ត៌មាន

បែងចែកគំនិតសំខាន់ៗជាក្រុម និងភ្ជាប់គំនិតសំខាន់ៗពីប្រភពផ្សេងៗគ្នាជាមួយគ្នា ដើម្បីបង្ហាញពីទំនាក់ទំនងរវាងគំនិតទាំងនេះជាមួយគ្នា និងថាតើគំនិតទាំងនេះមានទំនាក់ទំនងបែបណាជាមួយសំណួរស្រាវជ្រាវរបស់អ្នក។

ជំហានទី៦

### វិភាគព័ត៌មានដែលមានស្រាប់ឱ្យបានល្អិតល្អន់

កំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃប្រភពនីមួយៗ បង្ហាញពីចំណុចខ្វះខាតនៅក្នុងឯកសារពាក់ព័ន្ធ និងស្វែងយល់ពីភាពស្រដៀងគ្នា និងភាពខុសគ្នានៅក្នុងលទ្ធផលរកឃើញ ឬទឡ្ហីករណ៍នានា។

## វិធីនានាសម្រាប់សម្គាល់ប្រភពព័ត៌មានដែលគួរឱ្យទុកចិត្តបាន

| ប្រភពព័ត៌មានដែលគួរឱ្យទុកចិត្តបាន | ប្រភពព័ត៌មាន ដែលទំនងជាមិនអាចទុកចិត្តបាន |
| --- | --- |
| អ្នកនិពន្ធគឺជាបញ្ញវន្ត ឬអ្នកជំនាញដែលត្រូវបានទទួលស្គាល់ មានសម្ព័ន្ធភាពជាមួយស្ថាប័ន និងមានគុណវុឌ្ឍិពាក់ព័ន្ធ | មិនមានអ្នកនិពន្ធ ឬសម្ព័ន្ធភាពជាមួយស្ថាប័នច្បាស់លាស់ (ឧ. ការបង្ហោះប្លុកដែលមិនច្បាស់លាស់) |
| បោះពុម្ពផ្សាយដោយទស្សនាវដ្ដី សារព័ត៌មានសាកលវិទ្យាល័យ ឬអង្គការដែលមានកេរ្តិ៍ឈ្មោះ (ឧ. WHO, UN, ADB)? | បោះពុម្ពផ្សាយដោយខ្លួនឯងទាំងជាឯកសារបោះពុម្ព ឬតាមអនឡាញ |
| ព័ត៌មានដែលបង្ហាញគឺផ្អែកលើទិន្នន័យ ហើយអ្នកនិពន្ធផ្ដល់នូវឯកសារយោង | គ្មានឯកសារយោង |
| ខ្លឹមសារមានតុល្យភាព និងមិនមានភាពលម្អៀង | មានភាពលម្អៀងយ៉ាងជាក់ច្បាស់ (ឧ. របាយការណ៍រៀបចំ ដោយមានការផ្ដល់ថវិកាគាំទ្រពីក្រុមហ៊ុនឯកជនដែលមានទំនាស់ផលប្រយោជន៍) |
| ប្រភពព័ត៌មានមានបច្ចុប្បន្នភាព និងពាក់ព័ន្ធនឹងបរិបទបច្ចុប្បន្ន | ព័ត៌មានមិនទាន់សភាពការណ៍ ឬមិនអាចផ្ទៀងផ្ទាត់បាន |
| ប្រភពព័ត៌មានត្រូវបានត្រួតពិនិត្យដោយអ្នកជំនាញក្នុងវិស័យដូចគ្នា | បោះពុម្ពផ្សាយនៅលើវេទិកា ដែលខ្វះស្តង់ដារពិនិត្យផ្ទៀងផ្ទាត់ (ឧ. វេទិកាអនឡាញដែលពុំមានការផ្ទៀតផ្ទាត់មាតិកា ។ល។) |

# ការធ្វើឱ្យការពិនិត្យឯកសារពាក់ព័ន្ធកាន់តែមានលក្ខណៈបរិយាបន្ន

ពិនិត្យពិច័យឱ្យបានល្អិតល្អន់ ថាតើចំណេះដឹងពីប្រភពណាខ្លះត្រូវបានផ្តល់អាទិភាព នៅក្នុងឯកសារពាក់ព័ន្ធដែលមានស្រាប់ ហើយចំណេះដឹងរបស់អ្នកណាដែលខ្វះចន្លោះ ជាពិសេសទាក់ទងនឹងសហគមន៍កម្ពុជា ដែលត្រូវបានផាត់ចេញ ឬមានភាពតំណាងតិចតួច។ តើអ្នកបានរួមបញ្ចូលប្រភពជាភាសាខ្មែរ ឬសរសេរដោយបញ្ញវន្តខ្មែរ តួអង្គសង្គមស៊ីវិល ឬសហគមន៍គោលដៅ ហើយឬនៅ ?

## ៣.៣ គ្រោងការស្រាវជ្រាវ (Research Design)

**គ្រោងការរៀបចំការស្រាវជ្រាវ** គឺជាប្លង់មេសម្រាប់ការសិក្សាណាមួយ។ មុនពេលចាប់ផ្តើមគម្រោងស្រាវជ្រាវមួយ អ្នកស្រាវជ្រាវត្រូវរៀបចំផែនការរួមសម្រាប់ការស្រាវជ្រាវនោះ ដោយត្រូវបញ្ចូលប្រភេទទិន្នន័យដែលត្រូវប្រមូល ប្រមូលពីប្រភពណា និងរបៀបវិភាគទិន្នន័យដើម្បីឆ្លើយនឹងសំណួរស្រាវជ្រាវ។

**ការរៀបចំនេះរួមបញ្ចូលទាំងការសម្រេចចិត្តអំពី៖**

**១**

តើអ្នកគ្រោងធ្វើការសិក្សាប្រភេទណា (ឧ. ការស្រាវជ្រាវបែបស្វែងយល់, បែបពិពណ៌នា,បែបពន្យល់)

**២**

តើអ្នកនឹងប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ បរិមាណវិស័យ ឬចម្រុះ

**៣**

តើការសិក្សានេះនឹងធ្វើឡើង ដោយការប្រមូលទិន្នន័យធ្វើឡើងក្នុងពេលតែមួយ (cross-sectional) ឬ ក្នុងរយៈពេលមួយយូរ (longitudinal)

## ការស្រាវជ្រាវបែបស្វែងយល់

ដើម្បីយល់កាន់តែច្បាស់**អំពីបញ្ហាដែលថ្មី មិនច្បាស់លាស់ ឬមិនត្រូវបានយល់ច្បាស់**។ ការស្រាវជ្រាវនេះជួយកំណត់ពីបញ្ហា បញ្ជាក់ពីគោលគំនិតសំខាន់ៗ និងតម្រង់ទិសការស្រាវជ្រាវ នាពេលអនាគត ឬការរៀបចំគោលនយោបាយជាដើម។ វិធីសាស្ត្រស្រាវជ្រាវបែបនេះមានប្រយោជន៍ជាពិសេសនៅពេលដែលមានព័ត៌មានពីមុនតិចតួច ឬសម្រាប់ការស្រាវជ្រាវលើប្រធានបទដែលលេចចេញថ្មីៗ ឬប្រធានបទរសើប។ វិធីសាស្ត្រទូទៅ រួមមាន ការកំណត់ ភាគីពាក់ព័ន្ធ ការវិភាគបរិបទ ការពិនិត្យគោលនយោបាយ និងការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ។

## ឧទាហរណ៍

- ស្វែងយល់ពីការយល់ដឹងរបស់សាធារណជនអំពីកម្មវិធីគាំពារសង្គមថ្មីៗ។
- កំណត់តួអង្គសំខាន់ៗដែលពាក់ព័ន្ធក្នុងគំនិតផ្តួចផ្តើមអប់រំឌីជីថលនៅតំបន់ជនបទ។
- ការធ្វើផែនទីទិដ្ឋភាពគោលនយោបាយពាក់ព័ន្ធនឹងសេវាសុខភាពផ្លូវចិត្ត

---

## ការស្រាវជ្រាវបែបពិពណ៌នា

មានគោលបំណង**ចងក្រងឯកសារ និងពន្យល់អំពីស្ថានភាព ប្រជាជន ឬបញ្ហាអ្វីមួយ**ឱ្យបានលម្អិត។ ការស្រាវជ្រាវបែបនេះឆ្លើយនឹងសំណួរដូចជា តើមានអ្វីកំពុងកើតឡើង? ឬតើបញ្ហានេះកើតមានញឹកញាប់ប៉ុណ្ណា? ហើយជារឿយៗ ផ្អែកលើការស្ទង់មតិ ការធ្វើសម្ភាសន៍ ឬការសង្កេត។ ការស្រាវជ្រាវប្រភេទនេះ មានប្រយោជន៍សម្រាប់ស្វែងយល់អំពីការអនុវត្តគោលនយោបាយដែលមានស្រាប់ តើគោលនយោបាយទាំងនោះប៉ះពាល់ដល់អ្នកណាខ្លះ និងតើមានការសម្រេចលទ្ធផលអ្វីខ្លះ។ ការស្រាវជ្រាវបែបនេះក៏អាចផ្តល់នូវទិន្នន័យដ៏មានតម្លៃ ដើម្បីគាំទ្រដល់ការកែសម្រួល ឬកំណែទម្រង់គោលនយោបាយផងដែរ។

## ឧទាហរណ៍

- ការចងក្រងឯកសារអំពីការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) នៅតាមបណ្តារាជធានីខេត្ត។
- ការធ្វើផែនទីបង្ហាញពីការប្រើប្រាស់សេវាសុខភាពសាធារណៈដោយជនមានពិការភាព។
- ការវិភាគអំពីរបៀបកសិករខ្នាតតូចរងផលប៉ះពាល់ដោយសារការចុះបញ្ជីដីធ្លី។

**ការស្រាវជ្រាវបែបពន្យល់**

**ស្វែងយល់ពីមូលហេតុដែលអ្វីមួយកើតឡើង ដោយពិនិត្យមើលទំនាក់ទំនង ហេតុ និងផល (causal links) រវាងគោលនយោបាយ និងលទ្ធផល។** ការរៀបចំការស្រាវជ្រាវប្រភេទនេះ ពឹងផ្អែកខ្លាំងលើការពិសោធន៍ ការវិភាគហេតុផល និងការវិភាគបែបស្ថិតិ។

**ឧទាហរណ៍**

- ការសិក្សាពីមូលហេតុដែលអត្រាបោះបង់ការសិក្សានៅតែមានកម្រិតខ្ពស់ក្នុងចំណោមសិស្សមធ្យមសិក្សានៅតំបន់ជនបទ ទោះបីជាមានការលុបបំបាត់ការបង់ថ្លៃក៏ដោយ។
- ការវិភាគកត្តាដែលជះឥទ្ធិពលលើការចូលរួមរបស់ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់។
- ការពិនិត្យមើលមូលហេតុដែលខេត្តមួយចំនួនមានអត្រាប្រឈមខ្ពស់ក្នុងការទទួលបាននូវទឹកស្អាត ទោះបីជាមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រដៀងគ្នាក៏ដោយ។

---

**ការស្រាវជ្រាវបែបវាយតម្លៃ**

វាយតម្លៃថាតើ**កម្មវិធី គោលនយោបាយ ឬអន្តរាគមន៍ណាមួយមានប្រសិទ្ធភាពដែរឬទេ និង/ឬដើម្បីស្វែងយល់ពីផលប៉ះពាល់ទូទៅរបស់វា។** ឧទាហរណ៍ ការស្រាវជ្រាវបែបវាយតម្លៃអាច ផ្តោតលើការស្វែងយល់ថាតើគោលនយោបាយនានាសម្រេចបាននូវគោលដៅរបស់ខ្លួនដែរឬទេ ហើយស្ថិតក្នុងលក្ខខណ្ឌអ្វីខ្លះ។ ការស្រាវជ្រាវនេះជួយឆ្លើយនឹងសំណួរដូចជា តើវាដំណើរការដែរឬទេ? តើវាដំណើរការបានល្អកម្រិតណា? និង ហេតុអ្វីបានជាវាដំណើរការ ឬមិនដំណើរការ? ការស្រាវជ្រាវនេះជារឿយៗប្រើប្រាស់វិធីសាស្រ្តចម្រុះទាំងបរិមាណវិស័យ និងគុណវិស័យ ដើម្បីស្វែងយល់ពីលទ្ធផល និងកែលម្អកម្មវិធីនាពេលអនាគត។

**ឧទាហរណ៍**

- ការវាយតម្លៃផលប៉ះពាល់នៃមូលនិធិសមធម៌សុខាភិបាលលើការបង្កើនលទ្ធភាពទទួលបានសេវាថែទាំសុខភាពសម្រាប់គ្រួសារដែលមានចំណូលទាប។
- ការវាយតម្លៃថាតើកម្មវិធីពង្រឹងសមត្ថភាពគ្រូបង្រៀនបានធ្វើឱ្យលទ្ធផលនៃការអានរបស់សិស្សថ្នាក់ដំបូងនៅតាមសាលារៀនជនបទប្រសើរឡើងកម្រិតណា។
- ការពិនិត្យមើលថាតើគំនិតផ្តួចផ្តើមផ្តល់ ប័ណ្ណកម្មសិទ្ធិដីធ្លីបានធ្វើឱ្យសន្តិសុខនៃការកាន់កាប់ដីធ្លីសម្រាប់សហគមន៍ជនជាតិដើមភាគតិចមានភាពប្រសើរឡើងដែរឬទេ។

**ការស្រាវជ្រាវបែបអនុវត្ត**

**ខិតខំដោះស្រាយបញ្ហាជាក់ស្តែង ដែលកើតមានពិតប្រាកដ** ជាជាងការចូលរួមចំណែកជាទូទៅដល់ចំណេះដឹងផ្នែកទ្រឹស្តី។ ការស្រាវជ្រាវបែបអនុវត្តផ្តល់នូវដំណោះស្រាយដែលគេអាចយកទៅអនុវត្តជាក់ស្តែងដែលអាចត្រូវបានអនុវត្តភ្លាមៗ និងជះឥទ្ធិពលដោយផ្ទាល់លើការសម្រេចចិត្តផ្នែកគោលនយោបាយ។

**ឧទាហរណ៍**

- ការវាយតម្លៃយុទ្ធសាស្រ្តដែលមានប្រសិទ្ធភាពចំណាយខ្ពស់បំផុតសម្រាប់ការកាត់បន្ថយការបំពុលខ្យល់នៅតំបន់ទីក្រុង។
- ការវាយតម្លៃប្រសិទ្ធភាពនៃការកំណត់ពីការខាតបង់ដោយសារការកកស្ទះចរាចរណ៍នៅតំបន់កណ្តាលក្រុង និងរបៀបដែលវាប៉ះពាល់ដល់លំហូរចរាចរណ៍ គុណភាពខ្យល់ និងការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ។
- ការវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការបង្កើតឱកាសការងារជាប់លាប់សម្រាប់កម្មករដែលមានចំណូលទាប ឬជំនាញទាបនៅតំបន់ជនបទ។

---

**ការស្រាវជ្រាវបែបចូលរួម (action research)**

មានការចូលរួមយ៉ាងសកម្មពី**សហគមន៍ដែលរងផលប៉ះពាល់ចូលរួមក្នុងដំណើរការស្រាវជ្រាវ ហើយជារឿយៗ ផ្តោតលើការកំណត់បញ្ហា ការយកដំណោះស្រាយសក្តានុពលទៅអនុវត្តជាក់ស្តែង និងការបង្កើតចំណេះដឹងដែលផ្សារភ្ជាប់នឹងបរិបទជាក់ស្តែង**។ ខុសពីការស្រាវជ្រាវបែបប្រពៃណី ដែលប្រៀបដូចជាការសង្កេតមើលពីចម្ងាយ ការស្រាវជ្រាវបែបចូលរួមត្រូវបានធ្វើឡើងជាមួយ ប្រជាជនផ្ទាល់ ពោលគឺមិនមែនជាការស្រាវជ្រាវអំពី ពួកគេទេ។ ការស្រាវជ្រាវបែបនេះគូសបញ្ជាក់ពីការសហការ ការរៀនសូត្ររួមគ្នា និងការពង្រឹងភាពអង់អាចនៅមូលដ្ឋាន ដែលធ្វើឱ្យការស្រាវជ្រាវបែបនេះមានតម្លៃជាពិសេសនៅក្នុងគំនិតផ្តួចផ្តើមស្រាវជ្រាវតាមសហគមន៍ ឬផ្តោតលើសិទ្ធិ។

**ឧទាហរណ៍**

- ការស្រាវជ្រាវបែបចូលរួមផ្តល់មានការចូលរួមពីគណៈកម្មការគ្រប់គ្រងសាលារៀនក្នុងការដោះស្រាយអត្រាបោះបង់ការសិក្សា។
- ការលើកកម្ពស់ជីវភាពរស់នៅតាមរយៈសហគមន៍ស្រ្តី៖ អង្គការមិនមែនរដ្ឋាភិបាល ចាប់ដៃគូជាមួយ សហគមន៍ស្រ្តីដើម្បីស្វែងយល់ពីឧបសគ្គ និងរួមគ្នាអភិវឌ្ឍគំរូអាជីវកម្មសម្រាប់សហគមន៍ និងការបណ្តុះបណ្តាលជំនាញ។

- ការកាត់បន្ថយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GVB) នៅក្នុងសហគមន៍៖ អាជ្ញាធរ ក្រុងចាប់ដៃជាមួយក្រុមស្រាវជ្រាវ ដើម្បីធ្វើផែនទីអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ បង្កើនការយល់ដឹងតាមរយៈល្ខោនសហគមន៍ និងបង្កើតក្រុមឃ្លាំមើលសហគមន៍។ ទិន្នន័យ និងរឿងរ៉ាវនានាត្រូវបានប្រមូលក្នុងដំណើរការស្រាវជ្រាវទាំងមូល ហើយមតិត្រឡប់ដែលបានពីសហគមន៍ជួយកែសម្រួលអន្តរាគមន៍ឱ្យកាន់តែប្រសើរ។

---

## ការស្រាវជ្រាវគោលនយោបាយ

ផ្តោតលើការស្វែងយល់ ផ្តល់ព័ត៌មាន និងកែលម្អគោលនយោបាយសាធារណៈ។ ការស្រាវជ្រាវប្រភេទនេះពិនិត្យមើលពីរបៀបដែលគោលនយោបាយត្រូវបានរៀបចំឡើង អនុវត្ត និងបទពិសោធជាក់ស្តែង។ ការស្រាវជ្រាវគោលនយោបាយផ្តល់នូវអនុសាសន៍ផ្អែកលើទិន្នន័យ ដើម្បីជួយរដ្ឋាភិបាល សង្គមស៊ីវិល និងតួអង្គអភិវឌ្ឍន៍ធ្វើការសម្រេចចិត្តបានកាន់តែប្រសើរ។ ការស្រាវជ្រាវបែបអនុវត្តប្រភេទនេះគាំទ្រដល់ការសម្រេចគោលដៅនៃរបៀបវារៈស្រាវជ្រាវជាតិ ដោយជួយភ្ជាប់គម្លាតរវាងការស្រាវជ្រាវ ការសម្រេចចិត្តរបស់រដ្ឋាភិបាល និងតម្រូវការរបស់ប្រជាពលរដ្ឋ។

## ឧទាហរណ៍

- ការស្រាវជ្រាវគោលនយោបាយស្តីពីការអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព៖ ការស្រាវជ្រាវគោលនយោបាយ នឹងបញ្ចូលការសិក្សាថ្នាក់ជាតិមួយដែលធ្វើផែនទីបង្ហាញពីអត្រាចុះឈ្មោះចូលរៀនរបស់កុមារមានពិការភាព និងវាយតម្លៃលទ្ធភាពទទួលបានសេវា និងការត្រៀមលក្ខណៈរបស់គ្រូបង្រៀននៅតាមសាលារៀន។ ដៃគូស្រាវជ្រាវនឹងចាប់ដៃគូជាមួយអង្គការពាក់ព័ន្ធដើម្បីធ្វើសម្ភាសន៍ជាមួយគ្រូបង្រៀន ដៃគូគណៈគ្រប់គ្រងសាលារៀននិងមន្ត្រីរដ្ឋាភិបាលភិបាលពាក់ព័ន្ធ។ ការស្រាវជ្រាវនេះនឹងផ្តល់ព័ត៌មានដល់ក្រសួងពាក់ព័ន្ធ ដើម្បីកែសម្រួលគោលការណ៍ណែនាំស្តីពី ការអប់រំបរិយាបន្ន និងរួមចំណែកដល់គំនិតផ្តួចផ្តើមបណ្តុះបណ្តាលគ្រូនិងការផ្តល់ធនធាននៅកម្រិតសាលារៀនតែទទួលបានការគាំទ្រពីអ្នកផ្តល់ជំនួយ។

# ៣.៤ វិធីសាស្ត្រស្រាវជ្រាវ

**វិធីសាស្ត្រស្រាវជ្រាវ**

សំដៅលើវិធីសាស្ត្រជាប្រព័ន្ធ សម្រាប់ធ្វើការស្រាវជ្រាវ ដែលជឿទុកចិត្តបាន និងអាចដោះស្រាយចំណោទបញ្ហានៃការស្រាវជ្រាវបាន។ វិធីសាស្ត្រស្រាវជ្រាវនេះរួមមានវិធីសាស្ត្រ ឧបករណ៍ និងដំណើរការជាក់លាក់ដែលនឹងត្រូវបានប្រើប្រាស់ ដើម្បីប្រមូល វិភាគ និងបកស្រាយទិន្នន័យ ព្រមទាំងហេតុផលនៃការជ្រើសរើសវិធីសាស្ត្រទាំងនោះ។ វិធីសាស្ត្រស្រាវជ្រាវ ដែលច្បាស់លាស់ និងមានហេតុផលត្រឹមត្រូវ ជួយធានាថាការស្រាវជ្រាវនោះអាចជឿទុកចិត្តបាន មានតម្លាភាព និងអាចធ្វើឡើងវិញបាន។

ខណៈពេលដែលគ្រោងការស្រាវជ្រាវ គឺជាផែនការ ឬរចនាសម្ព័ន្ធជារួមនៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវគឺជាបច្ចេកទេស និងដំណើរការជាក់លាក់ដែលត្រូវបានប្រើប្រាស់ ដើម្បីប្រមូល និងវិភាគទិន្នន័យ ក្នុងការស្រាវជ្រាវ។ ការស្រាវជ្រាវអាចប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ បរិមាណវិស័យ ឬវិធីសាស្ត្រទាំងពីរបញ្ចូលគ្នា ដែលគេហៅថា "វិធីសាស្ត្រចម្រុះ"។

---

**ការស្រាវជ្រាវបែបគុណវិស័យ (qualitative research)**

ផ្តោតលើទិន្នន័យមិនមែនជាតួលេខ ដូចជា ប្រតិចារិកនៃសម្ភាសន៍ (interview transcripts) ការសង្កេត និងចម្លើយបើកជាដើម។ ការស្រាវជ្រាវបែបនេះស្វែងយល់ពីរបៀបដែលមនុស្សយល់ បកស្រាយនិងឆ្លងកាត់បទពិសោធជាក់ស្តែង និងមានប្រយោជន៍ជាពិសេស សម្រាប់ឆ្លើយសំណួរដូចជាយ៉ាងដូចម្តេច? ហេតុអ្វី?និងតើវាមានន័យដូចម្តេច? វិធីសាស្ត្រនេះឱ្យតម្លៃលើភាពស៊ីជម្រៅ បរិបទ និងអត្ថន័យ ជាងភាពទូលំទូលាយ និងសមស្របបំផុតសម្រាប់ប្រធានបទស្មុគស្មាញ ឬមិនត្រូវបានគេយល់ច្បាស់។ វិធីសាស្ត្របែបគុណវិស័យដែលគេប្រើប្រាស់ជាទូទៅ រួមមាន៖ សម្ភាសន៍ ការពិភាក្សាក្រុមគោលដៅ និងការសង្កេតជាដើម។

## ការស្រាវជ្រាវបែបបរិមាណវិស័យ

ប្រមូលទិន្នន័យជាលេខ ដោយប្រើឧបករណ៍ផ្សេងៗ ដូចជា ការស្ទង់មតិ ឬការវាយតម្លៃដោយមានការកំណត់លំដាប់លំដោយ និងប្រើប្រាស់វិភាគបែបស្ថិតិ។ ការស្រាវជ្រាវបែបនេះមានបំណងវាស់វែងគំរូ លំនាំឬទំនាក់ទំនង និងឆ្លើយសំណួរ ដូចជា *ប៉ុន្មាន? ញឹកញាប់ប៉ុណ្ណា?* តើមានផលប៉ះពាល់អ្វីខ្លះ?ការរកឃើញនៃការស្រាវជ្រាវបែបបរិមាណវិស័យ ជាញឹកញាប់ អាចត្រូវបានបកស្រាយថាជាការរកឃើញទូទៅសម្រាប់ស្ថិតិសកល (population) បាន អាស្រ័យលើរបៀបដែលគំរូត្រូវបានជ្រើសរើស។ វិធីសាស្ត្របែបបរិមាណវិស័យ ដែលគេប្រើទូទៅរួមមាន ការស្ទង់មតិ ការវិភាគទិន្នន័យពីប្រភពដែលមានស្រាប់ និងការធ្វើគំរូ (modeling)។

---

## វិធីសាស្ត្រចម្រុះ

រួមបញ្ចូលគ្នានូវវិធីសាស្ត្រទាំងបែបគុណវិស័យ ទាំងបែបបរិមាណវិស័យ ដើម្បីផ្តល់នូវរូបភាពកាន់តែពេញលេញអំពីប្រធានបទស្រាវជ្រាវ។ វិធីសាស្ត្រនេះប្រើប្រាស់តួលេខ ដើម្បីបង្ហាញពីអ្វី ដែលកំពុងកើតឡើង និងប្រើប្រាស់រឿងរ៉ាវ ឬបទពិសោធ ដើម្បីពន្យល់ពី *មូលហេតុ ឬរបៀប* ដែលវាកើតឡើង ដែលអនុញ្ញាតឱ្យមានការយល់ដឹងកាន់តែសម្បូរបែប និងស៊ីជម្រៅអំពីបញ្ហា ដែលកំពុងសិក្សា។

# ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវរបស់អ្នក

| | បែបគុណវិស័យ |
|---|---|
| គោលបំណងស្រាវជ្រាវចម្បង | ស្វែងយល់ពីបទពិសោធ និងដំណើរការ |
| សំណួរស្រាវជ្រាវ | *ហេតុអ្វី? យ៉ាងដូចម្ដេច? តើវាមានន័យដូចម្ដេច?* |
| ប្រភេទទិន្នន័យដែលត្រូវការ | ពាក្យសម្ដី រឿងរ៉ាវ ការសង្កេត |
| វិធីសាស្ត្រដែលគេប្រើទូទៅ | សម្ភាសន៍ ការពិភាក្សាក្រុមគោលដៅ ការសង្កេត |
| មានប្រយោជន៍នៅពេល | • ប្រធានបទមួយ ជាប្រធានបទថ្មី ស្មុគស្មាញ ឬមិនមានការស្រាវជ្រាវច្បាស់លាស់<br>• អ្នកចាប់អារម្មណ៍លើការយល់ឃើញ និងគុណតម្លៃរបស់មនុស្សដែលបានឆ្លងកាត់ផ្ទាល់<br>• អ្នកត្រូវការការយល់ដឹងសម្បូរបែប និងស៊ីជម្រៅ មិនមែនត្រឹមតែលំនាំទូទៅទេ<br>• ស្រាវជ្រាវពីប្រធានបទរសើប ដូចជា អំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) ឬការធ្វើចំណាកស្រុក |
| ចំណុចខ្លាំង | ភាពស៊ីជម្រៅ បរិបទ ការយល់ដឹង បទពិសោធផ្ទាល់ |
| ដែនកំណត់ | មិនអាចបកស្រាយថាជារបកគំហើញទូទៅ អាចជាការវិភាគបែបអត្តនោម័ត អាចត្រូវការពេលយូរ |
| ការតម្រូវ | ទាមទារអ្នកសម្របសម្រួលដែលមានជំនាញ និងពេលវេលាសម្រាប់ការកត់ត្រា/ការវិភាគ |

| បែបបរិមាណវិស័យ | វិធីសាស្ត្រចម្រុះ |
| --- | --- |
| វាស់វែងគំរូ លំនាំ ឬទំនាក់ទំនង | ស្វែងយល់ និងវាស់វែងក្នុងពេលតែមួយ |
| *ប៉ុន្មាន ? ញឹកញាប់ប៉ុណ្ណា ? តើមានផលប៉ះពាល់អ្វីខ្លះ ?* | *ការរួមបញ្ចូលគ្នានៃសំណួរ ហេតុអ្វី និងប៉ុន្មាន* |
| ចំនួនការរាប់ និងចម្លើយតាមលំដាប់លំដោយ | ទាំងទិន្នន័យបែបពិពណ៌នា និងជាតួលេខ |
| ការស្ទង់មតិ ការសង្កេតតាមលំដាប់លំដោយ ទិន្នន័យរដ្ឋបាល | ការស្ទង់មតិ + ការសម្ភាស ឬការពិភាក្សាក្រុមដៅ + ការវិភាគបែបបរិមាណវិស័យ |
| • តាមដានការផ្លាស់ប្តូរតាមពេលវេលា (ឧ. ការសិក្សាដើមគ្រា និងការសិក្សាចុងគ្រា)<br>• ប្រៀបធៀបរវាងតំបន់ ឬក្រុមផ្សេងៗ<br>• អ្នកត្រូវការទិន្នន័យជាតួលេខ ដើម្បីផ្តល់ព័ត៌មានសម្រាប់ការរៀបចំគោលនយោបាយ ឬថវិកា | • ស្វែងយល់ទាំងអ្វីដែលកំពុងកើតឡើង និងមូលហេតុ<br>• វាយតម្លៃកម្មវិធី/គោលនយោបាយដែលមានលក្ខណៈស្មុគស្មាញ<br>• ផ្តោតលើក្រុមគោលដៅ ឬអ្នកពាក់ព័ន្ធចម្រុះ<br>• ការកំណត់ពីវិសាលភាព ឬការសិក្សាសមិទ្ធិលទ្ធភាព ឬការរៀបចំផែនការកម្មវិធីសាកល្បង |
| ភាពទូលំទូលាយ លទ្ធភាពធ្វើបកស្រាយថាជាការរកឃើញ (generalis-ability) ភាពអាចជឿទុកចិត្តបានផ្នែកស្ថិតិ | ការយល់ដឹងសម្បូរបែប + លំនាំទូទៅ |
| • ខ្វះភាពស៊ីជម្រៅ ឬបរិបទ<br>• មិនសូវមានប្រយោជន៍ក្នុងការឆ្លើយសំណួរ ហេតុអ្វី ?<br>• មិនសូវសមស្របសម្រាប់ប្រធានបទពាក់ព័ន្ធនឹងបរិបទជាក់លាក់ និងរសើប<br>• មិនសូវសមស្របសម្រាប់ប្រជាជនដែលមានកម្រិតអក្ខរកម្មទាប | ទាមទារពេលវេលា ធនធាន និងជំនាញច្រើនជាង |
| អាចទាមទារកម្មវិធីកុំព្យូទ័រ អ្នកប្រមូលទិន្នន័យ និងជំនាញផ្នែកស្ថិតិ | |

### ការធានាថាវិធីសាស្ត្រស្រាវជ្រាវរបស់អ្នកមានលក្ខណៈបរិយាបន្ន

ប្រើប្រាស់វិធីសាស្ត្រ ដែលសមស្របតាមវប្បធម៌ និងមានលក្ខណៈបរិយាបន្ន។ ពិចារណាប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបចូលរួមឱ្យបានកាន់តែច្រើន និងមានការចូលរួមពីក្រុមមនុស្សដែលត្រូវបានផាត់ចេញ ក្នុងការរៀបចំការស្រាវជ្រាវ និងការសាកល្បង។ ធានាឱ្យមានសំឡេងសម្បូរបែបក្នុងការប្រមូលទិន្នន័យជាពិសេសតាមរយៈការរួមបញ្ចូលសំឡេងពីក្រុមដែលត្រូវបានផាត់ចេញ ឬក្រុមដែលមិនសូវមានតំណាង។ ប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រប្រមូលទិន្នន័យ ដែលបង្កភាពងាយស្រួល ឬផ្តល់ផាសុកសមរម្យដល់អ្នកចូលរួម។

## ៣.៥ ការរៀបចំសំណាក

**ការជ្រើសរើសសំណាក គឺជាដំណើរការនៃការជ្រើសរើសក្រុមមនុស្ស ឬឯកតាមួយក្រុមពីស្ថិតិសកល (population) ដែលមានចំនួនច្រើន ដើម្បីចូលរួមក្នុងការសិក្សារបស់អ្នក។** ក្នុងការស្រាវជ្រាវបែបបរិមាណវិស័យ ទំហំសំណាកជាធម្មតាត្រូវបានកំណត់ដោយប្រើរូបមន្តស្ថិតិ ផ្អែកលើកម្រិតទំនុកចិត្តដែលចង់បាន កម្រិតគម្លាតនៃកំហុស (margin of error) ទំហំស្ថិតិសកល (population size) និងភាពប្រែប្រួលដែលរំពឹងទុក (expected variability)។ នៅពេលដែលសំណាកមានទំហំកាន់តែធំ គេកាន់តែអាចបកស្រាយការរកឃើញ ថាជារបកគំហើញទូទៅ សម្រាប់ស្ថិតិសកល។ ឧបករណ៍នានា ដូចជា កម្មវិធីគណនាទំហំសំណាក ជាដើម អាចជួយកំណត់ចំនួនអ្នកចូលរួមដែលត្រូវការ ដើម្បីទទួលបានលទ្ធផលត្រឹមត្រូវតាមបែបស្ថិតិ។ ក្នុងការស្រាវជ្រាវបែបគុណវិស័យ ការផ្តោតសំខាន់មិនមែនលើការបកស្រាយការរកឃើញថាជាការរកឃើញទូទៅសម្រាប់ស្ថិតិសកល (generali-zation) នោះទេ ប៉ុន្តែផ្តោតលើភាពស៊ីជម្រៅ និងភាពសំបូរបែបនៃព័ត៌មាន។ ការកំណត់ពីទំហំសំណាក ធ្វើឡើងផ្អែកតាមទស្សនទាននៃភាពឆ្អែត (concept of saturation) ពោលជាចំណុចមួយដែលការប្រមូលទិន្នន័យបន្ថែមលែងផ្តល់នូវការយល់ដឹង ឬអាចឱ្យយើងកំណត់ដឹងពីប្រធានបទថ្មីៗទៀតហើយ។ ចំនួនពិតប្រាកដនៃអ្នកចូលរួមដែលគេត្រូវការ អាចប្រែប្រួលអាស្រ័យលើវិសាលភាពនៃការសិក្សា វិធីសាស្ត្រ (ឧ. សម្ភាសន៍ ការពិភាក្សាក្រុមគោលដៅ) និងភាពចម្រុះនៃស្ថិតិសកល ប៉ុន្តែជារឿយៗ ការសិក្សាឈានដល់ចំណុចឆ្អែត ជាមួយនឹងសម្ភាសន៍ពី ១២ ទៅ ២០ នាក់ នៅក្នុងក្រុមប្រជាជនដែលមានលក្ខណៈដូចគ្នា។

## ការជ្រើសរើសសំណាកមានពីរប្រភេទធំៗ៖

**ការជ្រើសរើសសំណាកតាមបែបប្រូបាប៊ីលីតេ និងការជ្រើសរើសសំណាកតាមបែបមិនមែនប្រូបាប៊ីលីតេ។** ការជ្រើសរើសវិធីសាស្ត្រសំណាកដែលត្រឹមត្រូវគឺអាស្រ័យលើរចនាសម្ព័ន្ធនៃការសិក្សា គោលបំណង និងថាតើអ្នកមានបំណងធ្វើទាញលទ្ធផលទូទៅពីការរកឃើញ ឬស្វែងយល់ពីប្រធានបទណាមួយឱ្យកាន់តែស៊ីជម្រៅ។

នៅក្នុង**ការជ្រើសរើសសំណាកតាមបែបប្រូបាប៊ីលីតេ** សមាជិកម្នាក់ៗនៃស្ថិតិសកលមានឱកាសដែលបានដឹងជាមុន ក្នុងការត្រូវបានជ្រើសរើស។ វិធីសាស្ត្រនេះ រួមមានដូចជា ការជ្រើសរើសសំណាកដោយចៃដន្យ (random sampling) ឬការជ្រើសរើសសំណាកតាមស្រទាប់ (stratified sampling) ហើយជារឿយៗ ត្រូវបានប្រើប្រាស់ក្នុងការស្ទង់មតិ។

នៅក្នុង**ការជ្រើសរើសសំណាកតាមបែបមិនមែនប្រូបាប៊ីលីតេ** ការជ្រើសរើសគឺផ្អែកលើលក្ខណៈវិនិច្ឆ័យជាក់លាក់ ដូចជា ភាពងាយស្រួល ការជ្រើសរើសសំណាកបន្តគ្នា (snowballing) ឬការជ្រើសរើសសំណាកតាមគោលបំណង (purposeful sampling)។ នេះជាវិធីសាស្ត្រ ដែលគេប្រើប្រាស់ជាធម្មតានៅក្នុងការស្រាវជ្រាវបែបគុណវិស័យ ដើម្បីទទួលបានការយល់ដឹងស៊ីជម្រៅពីមនុស្សដែលមានបទពិសោធពាក់ព័ន្ធ។

## ការធានាថាការជ្រើសរើសសំណាកមានលក្ខណៈបរិយាបន្ន

រចនាសម្ព័ន្ធនៃការជ្រើសរើសសំណាករបស់អ្នក គួរគិតគូរជាមុន ដើម្បីបញ្ចូលបុគ្គលពីក្រុមដែលមិនសូវមានតំណាង មិនថាអ្នកប្រើប្រាស់វិធីសាស្ត្រណានោះឡើយ។ នៅក្នុងការស្ទង់មតិ ការជ្រើសរើសសំណាកដែលកាន់តែមានលក្ខណៈបរិយាបន្ន ធ្វើឱ្យការរកឃើញកាន់តែមានភាពពាក់ព័ន្ធ។ នៅក្នុងការសម្ភាសន៍ និងការពិភាក្សាក្រុមគោលដៅ ការចូលរួមដែលកាន់តែមានលក្ខណៈបរិយាបន្ន ផ្តល់នូវការយល់ដឹងកាន់តែសំបូរបែបអំពីបទពិសោធរបស់ក្រុមចម្រុះ។ ការធ្វើការជាមួយដៃគូក្នុងមូលដ្ឋាន ការកំណត់គោលដៅនៃភាពចម្រុះ និងការប្រើប្រាស់វិធីសាស្ត្រផ្សព្វផ្សាយព័ត៌មានចម្រុះ អាចជួយពង្រីកការចូលរួមបាន។ ចំណុចសំខាន់ផងដែរនោះ គឺតាមដានអ្នកដែលត្រូវបានបញ្ចូល ក្នុងអំឡុងពេលប្រមូលទិន្នន័យ និងធ្វើការកែសម្រួលតាមការចាំបាច់ ដើម្បីធានាឱ្យមានភាពជាតំណាងដ៏ទូលំទូលាយ។



# ៤. ក្រមសីលធម៌សម្រាប់ការស្រាវជ្រាវ

ក្រមសីលធម៌សម្រាប់ការស្រាវជ្រាវ សំដៅលើគោលការណ៍ និងស្តង់ដារដែលធានាថាការស្រាវជ្រាវត្រូវបានធ្វើឡើងប្រកបដោយការទទួលខុសត្រូវ គណនេយ្យភាព និងតម្លាភាព។ ក្រមសីលធម៌សម្រាប់ការស្រាវជ្រាវជួយធានាឱ្យមានការការពារអ្នកចូលរួមក្នុងការស្រាវជ្រាវ កសាងទំនុកចិត្ត និងបង្កើនភាពគួរឱ្យជឿជាក់នៃការរកឃើញ។

## ៤.១ គោលការណ៍ណែនាំសម្រាប់ការស្រាវជ្រាវប្រកបដោយក្រមសីលធម៌

**១ ការគោរពចំពោះមនុស្ស**

- លើកស្ទួយសេចក្តីថ្លៃថ្នូរ គុណតម្លៃវប្បធម៌ និងការប្រកាន់ជំនឿរបស់អ្នកចូលរួមក្នុងការស្រាវជ្រាវ និងសហគមន៍។
- ផ្តល់អាទិភាពលើការយល់ព្រមដោយសេរី បន្ទាប់ពីបានទទួលព័ត៌មានសព្វគ្រប់។

**២ គោលការណ៍បដិការ និងការផ្តល់ផលប្រយោជន៍**

- ការស្រាវជ្រាវគួរផ្តល់អត្ថប្រយោជន៍ជាក់ស្តែង និងអរូបីដល់អ្នកចូលរួម និងសហគមន៍។
- ធានាថាសហគមន៍មិនត្រឹមតែជាកម្មវត្ថុនៃការស្រាវជ្រាវប៉ុណ្ណោះទេ ប៉ុន្តែជាអ្នកចូលរួមយ៉ាងសកម្ម និងជាអ្នករួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវផងដែរ។
- បញ្ចូលយន្តការផ្តល់មតិត្រឡប់ជាប្រចាំ និងដំណើរការដែលមានរចនាសម្ព័ន្ធច្បាស់លាស់ សម្រាប់ការបញ្ជូនចំណេះដឹងត្រឡប់ទៅវិញ ដើម្បីធានាបាននូវគណនេយ្យភាព និងតម្លាភាព (៦. ការចែករំលែកលទ្ធផលស្រាវជ្រាវជាភាសាក្នុងស្រុកជាមួយសហគមន៍គោលដៅ)។



### ៣ បរិបទ និងការយល់ដឹងអំពីអំណាច

- ឆ្លុះបញ្ចាំងអំពីអត្តសញ្ញាណ ឯកសិទ្ធិ និងអំណាចពាក់ព័ន្ធរបស់ក្រុមស្រាវជ្រាវ នៅក្នុងដំណើរការស្រាវជ្រាវ ជាពិសេសនៅពេលធ្វើការជាមួយប្រជាជនដែលទទួលសេវាមិនគ្រប់គ្រាន់តាំងពីដើមរៀងមក។
- ត្រូវមានតម្លាភាពអំពីថវិកា គោលបំណង និងហានិភ័យដែលអាចកើតមាន ជាមួយអ្នកចូលរួមក្នុងការស្រាវជ្រាវ និងសហគមន៍។

### ៤ មិនបង្កគ្រោះថ្នាក់ និងលើកកម្ពស់យុត្តិធម៌

- កាត់បន្ថយហានិភ័យឱ្យនៅតិចបំផុត និងជៀសវាងការកេងប្រវ័ញ្ច ការធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តឡើងវិញ ឬការប្រមាថផ្នែកវប្បធម៌។
- ពិចារណាលើភាពអយុត្តិធម៌ដែលមានកន្លងមក ជាពិសេសភាពអយុត្តិធម៌ទាំងឡាយដែលទាក់ទងនឹងអត្តសញ្ញាណយេនឌ័រ ជាតិពន្ធុ សិទ្ធិដីធ្លី និងជម្លោះ។
- ទទួលស្គាល់ភាពងាយរងគ្រោះដែលត្រួតស៊ីគ្នា ឬអន្តរប្រសព្វ។

### ៥ អធិបតេយ្យភាពទិន្នន័យ (data sovereignty) និងការអនុវត្តទិន្នន័យប្រកបដោយក្រមសីលធម៌

- គោរពសិទ្ធិរបស់អ្នកចូលរួម និងសហគមន៍ ជុំវិញរបៀបដែលទិន្នន័យរបស់ពួកគេត្រូវបានប្រមូល ប្រើប្រាស់ និងរក្សាទុក។
- ការពារឯកជនភាព ភាពអនាមិក និងការសម្ងាត់។
- ប្រើប្រាស់ទិន្នន័យប្រកបដោយការទទួលខុសត្រូវ ដើម្បីបង្កើនអត្ថប្រយោជន៍ឱ្យបានជាអតិបរមា និងកាត់បន្ថយគ្រោះថ្នាក់ដែលអាចកើតមានឱ្យនៅកម្រិតអប្បបរមា។

## គន្លឹះសម្រាប់ការធ្វើការវាយតម្លៃហានិភ័យ

- កំណត់អំពីហានិភ័យផ្លូវកាយ ផ្លូវចិត្ត និងសង្គម ចំពោះអ្នកចូលរួមក្នុងការស្រាវជ្រាវ សហគមន៍របស់ពួកគេ អ្នកស្រាវជ្រាវ និងស្ថាប័នដែលធ្វើការស្រាវជ្រាវ។
- យកចិត្តទុកដាក់ជាពិសេសចំពោះក្រុមដែលងាយរងគ្រោះ ឬក្រុមប្រឈមនឹងហានិភ័យ ដូចជា បុគ្គលដែលមានប្រាក់ចំណូលទាប ជនភៀសខ្លួន ឬអ្នករស់រានមានជីវិត (ពីគ្រោះមហន្តរាយ ឬអំពើហិង្សាជាដើម)។
- វាយតម្លៃហានិភ័យ ក្នុងអំឡុងពេលដំណើរការស្រាវជ្រាវ និងហានិភ័យដែលអាចកើតឡើងជាលទ្ធផលនៃការស្រាវជ្រាវ។
- អញ្ជើញឱ្យមានការចូលរួមពីដៃគូក្នុងស្រុក និងប្រជាជនពីក្រុមគោលដៅ ដើម្បីជួយកំណត់អំពីហានិភ័យដែលអាចកើតមាន។
- រៀបចំយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យឱ្យបានច្បាស់លាស់ និងចងក្រងជាឯកសារ សម្រាប់ហានិភ័យនីមួយៗដែលបានកំណត់។
- ធ្វើបច្ចុប្បន្នភាពការវាយតម្លៃហានិភ័យពេញមួយដំណើរការស្រាវជ្រាវ។

## ឯកសារយោង


- ឧបករណ៍វាយតម្លៃហានិភ័យរបស់ DFAT៖ https://www.dfat.gov.au/sites/default/files/ethical-research-evaluation-guidance-note.pdf
- សំណួរដែលសួរញឹកញាប់របស់មូលនិធិវិទ្យាសាស្ត្រជាតិអាមេរិកស្ដីពីការស្រាវជ្រាវដែលពាក់ព័ន្ធនឹងមនុស្ស៖ https://www.nsf.gov/funding/faq/research-involving-human-subjects

# ៤.២ ការធ្វើការវាយតម្លៃហានិភ័យ

នៅពេលធ្វើការស្រាវជ្រាវដែលពាក់ព័ន្ធនឹងមនុស្ស ការវាយតម្លៃហានិភ័យ គឺជារឿងចាំបាច់ ដើម្បីការពារអ្នកចូលរួមពីគ្រោះថ្នាក់ និងធានាថាការស្រាវជ្រាវប្រព្រឹត្តទៅប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវ។ ការវាយតម្លៃហានិភ័យ ជួយអ្នកស្រាវជ្រាវក្នុងការកំណត់អំពីហានិភ័យដែលអាចកើតមាន និងចាត់វិធានការ ដើម្បីកាត់បន្ថយហានិភ័យទាំងនោះឱ្យនៅតិចបំផុត មុនពេលការប្រមូលទិន្នន័យចាប់ផ្តើម។ ការវាយតម្លៃហានិភ័យដែលល្អមួយក៏ត្រូវគិតគូរពីសុវត្ថិភាពរបស់អ្នកស្រាវជ្រាវ និងរបៀបដែលលទ្ធផលស្រាវជ្រាវអាចជះឥទ្ធិពលដល់បុគ្គល ឬសហគមន៍ បន្ទាប់ពីការសិក្សាបានបញ្ចប់ផងដែរ។ ការវាយតម្លៃនេះគួរតែត្រូវបានធ្វើឡើងនៅដំណាក់កាលដំបូងនៃការរៀបចំផែនការ ចងក្រងជាឯកសារឱ្យបានច្បាស់លាស់ និងពិនិត្យឡើងវិញជាប្រចាំ ក្នុងអំឡុងពេលគម្រោង ដ្បិតស្ថានភាពអាចមានការប្រែប្រួល។

# ៤.៣ ការរៀបចំផែនការគ្រប់គ្រងទិន្នន័យ

ផែនការគ្រប់គ្រងទិន្នន័យ (DMP) គឺជាឯកសារដែលរៀបរាប់អំពីរបៀបដែលទិន្នន័យស្រាវជ្រាវនឹងត្រូវបានប្រមូល រក្សាទុក ការពារ ចែករំលែក និងថែរក្សាទុក ទាំងក្នុងអំឡុងពេល និងក្រោយពេលគម្រោងស្រាវជ្រាវត្រូវបានបញ្ចប់។ នៅពេលធ្វើការស្រាវជ្រាវដែលពាក់ព័ន្ធនឹងមនុស្ស និងប្រមូលព័ត៌មានផ្ទាល់ខ្លួននិង/ឬព័ត៌មានរសើប ផែនការគ្រប់គ្រងទិន្នន័យគឺជាធាតុផ្សំដ៏សំខាន់មួយ ដើម្បីធានាថា អ្នកស្រាវជ្រាវការពារទិន្នន័យរបស់អ្នកចូលរួមបានយ៉ាងត្រឹមត្រូវ។ ព័ត៌មានផ្ទាល់ខ្លួនសំដៅលើទិន្នន័យណាមួយដែលអាចកំណត់អត្តសញ្ញាណបុគ្គលម្នាក់ដោយផ្ទាល់ ឬនៅពេលផ្សំជាមួយទិន្នន័យផ្សេងទៀត ដូចជា ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណ រូបថត ព័ត៌មានទំនាក់ទំនង ឬអត្តសញ្ញាណអនឡាញ។ ព័ត៌មានផ្ទាល់ខ្លួនរសើបគឺជាប្រភេទជាក់លាក់នៃទិន្នន័យផ្ទាល់ខ្លួន ដែលបញ្ចូលព័ត៌មានដែលមានលក្ខណៈឯកជនជាង និងអាចបង្កគ្រោះថ្នាក់ ប្រសិនបើត្រូវបានប្រើប្រាស់ខុស ដូចជា ឯកសារសុខភាព ទិន្នន័យជីវមាត្រឬហិរញ្ញវត្ថុ ជំនឿ នយោបាយ ឬសាសនា ទំនោរផ្លូវភេទ និងព័ត៌មានអំពី អនីតិជនជាដើម។

ការរៀបចំ DMP នៅពេលចាប់ផ្តើមការសិក្សា ជួយធានាថា ទិន្នន័យមានការរៀបចំបានល្អ មានសុវត្ថិភាព គ្រប់គ្រងប្រកបដោយក្រមសីលធម៌ និងងាយស្រួលប្រើប្រាស់ នាពេលអនាគត។ វាក៏ជួយកាត់បន្ថយហានិភ័យនៃការបាត់បង់ ឬការប្រើប្រាស់ទិន្នន័យខុស និងធ្វើឱ្យកាន់តែងាយស្រួលក្នុងការបំពេញតាមតម្រូវការរបស់អ្នកផ្តល់មូលនិធិ ស្ថាប័ន និងលក្ខខណ្ឌតម្រូវផ្នែកច្បាប់។ DMP ដែលរឹងមាំមួយជួយគាំទ្រដល់ការបង្កើនតម្លាភាព គណនេយ្យភាព និងតម្លៃរយៈពេលវែងនៃការស្រាវជ្រាវ ជាពិសេស នៅពេលធ្វើការជាមួយទិន្នន័យរសើប ឬទិន្នន័យផ្ទាល់ខ្លួន។

## គន្លឹះសម្រាប់ការរៀបចំផែនការគ្រប់គ្រងទិន្នន័យ (DMP)

- ចាប់ផ្ដើមឱ្យបានឆាប់ មុនពេលការប្រមូលទិន្នន័យចាប់ផ្ដើម។
- រាយបញ្ជីទិន្នន័យទាំងអស់ដែលអ្នកគ្រោងនឹងប្រមូល និងទម្រង់របស់វា។ ឧទាហរណ៍ ប្រសិនបើអ្នកគ្រោងធ្វើសម្ភាសន៍ អ្នកអាចនឹងមានកំណត់ត្រាលើក្រដាសពីកិច្ចសម្ភាសន៍ ការថតសំឡេងបែបឌីជីថល ការធ្វើប្រតិចារិក (transcriptions) នៅពេលក្រោយ និងក្របខ័ណ្ឌវិភាគមួយ។
- សម្រេចចិត្តលើរបៀបរក្សាទុក និងរៀបចំទិន្នន័យ រួមទាំងគោលការណ៍នៃការដាក់ឈ្មោះឯកសារ រចនាសម្ព័ន្ធនៃសំណុំឯកសារ និងដំណើរការត្រួតពិនិត្យលើកំណែឯកសារ។
- រៀបចំផែនការសម្រាប់ការរក្សាទុកទិន្នន័យប្រកបដោយសុវត្ថិភាព ជាពិសេស ទិន្នន័យផ្ទាល់ខ្លួន ឬទិន្នន័យរសើប។
- ពិចារណាឱ្យបានដិតដល់អំពីដំណើរការចែករំលែកទិន្នន័យ និងការការពារ ជាពិសេស នៅពេលរៀបចំផែនការចែករំលែកជាមួយអ្នកស្រាវជ្រាវផ្សេងទៀត រដ្ឋាភិបាល និងស្ថាប័នផ្សេងៗ។
- សម្រេចចិត្តថានឹងធ្វើអ្វីជាមួយទិន្នន័យ បន្ទាប់ពីការបោះពុម្ពផ្សាយ។ រៀបចំផែនការ ដើម្បីដកអត្តសញ្ញាណពីទិន្នន័យដើម។
- ត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនការជាប្រចាំ។

## ឯកសារយោង


- ការរៀបចំផែនការគ្រប់គ្រងទិន្នន័យស្រាវជ្រាវរបស់សាកលវិទ្យាល័យជាតិអូស្ត្រាលី៖ https://libguides.anu.edu.au/c. php?g=881167&p=6340655
- មគ្គុទេសក៍ DMP របស់ Australia Research Data Commons (ARDC)៖ https://ardc.edu.au/resource/data-management-plans/
- ការពន្យល់អំពី DMP របស់សាកលវិទ្យាល័យ Harvard៖ https://datamanagement.hms. harvard.edu/plan-design/data-management-plans
- មគ្គុទេសក៍ និងគំរូ DMP របស់វិទ្យាស្ថាន MIT៖ https://libraries.mit.edu/data-management/plan/write/

# ៤.៤ ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ (INFORMED CONSENT)

ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ គឺជាដំណើរការដែលមនុស្សយល់ព្រមចូលរួមក្នុងការស្រាវជ្រាវដោយស្ម័គ្រចិត្តបន្ទាប់ពីត្រូវបានផ្តល់ព័ត៌មានយ៉ាងពេញលេញអំពីគោលបំណង នីតិវិធី ហានិភ័យ អត្ថប្រយោជន៍ និងសិទ្ធិរបស់ពួកគេ រួមទាំងសិទ្ធិក្នុងការដកខ្លួនចេញពីសកម្មភាពនោះ។ ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ គឺជាលក្ខខណ្ឌតម្រូវផ្នែកក្រមសីលធម៌ជាមូលដ្ឋាន នៅពេលណាដែលអ្នកស្រាវជ្រាវប្រមូលទិន្នន័យផ្ទាល់ខ្លួន ឬទិន្នន័យរសើប (រួមទាំងរឿងរ៉ាវ និងរូបថត)។ **ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ គឺជា៖**

- ការបង្ហាញបំណងប្រាថ្នាដោយស្ម័គ្រចិត្ត ផ្តល់ឱ្យដោយសេរី ជាក់លាក់ ផ្អែកលើព័ត៌មាន និងមិនស្រពិចស្រពិល (មិនមែនជាលក្ខខណ្ឌតម្រូវសម្រាប់ការទទួលបានសិទ្ធិ ឬអត្ថប្រយោជន៍ទេ)។
- បង្ហាញតាមរយៈសេចក្តីថ្លែងការណ៍ ឬសកម្មភាពបញ្ជាក់ច្បាស់លាស់ដែលបង្ហាញពីការយល់ព្រម។
- ជាការជ្រើសរើសចូលរួម (Opt-in) មិនមែនជាការជ្រើសរើសមិនចូលរួម (Opt-out) ទេ។
- ជាការយល់ព្រមដោយសកម្ម មិនមែនជាការយល់ព្រមដោយអសកម្មទេ។
- ពន្យល់ដោយប្រើភាសាសាមញ្ញ ងាយយល់ ដើម្បីធានាបាននូវតម្លាភាព និងការយល់ដឹង។
- ជាការសន្ទនា និងជាដំណើរការ មិនមែនគ្រាន់តែជាការគូសសញ្ញាតែម្តងទេ។
- អាចដកហូតវិញបាន (អាចដកខ្លួនចេញ) ដោយគ្មានការពិន័យ។
- ត្រូវបានចងក្រងជាឯកសារ និងរក្សាទុកដោយសុវត្ថិភាព។

# ដំណើរការនៃការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់

**១**

កំណត់ថាគេនឹងយកទិន្នន័យទៅធ្វើអ្វីខ្លះ ពេញមួយវដ្តជីវិតរបស់វា។ បញ្ជាក់អំពីភាពចាំបាច់នៃទិន្នន័យផ្ទាល់ខ្លួន និងទិន្នន័យរសើបនីមួយៗ ដែលអ្នកគ្រោងនឹងប្រមូល (រួមទាំង មធ្យោបាយទុកដាក់ទិន្នន័យទាំងនោះ)។

**២**

ពិចារណាថាតើបរិបទសង្គម សេដ្ឋកិច្ច ប្រវត្តិសាស្ត្រ និងវប្បធម៌ នឹងជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះលើភាពចាំបាច់ក្នុងការទទួលបានការយល់ព្រមបន្ទាប់ពីជនជ្រាបព័ត៌មានសព្វគ្រប់និងកែសម្រួលទៅតាមនោះ។

**៣**

រៀបចំភាសា និងពិធីសារនៃការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់របស់អ្នកតាមរបៀបដែលបុគ្គលជាម្ចាស់ទិន្នន័យអាចយល់បាន និងមានស្វ័យភាពក្នុងការសម្រេចចិត្ត។

**៤**

ត្រូវគិតគូរពីករណីពិសេសណាមួយ ដូចជា ទិន្នន័យដែលបានពីអនីតិជន ឬក្រុមផ្សេងទៀតដែលមិនមានសមត្ថភាពពេញលេញក្នុងការយល់ព្រមដោយសេរី។

**៥**

ប្រសិនបើធ្វើការជាមួយអ្នកចុះប្រមូលទិន្នន័យ ត្រូវបណ្តុះបណ្តាលពួកគេអំពីរបៀបសុំការយល់ព្រមឱ្យបានសមស្របតាមវប្បធម៌។

**៦**

ប្រសិនបើធ្វើការតាមរយៈកម្មវិធី (app) ឬវេទិកាបច្ចេកវិទ្យា (platform) ត្រូវរៀបចំលក្ខខណ្ឌ និងភាសាដែលពន្យល់ពីគោលការណ៍ឯកជនភាពឱ្យបានច្បាស់លាស់។

**៧**

បង្កើតដំណើរការសម្រាប់ចងក្រងជាឯកសារ និងរក្សាទុកការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ ដើម្បីឱ្យអ្នកអាចបំពេញសិទ្ធិរបស់ម្ចាស់ទិន្នន័យបាន។

**៨**

បង្កើតយន្តការដោះស្រាយបណ្តឹង ដើម្បីធានាថាអ្នកចូលរួមក្នុងការស្រាវជ្រាវដឹងថាត្រូវទាក់ទងអ្នកណាប្រសិនបើពួកគេមានសំណួរ ឬចង់ដូរការយល់ព្រមវិញ ឬចង់ប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងនាមជាម្ចាស់ទិន្នន័យ។

## អ្វីដែលត្រូវបញ្ចូលក្នុងពិធីសារស្តីពីការយល់ព្រមបន្ទាប់ពីទទួលបានព័ត៌មានសព្វគ្រប់

- តើទិន្នន័យ ឬព័ត៌មានអ្វីខ្លះដែលកំពុងត្រូវបានប្រមូល?
- តើអ្នកណាកំពុងប្រមូលទិន្នន័យនេះ?
- តើទិន្នន័យនេះត្រូវបានប្រមូលដោយរបៀបណា?
- ហេតុអ្វីបានជាគេប្រមូលទិន្នន័យនេះ?
- តើអ្នកណានឹងដំណើរការទិន្នន័យនេះ ហើយដោយរបៀបណា? (តើអ្នកនឹងប្រើប្រាស់ភាគីទីបី ឬកម្មវិធីកុំព្យូទ័រដែរឬទេ?)
- តើទិន្នន័យនេះនឹងត្រូវបានប្រើប្រាស់ដោយរបៀបណា?
- តើទិន្នន័យនេះនឹងត្រូវបានចែករំលែកជាមួយអ្នកណាខ្លះ? (រួមទាំងអ្នកដំណើរការទិន្នន័យ ជាភាគីទីបី)
- តើទិន្នន័យផ្ទាល់ខ្លួន ឬទិន្នន័យរសើបនឹងត្រូវបានរក្សាទុករយៈពេលប៉ុន្មាន?
- តើមានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះដែលអាចកើតមានចំពោះបុគ្គលពាក់ព័ន្ធ?
- តើការប្រើប្រាស់ដែលបានគ្រោងទុក ទំនងជាធ្វើឱ្យបុគ្គលទាំងនោះជំទាស់ឬតវ៉ាដែរឬទេ?
- តើបុគ្គល ឬសហគមន៍មានសិទ្ធិអ្វីខ្លះ ពាក់ព័ន្ធនឹងទិន្នន័យរបស់ពួកគេក៏ដូចជានឹងការអនុវត្ត ឬគំនិតផ្តួចផ្តើមនេះ?
- តើមនុស្សម្នាក់អាចដកការយល់ព្រមរបស់ពួកគេវិញដោយរបៀបណា? តើពួកគេត្រូវទាក់ទងអ្នកណាដើម្បីទទួលបានព័ត៌មានបន្ថែម?
- ប្រសិនបើធ្វើការជាមួយកុមារ តើយើងមានទម្រង់សម្រាប់ទទួលបានការយល់ព្រមពីមនុស្សពេញវ័យ និងការយល់ព្រមពីកុមារដែរឬទេ? តើទម្រង់នោះងាយស្រួលសម្រាប់កុមារយល់ដែរឬទេ?

## ការទទួលបានការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ពីកុមារ

អនុលោមតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ កម្មវិធីពន្លកចំណេះចាត់ទុកមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ គឺជាកុមារ។ បទប្បញ្ញត្តិស្តីពីការការពារទិន្នន័យ ចាត់ថ្នាក់ទិន្នន័យរបស់កុមារជាទិន្នន័យរសើប ដែលទាមទារឱ្យមានការការពារកាន់តែខ្ពស់។ នេះរួមបញ្ចូលទាំងព័ត៌មានផ្ទាល់ខ្លួនរបស់កុមារ រូបភាពរបស់ពួកគេ វីដេអូរបស់កុមារ និងការថតសំឡេងដែលអាចកំណត់អត្តសញ្ញាណកុមារបាន។ ត្រូវសុំការយល់ព្រមដែលត្រូវបានបញ្ជាក់ជាឯកសារ ដែលពន្យល់យ៉ាងច្បាស់អំពីគោលបំណង វិសាលភាព និងការប្រើប្រាស់ទិន្នន័យ **ពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់**។ ក្នុងករណីដែលអាចធ្វើទៅបាន កុមារក៏គួរតែផ្តល់**ការយល់ព្រមដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ** ដោយប្រើភាសាសមស្របតាមវ័យរបស់ពួកគេ។ នៅពេលប្រមូលទិន្នន័យជារូបភាព ឬសំឡេង ត្រូវបញ្ជាក់ឱ្យបានច្បាស់ពីគោលបំណងនៃការថតរូបភាព ឬសំឡេងនោះ។ ត្រូវធានាថាសេចក្តីថ្លៃថ្នូររបស់កុមារត្រូវបានគោរពនៅក្នុងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ដោយជៀសវាងការបង្ហាញរូបភាពណាមួយដែលអាចបង្កគ្រោះថ្នាក់ ឬធ្វើឱ្យពួកគេរងការរើសអើង។

---

## ការពិចារណាពិសេសសម្រាប់ការសុំការយល់ព្រម

នៅពេលធ្វើការជាមួយក្រុមមនុស្សដែលងាយរងគ្រោះជាពិសេស ការរក្សាការសម្ងាត់គឺជារឿងសំខាន់បំផុត ហើយដំណើរការនៃការសុំការយល់ព្រម ត្រូវផ្តោតជាសំខាន់លើការយល់ដឹង និងសិទ្ធិសម្រេចចិត្តរបស់ម្ចាស់ទិន្នន័យ។ ក្នុងគ្រប់ករណីទាំងអស់ ភាពរសើបផ្នែកវប្បធម៌គឺជាទិដ្ឋភាពដ៏សំខាន់មួយនៃការកសាងទំនុកចិត្ត និងទំនាក់ទំនងល្អជាមួយមនុស្ស មុនពេល អំឡុងពេល និងក្រោយពេលដំណើរការប្រមូលទិន្នន័យ។ ក្នុងគ្រប់ករណីទាំងអស់ គួរមានការផ្តោតការយកចិត្តទុកដាក់លើការប្រាស្រ័យទាក់ទងច្បាស់លាស់ ការគោរពស្វ័យភាព និងការប្រើប្រាស់នីតិវិធីសុំការយល់ព្រម ដែលសមស្របតាមវប្បធម៌។

## ការធ្វើការជាមួយជនមានពិការភាព

នៅក្នុងបញ្ជីអ្នកតបសម្ភាសន៍របស់អ្នក អាចមានបុគ្គលដែលមានពិការភាព ដែលត្រូវការជំនួយ ដើម្បីអាចចូលរួមក្នុងការស្ទង់មតិ។ នៅពេលប្រមូលទិន្នន័យពីជនមានពិការភាព អ្នកស្រាវជ្រាវត្រូវតែចាត់វិធានការបន្ថែមដើម្បីធានាថាម្ចាស់ទិន្នន័យអាចចូលមើល និងយល់អំពីនីតិវិធី សម្រាប់ផ្តល់ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់។ ការបង្កើនភាពងាយស្រួលយល់ អាចបញ្ចូលទាំងការពន្យល់ដោយផ្ទាល់មាត់អំពីដំណើរការផ្តល់ការយល់ព្រមដល់អ្នកដែលខ្សោយគំហើញ និងការផ្តល់ទម្រង់យល់ព្រមជាអក្សរប្រៃយ៍ (Braille) ឬការសម្រួលភាសាក្នុងទម្រង់ផ្តល់ការយល់ព្រម ដើម្បីធានាថាអ្នកដែលមានពិការភាពពិបាករៀនសូត្រ អាចយល់ពីអ្វីដែលពួកគេត្រូវធ្វើពេលចូលរួមក្នុងសម្ភាសន៍។ នៅពេលធ្វើការជាមួយអ្នកចូលរួមដែលមានពិការភាព ឬមិនចេះអក្សរ ត្រូវមានការកែសម្រួលទម្រង់ផ្តល់ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ ដើម្បីធានាឱ្យពួកគេយល់មានស្វ័យភាព និងអាចចូលរួមដោយស្ម័គ្រចិត្ត។

- ប្រើប្រាស់អក្សរប្រៃយ៍ អក្សរពុម្ពធំៗ ទម្រង់ជាសំឡេង ឬទម្រង់ដែលងាយស្រួលសម្រាប់កម្មវិធីអានអេក្រង់ សម្រាប់អ្នកចូលរួមដែលខ្សោយគំហើញ។
- ផ្តល់អ្នកបកប្រែភាសាសញ្ញា ឬប្រតិចារិកភ្លាមៗ (real-time transcription) សម្រាប់អ្នកដែលខ្សោយខាងការស្តាប់។
- ប្រើប្រាស់ឯកសារដែលងាយស្រួលអាន (Easy Read) ដែលមានរូបភាព និងភាសាសាមញ្ញ សម្រាប់អ្នកដែលមានពិការភាពផ្នែកបញ្ញា ឬអ្នកដែលពិបាករៀនសូត្រ។
- ជានិច្ចកាល ត្រូវផ្ទៀងផ្ទាត់ថាតើពួកគេយល់ដែរឬទេ និងទុកពេលឱ្យសួរសំណួរ និងឆ្លុះបញ្ចាំង។

## ការធ្វើការជាមួយអ្នកចូលរួមដែលមិនចេះអក្សរ ឬមានកម្រិតអក្ខរកម្មទាប

នៅពេលធ្វើការជាមួយប្រជាជនដែលមិនចេះអក្សរ អ្នកស្រាវជ្រាវអាចត្រូវការរៀបចំការពន្យល់អំពីការយល់ព្រម ដោយផ្ទាល់មាត់ ដូចជាឱ្យអ្នកចុះប្រមូលទិន្នន័យអានទម្រង់ផ្តល់ការយល់ព្រមឱ្យពួកគេស្តាប់ ឬថតជាសំឡេងទុក និងចាក់ឱ្យស្តាប់ មុនពេលសម្ភាសន៍។ ក្នុងករណីទាំងនេះ ត្រូវមានការថតសំឡេង និងចងក្រងជាឯកសារនូវការយល់ព្រមដោយផ្ទាល់មាត់បែបនេះ។

- អានទម្រង់យល់ព្រមឱ្យឮៗជាភាសាក្នុងស្រុករបស់អ្នកចូលរួម ដោយប្រើប្រាស់ពាក្យពេចន៍សាមញ្ញ និងច្បាស់លាស់។
- ប្រើប្រាស់សម្ភារជំនួយក្នុងទម្រង់ជារូបភាព (ឧ. ដ្យាក្រាម ទម្រង់រូបភាព) ដើម្បីពន្យល់អំពីការសិក្សា។
- ទទួលបានការយល់ព្រមដោយផ្ទាល់មាត់ ឬសុំឱ្យផ្តិតស្នាមមេដៃ ជាមួយវត្តមានសាក្សីអព្យាក្រឹត ដើម្បីបញ្ជាក់ថាអ្នកតបសម្ភាសន៍
- ពិតជាយល់ខ្លឹមសារនៃទម្រង់យល់ព្រមប្រាកដមែន។
- ប្រើប្រាស់វិធីសាស្ត្របង្រៀនត្រឡប់ (teach-back) ដើម្បីធានាថាអ្នកចូលរួមអាចពន្យល់អំពីការសិក្សានេះ ដោយប្រើប្រាស់ពាក្យពេចន៍ផ្ទាល់ខ្លួន។

---

## ការធ្វើការជាមួយអ្នកដែលធ្លាប់ទទួលរងការប៉ះទង្គិចផ្លូវចិត្ត

នៅពេលធ្វើការជាមួយអ្នកដែលធ្លាប់ទទួលរងនូវការប៉ះទង្គិចផ្លូវចិត្តក្នុងរូបភាពណាមួយ ឬអ្នកដែលកំពុងប្រឈមនឹងហានិភ័យនៃការធ្វើទុក្ខបុកម្នេញ ឬគ្រោះថ្នាក់ប្រភេទផ្សេងទៀតដោយសារអត្តសញ្ញាណ ឬឋានៈរបស់ពួកគេនៅក្នុងសង្គម ឬដោយសារបរិបទដែលពួកគេកំពុងរស់នៅ វិធីសាស្ត្រ ផ្អែកលើព័ត៌មានអំពីការប៉ះទង្គិចផ្លូវចិត្ត គឺជាវិធីសាស្ត្រដ៏សំខាន់។

- បង្កើតបរិយាកាសដែលមានសុវត្ថិភាព និងផ្តល់ការគាំទ្រ (ឧ. ទីកន្លែងឯកជន ស្ងប់ស្ងាត់ និងមានផាសុកភាព)
- ត្រៀមខ្លួនសម្រាប់ប្រតិកម្មផ្នែកអារម្មណ៍ដែលអាចកើតមាន
- ត្រៀមព័ត៌មានសម្រាប់បញ្ជូនបន្តទៅកាន់សេវាសុខភាពផ្លូវចិត្ត ឬសេវាគាំទ្រពាក់ព័ន្ធផ្សេងៗ
- កាត់បន្ថយអតុល្យភាពនៃអំណាច (ឧ. អង្គុយនៅក្បែរអ្នកចូលរួមក្នុងកម្រិតស្មើគ្នា)
- អនុញ្ញាតឱ្យអ្នកចូលរួមមានជំនួយការនៅជាមួយ ក្នុងពេលសម្ភាសន៍/ឆ្លើយសំណួរស្ទង់មតិ
- កុំដាក់សម្ពាធ ឬបញ្ចុះបញ្ចូល ជៀសវាងការនិយាយពាក្យពេចន៍ដូចជា «រឿងរ៉ាវរបស់អ្នកមានសារៈសំខាន់ណាស់» ឬ «ការណ៍នេះនឹងជួយដល់អ្នកដទៃ»។

## ឯកសារយោង

- បញ្ជីត្រួតពិនិត្យនិងគំរូនៃការយល់ព្រមក្រោយទទួលព័ត៌មានសព្វគ្រប់របស់អង្គការមូលនិធិអាស៊ី (ឧសម្ព័ន្ធ E-H)
- មគ្គុទេសក៍និងឧបករណ៍របស់មហាវិទ្យាល័យ Sawthmore សម្រាប់ការរៀបចំការយល់ព្រមក្រោយទទួលព័ត៌មានសព្វគ្រប់ https://www.swarthmore.edu/institutional-review-board/guides-and-templates
- គំរូនៃការយល់ព្រមក្រោយទទួលព័ត៌មានសព្វគ្រប់ របស់សាកលវិទ្យាល័យ Virginia https://research.virginia.edu/irb-sbs/consent-templates

---

## ការស្រាវជ្រាវគិតគូរពីយេនឌ័រ

ការស្រាវជ្រាវគិតគូរពីយេនឌ័រ គឺធ្វើលើសពីការសម្រេចបាននូវគុណភាពយេនឌ័រ និងមានគោលបំណងស្វែងយល់ និងបង្ហាញពីបទពិសោធចម្រុះរបស់មនុស្សគ្រប់យេនឌ័រ។ ការស្រាវជ្រាវបែបនេះទទួលស្គាល់ថា យេនឌ័រមិនមែនជាប្រភេទដាច់ដោយឡែកនោះទេ ប៉ុន្តែត្រូវបានកំណត់ ដោយរចនាសម្ព័ន្ធអំណាចដែលប្រសព្វគ្នា ដូចជា វណ្ណៈ ជាតិពន្ធុ ពិការភាព អាយុ និងលក្ខណៈផ្លូវភេទជាដើម។

មិនមានវិធីសាស្ត្រតែមួយ ឬវិធីសាស្ត្រជាសកល ដើម្បីធ្វើការស្រាវជ្រាវប្រកបដោយបរិយាបន្ននោះទេ។ ទំនាក់ទំនងយេនឌ័រ និងអំណាចសង្គម មានភាពស្មុគស្មាញ និងជាក់លាក់តាមបរិបទ ដោយវាបង្កប់នៅក្នុងបទដ្ឋានវប្បធម៌ ប្រព័ន្ធនយោបាយ លក្ខខណ្ឌសេដ្ឋកិច្ច និងការអនុវត្តរបស់ស្ថាប័នជាដើម។ ដូច្នេះ ជារឿយៗ អ្នកស្រាវជ្រាវត្រូវប្រើប្រាស់ក្របខណ្ឌ វិធីសាស្ត្រ និងឧបករណ៍ជាច្រើនដែលបំពេញបន្ថែមគ្នាទៅវិញទៅមក និងឆ្លុះបញ្ចាំងពីតថភាពនៃសហគមន៍ចម្រុះ។

នៅក្នុងវិធីសាស្ត្រស្រាវជ្រាវបែបស្ត្រីនិយម (feminist) និងបែបចូលរួម អ្នកដែលពាក់ព័ន្ធក្នុងដំណើរការស្រាវជ្រាវនិងរបៀបដែលពួកគេចូលរួម គឺមានសារៈសំខាន់ដូចគ្នានឹងទិន្នន័យដែលត្រូវបានប្រមូលដែរ។ អ្នកស្រាវជ្រាវគួរកំណត់ឱ្យបានច្បាស់លាស់ ថាតើអ្នកណាជាអ្នកប្រមូលទិន្នន័យ របៀបនៃអំណាច និងការសម្រេចចិត្តត្រូវបានចែករំលែកជាមួយដៃគូសហការ និងថាតើមានការផ្តល់តម្លៃ និងយកចិត្តទុកដាក់លើជំនាញក្នុងមូលដ្ឋានក្នុងកម្រិតណា។

## ឧទាហរណ៍

### ការស្រាវជ្រាវគិតគូរពីយេនឌ័រលើលទ្ធភាពទទួលបានការអប់រំនៅជនបទក្នុងប្រទេសកម្ពុជា

អ្នកស្រាវជ្រាវមួយក្រុមដែលសិក្សាអំពីឧបសគ្គក្នុងការទទួលបានការអប់រំនៅជនបទក្នុងប្រទេសកម្ពុជាបានរៀបចំវិធីសាស្ត្ររបស់ខ្លួនឱ្យមានលក្ខណៈគិតគូពីយេនឌ័រ។ ក្នុងអំឡុងពេលជ្រើសរើសសំណាកពួកគេបានធានានូវតំណាងស្មើគ្នារវាងក្មេងប្រុស និងក្មេងស្រី ហើយក៏បានបញ្ចូលការសម្ភាសន៍ជាមួយមាតាបិតា គ្រូបង្រៀន និងអ្នកដឹកនាំ សហគមន៍ផងដែរ។ ដើម្បីគិតគូរពីបទដ្ឋានវប្បធម៌ ពួកគេបានរៀបចំការពិភាក្សាក្រុមគោលដៅដាច់ដោយឡែកសម្រាប់ក្មេងស្រីដែលដឹកនាំដោយអ្នកសម្របសម្រួលជានារី ដើម្បីបង្កើតបរិយាកាសសុវត្ថិភាពឱ្យក្មេងស្រីអាចនិយាយដោយសេរី។

កម្រងសំណួរមានបញ្ចូលទាំងសំណួរជាក់លាក់តាមយេនឌ័រ ដូចជាថាតើការទទួលខុសត្រូវក្នុងគ្រួសារប៉ះពាល់ដល់ការចូលរៀនយ៉ាងដូចម្តេច។ នៅក្នុងការវិភាគ ក្រុមអ្នកស្រាវជ្រាវបានបែងចែកទិន្នន័យតាមយេនឌ័រ និងបានគូសបញ្ជាក់ពីរបៀបដែលក្មេងស្រីទំនោរបោះបង់ការសិក្សា ដោយសារតែកាតព្វកិច្ចមើលថែទាំ ឬការរៀបការទាំងវ័យក្មេង។ របាយការណ៍ចុងក្រោយបានផ្តល់អនុសាសន៍ឱ្យមានការអនុវត្តអន្តរាគមន៍ចំគោលដៅដូចជា យុទ្ធនាការបង្កើនការយល់ដឹងក្នុងសហគមន៍ និងកម្មវិធីអាហារូបករណ៍សម្រាប់ក្មេងស្រី ជាដើម។ វិធីសាស្ត្រនេះធានាថា តថភាពនៃបញ្ហាយេនឌ័រមិនត្រឹមតែត្រូវបានគេទទួលស្គាល់ប៉ុណ្ណោះទេថែមទាំងត្រូវបានប្រើប្រាស់ដើម្បីផ្តល់ព័ត៌មានសម្រាប់ដាក់ចេញអនុសាសន៍គោលនយោបាយ ដែលគេអាចយកទៅអនុវត្តបានទៀតផង។

# ៤.៥ វិធីសាស្ត្រដែលផ្តោតជនរង គ្រោះជាចម្បង

នៅពេលស្រាវជ្រាវលើប្រធានបទរសើបដូចជា អំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) គេត្រូវយក វិធីសាស្ត្រដែលផ្តោតលើជនរងគ្រោះជាចម្បង និងយល់ដឹងពីការប៉ះទង្គិចផ្លូវចិត្ត មកអនុវត្ត។ វិធីសាស្ត្រនេះ រួមមានការផ្តល់អាទិភាពដល់សេចក្តីថ្លៃថ្នូរ ស្វ័យភាព និងសុវត្ថិភាពរបស់ជនរងគ្រោះ និងការអនុវត្តតាមគោលការណ៍ក្រមសីលធម៌ស្នូល (សូមមើលខាងក្រោម)។ អ្នកស្រាវជ្រាវក៏គួរតែវាយតម្លៃ និងកាត់បន្ថយហានិភ័យដែលអាចកើតមាន ទាំងចំពោះអ្នកចូលរួម ទាំងចំពោះអ្នកប្រមូលទិន្នន័យ ដោយត្រៀមជាស្រេចនូវយន្តការថែទាំ ការបញ្ជូនបន្ត និងការការពារ។

វិធីសាស្ត្រដែលផ្តោតលើជនរងគ្រោះជាចម្បង ផ្តល់សិទ្ធិអំណាចដល់ជនរងគ្រោះដោយចាត់ទុក តម្រូវការ សិទ្ធិនិងជម្រើសរបស់ពួកគេ ជាស្នូលនៃដំណើរការស្រាវជ្រាវ។ វិធីសាស្ត្រនេះទទួលស្គាល់ថា ជនរងគ្រោះពីអំពើ ទាក់ទងនឹងយេនឌ័រម្នាក់ៗ គឺមានភាពខុសប្លែកពីគ្នា មានប្រតិកម្មខុសៗគ្នា ពឹងផ្អែកលើភាពខ្លាំងផ្សេងៗគ្នា និងប្រើប្រាស់យន្តការទប់ទល់ផ្សេងៗគ្នា។ ជនរងគ្រោះមានសិទ្ធិសម្រេចពីព័ត៌មានដែលពួកគេចែករំលែក ត្រូវចែករំលែកជាមួយអ្នកណា និងអ្វីដែលគួរតែកើតឡើងបន្ទាប់។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាការបង្ហាញឱ្យឃើញពីវិសមភាពនៃអំណាច នៅពេលដែលអ្នកមានអំណាច (ដូចជាអ្នកស្រាវជ្រាវនិងអ្នកផ្តល់សេវា) បង្ខំឱ្យគេទទួលយកទស្សនៈរបស់ខ្លួន នោះពួកគេប្រឈមនឹងហានិភ័យធ្វើឱ្យជនរងគ្រោះបាត់បង់អំណាចបន្ថែមទៀត។ វិធីសាស្ត្រដែលផ្តោតលើជនរងគ្រោះ គឺផ្តោតឧត្តមប្រយោជន៍ដល់ជនរងគ្រោះ និងប្រកាន់ខ្ជាប់តាមគោលការណ៍ស្នូលនានា ដូចជា សុវត្ថិភាព ការសម្ងាត់ ការគោរព និងការមិនរើសអើង ជាដើម។

អ្នកស្រាវជ្រាវត្រូវយល់ពីស្ថានភាពអ្នកដែលធ្លាប់ជួបប្រទះទុក្ខសោក ឬការប៉ះទង្គិចផ្លូវចិត្ត ដោយគោរពសិទ្ធិឯកជនរបស់ពួកគេ និងទទួលស្គាល់ថា អ្នកចូលរួមអាចមិនយល់ពីដំណើរការស្រាវជ្រាវ។ អ្នកស្រាវជ្រាវមានកាតព្វកិច្ចធានាថា ការចូលរួមក្នុងការសិក្សាណាមួយ មិនបណ្តាលឱ្យមានគ្រោះថ្នាក់បន្ថែមទៀតនោះទេ។ ក្នុងនាមជាអ្នកស្រាវជ្រាវយើងត្រូវតែថ្លឹងថ្លែងជានិច្ចរវាងហានិភ័យ និងអត្ថប្រយោជន៍ដែលអាចកើតមាន ចេញពីការធ្វើស្រាវជ្រាវលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ដោយសារប្រធានបទស្រាវជ្រាវអំពីអំពើហិង្សាមានលក្ខណៈប៉ះទង្គិចផ្លូវចិត្ត និងអាចបង្កការគំរាមកំហែង គេរឹតតែត្រូវពិចារណាឱ្យបានល្អិតល្អន់អំពីក្រមសីលធម៌។ ប្រសិនបើចាត់ចែងមិនបានត្រឹមត្រូវ សុវត្ថិភាព និងអាយុជីវិតរបស់អ្នកឆ្លើយតប និងអ្នកសម្ភាសន៍អាចនឹងប្រឈមនឹងគ្រោះថ្នាក់ ជាមិនខាន។

# គោលការណ៍នៃវិធីសាស្ត្រដែលផ្ដោតជនរងគ្រោះជាចម្បង

### សុវត្ថិភាព

- ផ្ដល់អាទិភាពដល់សុវត្ថិភាពផ្លូវកាយ ផ្លូវចិត្ត និងផ្លូវអារម្មណ៍របស់ជនរងគ្រោះគ្រប់ពេលវេលា រួមទាំងក្នុងអំឡុងពេលជ្រើសរើសអ្នកចូលរួម ការសម្ភាសន៍ និងការគ្រប់គ្រងទិន្នន័យ។
- ជៀសវាងសកម្មភាពណាមួយដែលអាចធ្វើឱ្យជនរងគ្រោះប្រឈមនឹងការសងសឹក ការប៉ះទង្គិចផ្លូវចិត្តឡើងវិញ ឬគ្រោះថ្នាក់។

### ភាពសម្ងាត់

- ការពារអត្តសញ្ញាណរបស់ជនរងគ្រោះ និងព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបាន។
- ដាក់កំហិតលើការចូលប្រើប្រាស់ទិន្នន័យសម្រាប់តែអ្នកដែលត្រូវការទិន្នន័យប៉ុណ្ណោះ ហើយពន្យល់ឱ្យបានច្បាស់លាស់អំពីដែនកំណត់នៃភាពសម្ងាត់ដល់អ្នកចូលរួម។

### ការយល់ព្រមក្រោយទទួលព័ត៌មានសព្វគ្រប់ និងស្វ័យភាព

- ផ្ដល់ព័ត៌មានច្បាស់លាស់ និងងាយស្រួលយល់អំពីការស្រាវជ្រាវ និងសិទ្ធិរបស់អ្នកចូលរួម។
- ធានាថាការចូលរួមគឺផ្អែកលើគោលការណ៍ស្ម័គ្រចិត្តទាំងស្រុង ហើយជនរងគ្រោះអាចដកការយល់ព្រមរបស់ខ្លួនវិញនៅពេលណាក៏បាន ដោយគ្មានផលវិបាកអវិជ្ជមានអ្វីទាំងអស់។

### ការចូលរួម និងការផ្ដល់សិទ្ធិអំណាច

- ឱ្យជនរងគ្រោះចូលរួមប្រកបដោយអត្ថន័យក្នុងការកំណត់ពីរបៀបរៀបចំ និងអនុវត្តការស្រាវជ្រាវ ឬសេវានានា។
- ទទួលស្គាល់បទពិសោធ និងជម្រើសរបស់ពួកគេ ហើយជៀសវាងការនិយាយ ឬសម្រេចចិត្តជំនួសពួកគេ។

### ការធ្វើការជាមួយអនីតិជន

- ផ្ដល់ឧត្តមប្រយោជន៍របស់កុមារនៅគ្រប់ដំណាក់កាលនៃការស្រាវជ្រាវ។
- ស្វែងរកការយល់ព្រមពីកុមារ បន្ថែមពីលើការយល់ព្រមក្រោយទទួលព័ត៌មានសព្វគ្រប់ពីឪពុកម្ដាយ ឬអាណាព្យាបាលរបស់កុមារ ឬក្មេងជំទង់។
- អនុវត្តតាមច្បាប់ក្នុងស្រុក និងបទដ្ឋានអន្តរជាតិទាំងអស់ ជុំវិញការចូលរួមរបស់កុមារក្នុងការស្រាវជ្រាវដែលមានលក្ខណៈរសើប ដោយជ្រើសរើសយកការការពារណាមួយដែលខ្ពស់ជាង។

### ការគោរព

- ប្រព្រឹត្តចំពោះជនរងគ្រោះទាំងអស់ដោយសេចក្តីថ្លៃថ្នូរ ដោយមិនគិតពីប្រវត្តិ ជម្រើស ឬបទពិសោធរបស់ពួកគេឡើយ។
- ជៀសវាងឥរិយាបថវិនិច្ឆ័យ ហើយធានាថាជនរងគ្រោះត្រូវបានគេយកចិត្តទុកដាក់ស្តាប់ និងជឿជាក់។

### ការមិនរើសអើង

- ធានាឱ្យមានការប្រព្រឹត្តដោយស្មើភាព និងយុត្តិធម៌ចំពោះជនរងគ្រោះទាំងអស់ ដោយមិនគិតពីយេនឌ័រ ជាតិពន្ធុ ពិការភាព អាយុ និន្នាការភេទ ស្ថានភាពសេដ្ឋកិច្ចសង្គម ឬកត្តាអត្តសញ្ញាណផ្សេងទៀតឡើយ។
- ទទួលស្គាល់ភាពលម្អៀងដែលអាចកើតមាន និងទំនាក់ទំនងអំណាចមិនស្មើគ្នា។

### ការមិនបង្កគ្រោះថ្នាក់

- ធានាថាដំណើរការស្រាវជ្រាវមិនបង្កឱ្យមានការប៉ះទង្គិចផ្លូវចិត្ត ការឈឺចាប់ ឬផលវិបាកដែលមិនបានរំពឹងទុក បន្ថែមទៀត។
- វាយតម្លៃហានិភ័យដោយប្រុងប្រយ័ត្ននៅគ្រប់ដំណាក់កាល និងអនុវត្តយុទ្ធសាស្រ្តកាត់បន្ថយហានិភ័យ។

### ការផ្តល់ដំណោះស្រាយ

- បង្កើតយន្តការបញ្ជូនបន្តទៅកាន់សេវាគាំទ្រសមស្រប ក្រោយការសម្ភាសន៍។
- កត់ត្រា និងឆ្លើយតបទៅនឹងការមិនពេញចិត្ត ឱ្យបានភ្លាមៗ។

## ឯកសារយោង


- ការស្រាវជ្រាវដែលផ្តោតជនរងគ្រោះជាចម្បង សេចក្តីណែនាំ គោលការណ៍ និងឯកសារយោង៖ https://www.mcgill.ca/definetheline/files/definetheline/survivor-centred_research_rentschler_et_al.2022.pdf
- ការស្រាវជ្រាវបែបចូលរួមរបស់ជនរងគ្រោះ ការប្រើប្រាស់វិធីសាស្រ្តដែលយល់ដឹងពីការប៉ះទង្គិចផ្លូវចិត្ត និងផ្តោតជនរងគ្រោះជាចម្បង៖ https://jprm.scholasticahq.com/article/24414-participatory-research-engagement-of-vulnerable-populations-employing-survivor-centered-trauma-informed-approaches



# ៥. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺជាដំណើរការនៃការប្រមូលព័ត៌មានជាប្រព័ន្ធ ដើម្បីឆ្លើយតបនឹងសំណួរស្រាវជ្រាវ។ ទោះបីជាតាមរយៈការស្ទង់មតិ ការសម្ភាសន៍ ការសង្កេត ឬទិន្នន័យរដ្ឋបាលក៏ដោយ របៀបដែលទិន្នន័យត្រូវបានប្រមូល ជះឥទ្ធិពលដោយផ្ទាល់ទៅលើភាពត្រឹមត្រូវ ភាពជឿជាក់ និងអត្ថប្រយោជន៍នៃការរកឃើញដែលបានពីការស្រាវជ្រាវ។ ដំណើរការប្រមូលទិន្នន័យដែលហ្មត់ចត់ និងជាប្រព័ន្ធ ជួយធានាថាការស្រាវជ្រាវធ្វើឡើង ផ្អែកលើទិន្នន័យដែលអាចទុកចិត្តបាន និងមានសុពលភាព ដើម្បីគាំទ្រដល់ការវិភាគ និងការបកស្រាយ  ការរកឃើញនៃការស្រាវជ្រាវ។ ការប្រមូលទិន្នន័យដែលមានគុណភាពខ្ពស់ អនុញ្ញាតឱ្យអ្នកស្រាវជ្រាវផ្តល់នូវទិន្នន័យ និងការយល់ដឹងស៊ីជម្រៅសម្រាប់ការសម្រេចចិត្តផ្អែកគោលនយោបាយ ការរៀបចំកម្មវិធី ឬការស្រាវជ្រាវ នាពេលអនាគត។

## ៥.១ វិធីសាស្ត្រប្រមូលទិន្នន័យ

| ការប្រមូលទិន្នន័យបែបគុណវិស័យ | ការប្រមូលទិន្នន័យបែបបរិមាណវិស័យ |
| --- | --- |
| • ការសម្ភាសន៍ស៊ីជម្រៅ<br>• ការពិភាក្សាក្រុមគោលដៅ (FGDs)<br>• ការសង្កេតដោយមានការចូលរួម<br>• កំណត់ត្រាពេលចុះប្រមូលទិន្នន័យនៅទីវាល<br>• ការវិភាគឯកសារ និងខ្លឹមសារ | • ការស្ទង់មតិ<br>• ការធ្វើតេស្ត ឬការវាយតម្លៃ<br>• ការសង្កេត ដែលមានរចនាសម្ព័ន្ធច្បាស់លាស់<br>• ទិន្នន័យជាលេខពីប្រភពដែលមានស្រាប់ (ឧ. ជំរឿន ស្ថិតិជាតិ ទិន្នន័យរដ្ឋបាល) |




ការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ គឺអាស្រ័យលើវិធីសាស្ត្រស្រាវជ្រាវ សំណួរស្រាវជ្រាវ និងកត្តាផ្សេងៗទៀត ដូចជា៖ ពេលវេលា ថវិកា លទ្ធភាពទទួលបានទិន្នន័យ និងលទ្ធភាពជួបអ្នកចូលរួម/អ្នកឆ្លើយតប ជាដើម។

## ការធ្វើឱ្យវិធីសាស្ត្រប្រមូលទិន្នន័យកាន់តែមានលក្ខណៈបរិយាបន្ន

- សួរសំណួរទូលំទូលាយមុនសំណួរជាក់លាក់ ដើម្បីជៀសវាងបង្ហើបចម្លើយដល់អ្នកចូលរួម ឬកំហិតចម្លើយរបស់ពួកគេ។
- ជៀសវាងភាសាដែលនាំមុខ ឬពាក្យពេចន៍ធ្ងន់ៗ ដែលអាចជះឥទ្ធិពលដល់ចម្លើយរបស់អ្នកចូលរួម។
- ប្រើប្រាស់អ្នកសម្របសម្រួលអព្យាក្រឹត ក្នុងករណីដែលទំនាក់ទំនងអំណាចអាចជះឥទ្ធិពលដល់របៀបឆ្លើយតបរបស់អ្នកចូលរួម ។
- សាកល្បងឧបករណ៍របស់អ្នកជាមុន ដើម្បីកំណត់ និងកែសម្រួលសំណួរណាមួយ ដែលអាចនាំឱ្យមានភាពលម្អៀងដោយអចេតនា។

# ៥.២ សម្ភាសន៍

**សម្ភាសន៍** គឺជាវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ដែលត្រូវបានប្រើ ដើម្បីស្វែងយល់ស៊ីជម្រៅអំពីបទពិសោធ មតិយោបល់ និងទស្សនៈរបស់មនុស្ស។ ជាទូទៅ ការសម្ភាសន៍ គឺជាការសន្ទនាមួយទល់នឹងមួយ ដោយប្រើសំណួរបើក ដែលអនុញ្ញាតឱ្យអ្នកចូលរួមនិយាយ ដោយប្រើប្រាស់ពាក្យពេចន៍របស់ខ្លួនផ្ទាល់។ សម្ភាសន៍អនុញ្ញាតឱ្យអ្នកស្រាវជ្រាវបង្កើតទំនុកចិត្ត សួរសំណួរបន្ត និងទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅជាងអ្វីដែលការស្ទង់មតិអាចធ្វើបាន។ សម្ភាសន៍មានបីប្រភេទធំៗគឺៈ សម្ភាសន៍ដែលមានរចនាសម្ព័ន្ធ (structured interviews) សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ (semi-structured interviews) និងសម្ភាសន៍គ្មានរចនាសម្ព័ន្ធ (unstructured interviews) [6]។

- **សម្ភាសន៍ដែលមានរចនាសម្ព័ន្ធ** ប្រើប្រាស់កម្រងសំណួរដែលកំណត់ទុកជាមុន ដែលភាគច្រើនជាសំណួរបិទតាមលំដាប់លំដោយដែលបានកំណត់ ធ្វើឱ្យសម្ភាសន៍ប្រភេទនេះល្អបំផុត សម្រាប់ប្រៀបធៀបចម្លើយរវាងអ្នកចូលរួម និងធានានូវភាពស៊ីសង្វាក់គ្នា និងភាពជឿជាក់។
- **សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ** អនុវត្តតាមមគ្គុទ្ទេសក៍សំណួរដែលអាចបត់បែនបាន ជាមួយនឹងសំណួរបើក ដែលអនុញ្ញាតឱ្យមានការស្វែងយល់ស៊ីជម្រៅ ហើយនៅតែអាចរក្សាបានរចនាសម្ព័ន្ធតាមប្រធានបទ។
- **សម្ភាសន៍គ្មានរចនាសម្ព័ន្ធ** មានលក្ខណៈបើកចំហ និងជាការសន្ទនាទាំងស្រុង ដោយគ្មានសំណួរ ឬលំដាប់លំដោយដែលបានកំណត់ទុកជាមុនឡើយ ដែលផ្តល់នូវការយល់ដឹងស៊ីជម្រៅជាក់លាក់តាមបរិបទ ប៉ុន្តែទាមទារឱ្យមានការសម្របសម្រួលយ៉ាងប៉ិនប្រសប់។

[6] Tegan George, "Types of Interviews in Research | Guide & Examples," Scribbr, June 22, 2023, https://www.scribbr.com/methodology/interviews-research/.

## ការធ្វើឱ្យការសម្ភាសន៍កាន់តែមានលក្ខណៈបរិយាបន្ន

ដើម្បីស្វែងយល់កាន់តែច្បាស់អំពីទស្សនៈចម្រុះ អ្នកស្រាវជ្រាវគួរតែជ្រើសរើសអ្នកចូលរួមពីមជ្ឈដ្ឋានផ្សេងៗគ្នា ជាពិសេសអ្នកដែលមិនសូវមានតំណាងនៅក្នុងការស្រាវជ្រាវកន្លងមក ដូចជា ស្ត្រី ជនមានពិការភាព ជនជាតិភាគតិច ឬសហគមន៍ជនបទ។ សម្ភាសន៍គួរតែត្រូវបានធ្វើឡើងជាភាសាដែលអ្នកចូលរួមមានភាពងាយស្រួល និងនៅទីកន្លែងដែលមានសុវត្ថិភាព ងាយស្រួលទៅដល់ និងមានលក្ខណៈឯកជន។ អ្នកស្រាវជ្រាវគួរតែមានការគោរព ស្ដាប់ដោយមិនវិនិច្ឆ័យ និងកែសម្រួលវិធីសាស្ត្ររបស់ខ្លួន ឱ្យឆ្លើយតបនឹងតម្រូវការរបស់អ្នកចូលរួមម្នាក់ៗ ដូចជា ការផ្ដល់ការបកប្រែភាសា ពេលវេលាដែលអាចបត់បែនបាន ឬការសម្របសម្រួលសមស្របសម្រាប់ជនមានពិការភាព។

## ឯកសារយោង


- មគ្គុទេសក៍នៃការសម្ភាសន៍ Community Toolbox របស់សាកលវិទ្យាល័យ Kansas៖ https://ctb.ku.edu/en/table-of-contents/assessment/assessing-community-needs-and-resources/conduct-interviews/main

# ៥.៣ ការពិភាក្សាក្រុមគោលដៅ

ការពិភាក្សាក្រុមគោលដៅ (Focus group discussions - FGDs) គឺជាវិធីសាស្ត្រមួយ សម្រាប់ប្រមូលមតិយោបល់ស៊ីជម្រៅពីមនុស្សមួយក្រុមតូចអំពីប្រធានបទជាក់លាក់ណាមួយ។ នៅក្នុងការពិភាក្សាក្រុមគោលដៅ អ្នកសម្របសម្រួលដែលមានជំនាញ ដឹកនាំការសន្ទនាជាមួយអ្នកចូលរួមពី ៦ ទៅ ១០ នាក់ ដែលមានបទពិសោធ ឬប្រវត្តិប្រហាក់ប្រហែលគ្នា។ គោលបំណងគឺដើម្បីស្វែងយល់ពីទស្សនៈ អារម្មណ៍ និងសំណូមពររបស់ពួកគេ នៅក្នុងបរិយាកាសប្រកបដោយភាពកក់ក្ដៅ ដែលពួកគេក៏អាចឆ្លើយតបគ្នាទៅវិញទៅមកបានផងដែរ។ ការពិភាក្សាក្រុមគោលដៅមានប្រសិទ្ធភាព នៅពេលដែលអ្នកចង់ស្វែងយល់ពីគំនិតរបស់មនុស្សតាមរយៈពាក្យពេចន៍ផ្ទាល់របស់ពួកគេ ជាពិសេសលើបញ្ហាស្មុគស្មាញ ឬរសើប។ ដើម្បីឱ្យការពិភាក្សាក្រុមគោលដៅទទួលបានជោគជ័យ វាជារឿងសំខាន់ក្នុងការសួរសំណួរបើកចំហ បង្កើតបរិយាកាសប្រកបដោយសុវត្ថិភាព និងការគោរព ហើយធានាថាអ្នកចូលរួមគ្រប់រូបមានឱកាសបញ្ចេញមតិ មិនមែនសម្រាប់តែអ្នកដែលនិយាយច្រើនជាងគេនោះទេ។ ការថតសំឡេងការពិភាក្សា ឬការកត់ត្រាលម្អិតជួយក្នុងការប្រមូលទិន្នន័យសម្រាប់ការវិភាគ នៅពេលក្រោយ។ ការពិភាក្សាក្រុមគោលដៅមានប្រយោជន៍ជាពិសេសក្នុងការស្រាវជ្រាវផ្នែកអភិវឌ្ឍន៍ ដើម្បីស្វែងយល់ពីតម្រូវការសហគមន៍ សាកល្បងគំនិត ឬវាយតម្លៃអំពីរបៀបដែលមនុស្សទទួលបានបទពិសោធពីកម្មវិធី ឬគោលនយោបាយណាមួយ។

## ធ្វើឱ្យការពិភាក្សាក្រុមគោលដៅកាន់តែមានលក្ខណៈបរិយាបន្ន

ដើម្បីធានាថាការពិភាក្សាក្រុមគោលដៅមានលក្ខណៈបរិយាបន្ន និងបង្កភាពងាយស្រួល វាជារឿងសំខាន់ដែលគេត្រូវពិចារណាដោយប្រុងប្រយ័ត្នអំពីអ្នកដែលត្រូវបានអញ្ជើញ ទីកន្លែងដែលការពិភាក្សាប្រព្រឹត្តទៅ និងរបៀបដែលការពិភាក្សាត្រូវបានសម្របសម្រួល។ ត្រូវប្រាកដថាអ្នកចូលរួមឆ្លុះបញ្ចាំងពីសំឡេងមកពីមជ្ឈដ្ឋានចម្រុះ ជាពិសេសអ្នកដែលតែងតែត្រូវបានគេមើលរំលង (ឧ. ស្ត្រី ជនមានពិការភាព ជនជាតិភាគតិច ឬយុវជន)។ ជ្រើសរើសទីតាំង ដែលផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរ មានសុវត្ថិភាព និងជាកន្លែងដែលអ្នកចូលរួមធ្លាប់ស្គាល់។ ប្រើប្រាស់ភាសាសាមញ្ញ ងាយយល់ និងផ្តល់ការបកប្រែភាសា បើចាំបាច់។ ក្នុងអំឡុងពេលពិភាក្សា អ្នកសម្របសម្រួលគួរលើកទឹកចិត្តយ៉ាងសកម្មដល់អ្នកចូលរួមដែលមិនសូវនិយាយស្តីឱ្យបញ្ចេញមតិ និងបង្កើតឱកាសឱ្យគេស្តាប់ទស្សនៈផ្សេងៗ ដោយគ្មានការវិនិច្ឆ័យ។ ការផ្តល់មធ្យោបាយធ្វើដំណើរ ការមើលថែទាំកុមារ ឬអាហារសម្រន់ ក៏អាចកាត់បន្ថយឧបសគ្គ ក្នុងការចូលរួមផងដែរ។

## ឯកសារយោង

- Eval Academic គន្លឹះសម្រាប់ការរៀបចំការពិភាក្សាក្រុមគោលដៅ៖ https://www.evalacademy.com/articles/new-infographic-10-tips-for-running-a-focus-group
- Scribbr ការណែនាំជាជំហានៗ និងឧទាហរណ៍អំពីការពិភាក្សាក្រុមគោលដៅ៖ https://www.scribbr.com/methodology/focus-group/
- Intrac ការណែនាំអំពីការពិភាក្សាក្រុមគោលដៅ៖ https://www.intrac.org/app/uploads/2017/01/Focus-group-discussions. pdf

# ៥.៤ ការស្ទង់មតិ

ការស្ទង់មតិ ប្រើប្រាស់កម្រងសំណួរដែលមានរចនាសម្ព័ន្ធ ជាវិធីសាស្ត្របែបបរិមាណវិស័យចម្បង ដើម្បីប្រមូលព័ត៌មានពីបុគ្គលម្នាក់ៗ ក្នុងគោលបំណងស្វែងយល់ពីទស្សនៈ បទពិសោធ និង/ឬឥរិយាបថរបស់ពួកគេ។ វិធីសាស្ត្រនេះមានប្រយោជន៍ជាពិសេស នៅពេលដែលអ្នកស្រាវជ្រាវត្រូវការប្រមូលទិន្នន័យពីមនុស្សមួយចំនួនធំ តាមរបៀបដែលមានភាពស៊ីសង្វាក់គ្នា និងអាចប្រៀបធៀបបាន។ ការស្ទង់មតិអាចធ្វើឡើងដោយផ្ទាល់ តាមទូរសព្ទ តាមអនឡាញ ឬប្រើប្រាស់ទម្រង់បែបជាក្រដាស។ ដើម្បីទទួលបានលទ្ធផលដែលអាចទុកចិត្តបាន និងប្រកបដោយអត្ថន័យ ការស្ទង់មតិគួរតែត្រូវបានរៀបចំឡើងដោយប្រុងប្រយ័ត្ន ដោយមានសំណួរច្បាស់លាស់ មិនលម្អៀង និងមានសំណាកអ្នកឆ្លើយតបដែលបានកំណត់ច្បាស់លាស់។ ការស្រាវជ្រាវដោយប្រើការស្ទង់មតិ ប្រើប្រាស់ការវិភាគស្ថិតិបែបបរិមាណវិស័យ ដើម្បីកំណត់ពីគំរូ លំនាំ និងទំនាក់ទំនង។ ការរកឃើញទាំងនេះ អាចជួយវាយតម្លៃតម្រូវការតាមដានលទ្ធផលកម្មវិធី ឬផ្តល់ព័ត៌មានសម្រាប់ការសម្រេចចិត្ត ក្នុងការរៀបចំគោលនយោបាយ ការធ្វើផែនការ និងការផ្តល់សេវា។

## ធ្វើឱ្យការស្ទង់មតិកាន់តែមានលក្ខណៈបរិយាបន្ន

មុននឹងដាក់ឱ្យប្រើប្រាស់ការស្ទង់មតិសម្រាប់ការប្រមូលទិន្នន័យ វាជារឿងសំខាន់ក្នុងការសាកល្បងកម្រងសំណួរជាមុនសិន។ ការធ្វើតេស្តបែបនេះជួយកំណត់រកភាសាដែលនាំឱ្យច្រឡំ ភាពរសើបផ្នែកវប្បធម៌ ឬឧបសគ្គក្នុងការយល់ដឹង ជាពិសេសសម្រាប់អ្នកចូលរួមដែលមានកម្រិតអក្ខរកម្មទាប ឬមិនសូវមានបទពិសោធជាមួយការស្រាវជ្រាវផ្លូវការ។ ត្រូវប្រើប្រាស់ភាសាច្បាស់លាស់ សាមញ្ញ និងជៀសវាងពាក្យបច្ចេកទេស។ បកប្រែកម្រងសំណួរទៅជាភាសាក្នុងស្រុក ហើយប្រសិនបើអាចធ្វើទៅបាន ត្រូវរៀបចំការចូលរួមជាច្រើនទម្រង់ ដូចជា សម្ភាសន៍ដោយផ្ទាល់មាត់ និងការប្រើប្រាស់រូបភាពជំនួយសម្រាប់អ្នកដែលមានកម្រិតអក្ខរកម្មទាប ឬទម្រង់ជា ឌីជីថល ឬសំឡេង សម្រាប់អ្នកខ្សោយគំហើញ។

នៅពេលរៀបចំការជ្រើសរើសសំណាក និងការផ្សព្វផ្សាយព័ត៌មានដល់អ្នកចូលរួម ត្រូវធានាថា ស្ត្រី ជនជាតិភាគតិច ជនមានពិការភាព និងអ្នកផ្សេងទៀតដែលកន្លងមកមិនសូវទទួលបានសេវា ឬត្រូវបានគេផាត់ចេញ ត្រូវបានបញ្ចូលទៅក្នុងការស្ទង់មតិ។ ការអាចតម្រូវឱ្យមានការចាប់ដៃគូជាមួយក្រុមការងារក្នុងមូលដ្ឋានដែលគួរឱ្យ ទុកចិត្ត កែសម្រួលពេលវេលា និងទីកន្លែងប្រមូលទិន្នន័យ ដើម្បីសម្របតាមតម្រូវការរបស់អ្នកចូលរួម ឬផ្តល់ជំនួយគាំទ្រ ដូចជា ការធ្វើដំណើរ ការមើលថែទាំកុមារ ឬអ្នកបកប្រែ ជាដើម។ ជាចុងក្រោយ ត្រូវកសាងទំនុកចិត្តដោយបង្កើតបរិយាកាសប្រកបដោយសុវត្ថិភាព និងការគោរពដែលអ្នកចូលរួមអាចឆ្លើយតបដោយសេរី និងជាឯកជនបាន។

## ឯកសារយោង


- សាកលវិទ្យាល័យបូស្តុនការណែនាំអំពីការរៀបចំការស្ទង់មតិ៖ https://www.bu.edu/asir/services/bu-community-surveys/bu-community-surveys-info/survey-development-guide/
- បទដ្ឋាននិងក្រមសីលធម៌នៃការស្ទង់មតិ AAPOR៖ https://aapor.org/standards-and-ethics/best-practices/



# ៦. ការវាយតម្លៃគុណភាពទិន្នន័យ

## ៦.១ ធ្វើការវាយតម្លៃគុណភាពទិន្នន័យ ( DQA )

ការធ្វើការវាយតម្លៃគុណភាពទិន្នន័យ ( Data Quality Assessment - DQA ) ធានាថាព័ត៌មានដែលប្រមូលបានមានភាពត្រឹមត្រូវ អាចទុកចិត្តបាន និងមានប្រយោជន៍ សម្រាប់ការសម្រេចចិត្ត។ ទិន្នន័យដែលមានគុណភាពខ្ពស់ ពង្រឹងភាពគួរឱ្យទុកចិត្តនៃការរកឃើញ និងកែលម្អប្រសិទ្ធភាពនៃកម្មវិធី និងគោលនយោបាយ ផ្អែកលើទិន្នន័យនោះ។ ការវាយតម្លៃគុណភាពទិន្នន័យជួយកំណត់រកចន្លោះប្រហោង ឬចំណុចខ្សោយនៅក្នុងឧបករណ៍ ដំណើរការ និងការអនុវត្តក្នុងការប្រមូលទិន្នន័យ ដែលអាចនាំឱ្យមានការកែតម្រូវ និងកែលម្អបានទាន់ពេលវេលា។

| លក្ខណៈវិនិច្ឆ័យ | អត្ថន័យ |
| --- | --- |
| សុពលភាព | • តើឧបករណ៍ ឬវិធីសាស្ត្រមួយវាស់វែងអ្វីដែលអ្នកចង់សិក្សាបានល្អកម្រិតណា |
| ភាពជឿជាក់បាន | • វិធីសាស្ត្រស្រាវជ្រាវផ្តល់លទ្ធផលដូចគ្នា នៅពេលប្រើប្រាស់ក្រោមលក្ខខណ្ឌដូចៗគ្នា |
| ភាពត្រឹមត្រូវ | • ទិន្នន័យត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវ និងគ្មានកំហុស |



ផ្នែកនេះបង្ហាញពីលក្ខណៈវិនិច្ឆ័យសំខាន់ៗ សម្រាប់ការវាយតម្លៃគុណភាពទិន្នន័យ ដូចជា សុពលភាព ភាពជឿជាក់បាន ភាពត្រឹមត្រូវ ភាពពាក់ព័ន្ធ ភាពពេញលេញ ភាពទាន់ពេលវេលា ភាពជាក់លាក់ ភាពស៊ីសង្វាក់គ្នា និងសុចរិតភាព រួមជាមួយនឹងការណែនាំជាក់ស្តែងអំពីរបៀបត្រួតពិនិត្យលក្ខណៈវិនិច្ឆ័យនីមួយៗ។ តាមរយៈការប្រើប្រាស់ការត្រួតពិនិត្យទាំងនេះក្នុងលក្ខណៈជាប្រព័ន្ធ ក្រុមស្រាវជ្រាវអាចបង្កើនតម្លាភាព កាត់បន្ថយភាពលម្អៀង និងរក្សាស្តង់ដារខ្ពស់ ក្នុងដំណើរការស្រាវជ្រាវទាំងមូល។

## របៀបត្រួតពិនិត្យ

- ត្រូវប្រាកដថាសំណួរឆ្លុះបញ្ចាំងពីគោលដៅស្រាវជ្រាវ។
- សាកល្បងឧបករណ៍របស់អ្នក មុននឹងប្រើប្រាស់វានៅទីវាល។
- ស្នើសុំឱ្យសហការី ឬអ្នកជំនាញពិនិត្យមើលសំណួររបស់អ្នក។
- កំណត់ថាតើលទ្ធផលស្ថិតនៅក្នុងរង្វង់លទ្ធផលដែលចង់បានដែរឬទេ។

- បណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យទាំងអស់ឱ្យប្រើប្រាស់ឧបករណ៍តាមរបៀបដូចៗគ្នា។
- ចងក្រងជាឯកសារ និងប្រើប្រាស់ការណែនាំ និងនិយមន័យឱ្យបានច្បាស់លាស់។
- សាកល្បងឧបករណ៍ដដែលឱ្យបានច្រើនជាងមួយដង រួចប្រៀបធៀបលទ្ធផល។

- ពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យដែលបានបញ្ចូល ធៀបជាមួយឯកសារដើម។
- ពិនិត្យមើលទិន្នន័យដែលបានបញ្ចូលរកមើលកំហុស ទិន្នន័យខុសគេ ឬភាពផ្ទុយគ្នា។
- ត្រួតពិនិត្យការប្រមូលទិន្នន័យនៅទីវាល។

| | |
|---|---|
| **ភាពពាក់ព័ន្ធ** | • ទិន្នន័យគួរតែឆ្លើយតបផ្ទាល់នឹងសំណួរ និងគោលបំណងនៃការស្រាវជ្រាវ |
| **ភាពពេញលេញ** | • មិនគួរមានទិន្នន័យដែលបាត់ ឬសំណួរដែលឆ្លើយមិនពេញលេញនោះទេ |
| **ភាពទាន់ពេលវេលា** | • ទិន្នន័យគួរមានបច្ចុប្បន្នភាព ដើម្បីឱ្យវានៅតែពាក់ព័ន្ធ និងមានប្រយោជន៍សម្រាប់ការសម្រេចចិត្ត |
| **ភាពជាក់លាក់** | • ទិន្នន័យមានភាពលម្អិតគ្រប់គ្រាន់ដើម្បីមានប្រយោជន៍ មិនស្រពិចស្រពិលពេក ឬទូទៅពេក |
| **ភាពស៊ីសង្វាក់** | • ទិន្នន័យគួរតែត្រូវបានប្រមូល តាមរបៀបដូចៗគ្នា សម្រាប់អ្នកចុះប្រមូលទិន្នន័យ អ្នកចូលរួម និងទីតាំងទាំងអស់ |
| **សុចរិតភាព** | • ទិន្នន័យត្រូវបានការពារពីហានិភ័យនៃភាពលម្អៀង កំហុសក្នុងការចម្លង ឬការកែបន្លំ |

## ឯកសារយោង

- Survey CTO ការវាយតម្លៃគុណភាពទិន្នន័យ៖ https://www.surveycto.com/blog/how-to-ensure-data-quality/
- បញ្ជីត្រួតពិនិត្យ DQA របស់ USAID មាននៅទីនេះ៖ https://www.kmtraining.org/wp-content/uploads/2022/06/ah-dqa-checklist_final2021_1.pdf
- ការណែនាំអំពី DQA សម្រាប់ទិន្នន័យសុខាភិបាល៖ https://www.measureevaluation. org/our-work/data-quality/data-quality-review.html
- Data.org ការណែនាំអំពីការត្រួតពិនិត្យគុណភាពទិន្នន័យ៖ https://data.org/guides/how-to-improve-data-quality-through-validation-and-quality-checks/

- ប្រៀបធៀបឧបករណ៍ប្រមូលទិន្នន័យរបស់អ្នកជាមួយគោលបំណងស្រាវជ្រាវ ជាប្រចាំ។
- លុបសំណួរមិនចាំបាច់ចេញ និងធានាថា មានការកត់ត្រាអថេរសំខាន់ៗបានច្បាស់លាស់។

- ប្រើប្រាស់ការតាមដានតាមពេលវេលាជាក់ស្តែង (ឧ. ក្នុង SurveyCTO, KoboToolbox, ឬ Excel) ដើម្បីតាមដានទិន្នន័យដែលបាត់។
- បញ្ចូលចម្លើយដែលត្រូវតែឆ្លើយ តាមកន្លែងសមស្រប។
- ពិនិត្យមើលទម្រង់ដែលបានបំពេញរួចភ្លាមៗ បន្ទាប់ពីសម្ភាសន៍ ឬការស្ទង់មតិ។

- បង្កើតកាលវិភាគជាក់ស្តែងសម្រាប់ការប្រមូលទិន្នន័យ និងអនុវត្តតាមកាលវិភាគនេះ (បង្ហាញពីការរំពឹងទុកទៅកាន់ក្រុមការងារប្រមូលទិន្នន័យ)។
- តាមដានការប្រមូលទិន្នន័យប្រចាំថ្ងៃ។
- ធ្វើការត្រួតពិនិត្យភ្លាមៗ និងជៀសវាងភាពយឺតយ៉ាវក្នុងការធ្វើប្រតិចារិក (transcription) ឬការបញ្ចូលទិន្នន័យ។

- ប្រមូលតម្លៃជាក់លាក់ នៅពេលសមស្រប (ឧ. អាយុពិតប្រាកដ មិនមែនត្រឹមតែ "កុមារ")។
- ជៀសវាងប្រើប្រាស់ប្រភេទទូទៅ ដូចជា "ផ្សេងៗ" លើកលែងតែក្នុងករណីចាំបាច់។
- បំបែកលទ្ធផលតាមប្រភេទពាក់ព័ន្ធ ដូចជា យេនឌ័រ អាយុ ឬទីតាំង នៅពេលចាំបាច់។

- ប្រើប្រាស់មគ្គុទ្ទេសក៍សំណួរ ឬឧបករណ៍ស្ទង់មតិ ដែលមានលក្ខណៈស្តង់ដារ។
- បណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យទាំងអស់តាមរបៀបដូចគ្នា និងធ្វើការបណ្តុះបណ្តាលរំឭកឡើងវិញ។
- ត្រួតពិនិត្យការប្រមូលទិន្នន័យជាប្រចាំ។
- ប្រៀបធៀបចម្លើយរវាងអ្នកចុះប្រមូលទិន្នន័យ ឬតំបន់ ដើម្បីរកមើលភាពមិនស៊ីសង្វាក់គ្នា។

- ត្រួតពិនិត្យលើការចូលប្រើប្រាស់ ដើម្បីកំហិតអ្នកដែលអាចផ្លាស់ប្តូរ ឬកែសម្រួលទិន្នន័យបាន។
- អនុវត្តវិធានការសុវត្ថិភាពទិន្នន័យ ដូចជា ពាក្យសម្ងាត់ ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ multi-factor authentication និងencryption ដើម្បីកាត់បន្ថយការចូលប្រើប្រាស់ ដោយគ្មានការអនុញ្ញាត។
- ធ្វើសវនកម្មជាប្រចាំ ដើម្បីធានាបូរណភាពទិន្នន័យ។



# ៧. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ រួមមាន ការរៀបចំជាប្រព័ន្ធ ការសម្អាត និងការបកស្រាយទិន្នន័យដែលបានប្រមូល។ ការយល់ដឹងស៊ីជម្រៅដែលទទួលបានពីការវិភាគទិន្នន័យ ជួយឆ្លើយតបនឹងសំណួរស្រាវជ្រាវ កំណត់រកលំនាំ ទាញសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍។ គេអាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា សម្រាប់វិភាគទិន្នន័យ អាស្រ័យលើប្រភេទទិន្នន័យដែលបានប្រមូល។

## ៧.១ ការវិភាគទិន្នន័យបរិមាណវិស័យ

**ការវិភាគទិន្នន័យបរិមាណវិស័យ** ពាក់ព័ន្ធនឹងការប្រើប្រាស់តួលេខ ដើម្បីស្វែងរកលំនាំ ធ្វើតេស្តទំនាក់ទំនង និងសង្ខេបព័ត៌មាន ដោយប្រើស្ថិតិ។ ការវិភាគបែបនេះអាចមានការប្រើប្រាស់បច្ចេកទេសសាមញ្ញៗ ដូចជាការគណនាមធ្យមភាគ និងភាគរយ ឬវិធីសាស្ត្រស្មុគស្មាញជាងនេះ ដូចជា ការវិភាគរីហ្គ្រេសិន (regression) ឬការធ្វើតេស្តសម្មតិកម្ម ដើម្បីផ្តល់លទ្ធផលស្រាវជ្រាវដែលមានលក្ខណៈសត្យានុម័ត អាចវាស់វែងបាន និងទាញជាការរកឃើញទូទៅ សម្រាប់ស្ថិតិសកល (ប្រសិនបើការរៀបចំសំណាកធ្វើឡើងត្រឹមត្រូវ)។

**សូមចងចាំថា ការវិភាគទិន្នន័យបរិមាណវិស័យ ជារឿយៗត្រូវបានប្រើដើម្បីឆ្លើយសំណួរដូចជា *តើមានចំនួនប៉ុន្មាន? តើញឹកញាប់ប៉ុណ្ណា?* ឬ *តើមានផលប៉ះពាល់អ្វីខ្លះ?***



## ការវិភាគទិន្នន័យបរិមាណមានពីរប្រភេទសំខាន់ៗ។

**ស្ថិតិពិពណ៌នា** *(descriptive statistics)* ត្រូវបានប្រើ ដើម្បីពិពណ៌នាអំពីសំណុំទិន្នន័យ តាមរយៈការសង្ខេបទិន្នន័យ និងស្វែងរកលំនាំ ដែលជួយយើងឱ្យយល់លម្អិតនៃសំណាក/សំណុំទិន្នន័យជាក់លាក់។ ស្ថិតិប្រភេទនេះជួយពិពណ៌នាអំពីលក្ខណៈមូលដ្ឋាននៃសំណុំទិន្នន័យ ដូចជា តម្លៃមធ្យម ភាគរយ និងប្រេកង់ (frequencies) ដែលធ្វើឱ្យគេកាន់តែងាយយល់អំពីលំនាំ នៅក្នុងសំណាកជាក់លាក់ណាមួយ។ ឧទាហរណ៍ ស្ថិតិពិពណ៌នាបង្ហាញពីចំនួនមនុស្សដែលបានឆ្លើយតបតាមរបៀបជាក់លាក់ណាមួយ ឬចម្លើយមួយណាដែលកើតមានញឹកញាប់ជាងគេ។ វាផ្តល់ឱ្យយើងនូវរូបភាពនៃអ្វីដែលកំពុងកើតឡើង នៅក្នុងក្រុមដែលយើងបានសិក្សា។

**ស្ថិតិអនុមាន** (*inferential statistics*) ធ្វើលើសពីនេះមួយកម្រិតទៀត ដោយជួយធ្វើការព្យាករ ឬទាញជាការរកឃើញទូទៅសម្រាប់ស្ថិតិសកល (generalization) ផ្អែកលើការសិក្សាលើក្រុម (សំណាក)។ ការវិភាគប្រភេទនេះត្រូវបានប្រើប្រាស់ សម្រាប់ធ្វើតេស្តសម្មតិកម្ម ដើម្បីព្យាករពីការផ្លាស់ប្តូរ ឬភាពខុសគ្នា និងអាចបង្ហាញពីទំនាក់ទំនងរវាងអថេរនានា (បុគ្គល ទីកន្លែង វត្ថុ បាតុភូតដែលយើងកំពុងព្យាយាមវាស់វែង)។ ឧទាហរណ៍ អ្នកស្រាវជ្រាវម្នាក់អាចសិក្សាលើសំណាកចំនួន ១០០ គ្រួសារ ដើម្បីសាកល្បងថាតើកម្រិតប្រាក់ចំណូលមានទំនាក់ទំនងជាមួយការទទួលបានសេវាថែទាំសុខភាពដែរឬទេ ហើយបន្ទាប់មកប្រើស្ថិតិអនុមាន ដើម្បីព្យាករថាតើទំនាក់ទំនងខាងលើអាចបកស្រាយបានជាទំនាក់ទំនងទូទៅ សម្រាប់តំបន់ទាំងមូលដែរឬទេ។

# ៧.២ ការវិភាគទិន្នន័យគុណវិស័យ

ការវិភាគទិន្នន័យគុណវិស័យ ផ្តោតលើការកំណត់រកប្រធានបទ អត្ថន័យ និងការយល់ដឹងស៊ីជម្រៅពីទិន្នន័យមិនមែនជាតួលេខ ដូចជា អត្ថបទប្រតិចារិកនៃកិច្ចសម្ភាសន៍ (interview transcripts) កំណត់ត្រានៃការពិភាក្សាក្រុមគោលដៅ ឬកំណត់ត្រានៃការសង្កេត។ នៅក្នុងការវិភាគប្រភេទនេះ មានការរៀបចំទិន្នន័យ ការដាក់កូដគំនិតសំខាន់ៗ និងការស្វែងរកលំនាំជុំវិញរបៀបដែលមនុស្សនិយាយអំពីបទពិសោធរបស់ពួកគេ។ វាគឺជាដំណើរការបកស្រាយ ដែលផ្តល់តម្លៃដល់ភាពស៊ីជម្រៅ បរិបទ និងភាពចម្រុះនៃទស្សនៈ។ ការវិភាគគុណវិស័យជួយឆ្លើយសំណួរដូចជា ហេតុអ្វីបានជារឿងនេះកើតឡើង? ឬ តើវាមានន័យយ៉ាងណាចំពោះអ្នកដែលពាក់ព័ន្ធ? ហើយវាមានប្រយោជន៍ជាពិសេស ដើម្បីយល់អំពីបញ្ហាសង្គមដ៏ស្មុគស្មាញ។

## ការបង្កើតក្របខ័ណ្ឌ សម្រាប់វិភាគទិន្នន័យគុណវិស័យ

គេអាចបង្កើតក្របខ័ណ្ឌ សម្រាប់វិភាគទិន្នន័យគុណវិស័យ នៅក្នុងកម្មវិធី Excel ឬបញ្ជីការងារ (spreadsheet software) ផ្សេងទៀត។ ចាប់ផ្តើមដោយដាក់សំណួរទាំងអស់ ដែលបានពីមគ្គុទ្ទេសក៍សំណួរនៅក្នុងជួរដេក ហើយដាក់ឈ្មោះ ឬលេខសម្គាល់របស់អ្នកចូលរួមម្នាក់ៗនៅតាមបណ្តោយជួរឈរ។ បញ្ចូលខ្លឹមសារប្រតិចារិកនៃចម្លើយដែលបានចម្លង នៅក្រោមឈ្មោះអ្នកចូលរួមម្នាក់ៗ។ បន្ថែមជួរឈរសង្ខេបមួយ ដើម្បីជួយដល់ការវិភាគតាមប្រធានបទ។ នៅក្នុង sheet ដាច់ដោយឡែកមួយនៅក្នុងឯកសារ Excel តែមួយ សូមរាយសំណួរស្រាវជ្រាវចម្បង និងសំណួរស្រាវជ្រាវបន្ទាប់បន្សំរបស់អ្នក។ ប្រើសន្លឹកកិច្ចការនេះ ដើម្បីដាក់កូដនៃការយល់ដឹងដែលទាក់ទងនឹងសំណួរស្រាវជ្រាវនីមួយៗ ជាក្រុម។

### ឯកសារយោង

- ការវិភាគទិន្នន័យបរិមាណវិស័យ៖ការណែនាគ្រប់ជ្រុងជ្រោយ https://hevodata.com/learn/quantitative-data-analysis/
- ការបង្រៀនជាមូលដ្ឋានអំពីការវិភាគទិន្នន័យបរិមាណ១០១៖ ស្ថិតិពិពណ៌នាទល់នឹងស្ថិតិអនុមានជាមួយឧទាហរណ៍- វីដេអូរយៈពេល២៨នាទីដែលពន្យល់ពីភាពខុសគ្នារវាងស្ថិតិពិពណ៌នានិងស្ថិតិអនុមាន
- ឧបករណ៍ទូទៅសម្រាប់ការវិភាគទិន្នន័យបរិមាណវិស័យ៖ Microsoft Excel, SPSS, Stata, R

## ឧទាហរណ៍

| អ្នកចូលរួម | តើលោក/លោកស្រីប្រឈមនឹងបញ្ហាអ្វីខ្លះ នៅពេលព្យាយាមបោះចោលសំរាមពីផ្ទះ ឱ្យបានត្រឹមត្រូវ? | តើលោក/លោកស្រីចង់ឃើញមានការកែលម្អអ្វីខ្លះ នៃសេវាសាធារណៈក្នុងមូលដ្ឋាន? |
|---|---|---|
|  | គ្មានធុងសំរាមនៅជិតផ្សារទេ ដូច្នេះគេបោះចោលសំរាមគ្រប់ទីកន្លែង។ | បន្ថែមធុងសំរាមសាធារណៈឱ្យបានច្រើន និងផ្សព្វផ្សាយជាសាធារណៈនូវកាលវិភាគប្រមូលសំរាម។ |
|  | ពួកយើងមិនដឹងពីកាលវិភាគទេ ដូច្នេះពួកយើងតែងតែខកខានថ្ងៃប្រមូលសំរាម។ | ផ្តល់ជម្រើសសម្រាប់កែច្នៃឡើងវិញ មិនមែនមានធុងតែមួយសម្រាប់ដាក់សំរាមគ្រប់យ៉ាងនោះទេ។ |
|  | ឡានដឹកសំរាមមានសំឡេងរំខាន ហើយមកព្រលឹមពេក។ | កែលម្អការប្រាស្រ័យទាក់ទង និងធ្វើឱ្យសេវា កាន់តែឆ្លើយតបទៅនឹងពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ។ |

## ជំហាន ដើម្បីធ្វើការវិភាគទិន្នន័យគុណវិស័យ

**ជំហាន ១** | **ធ្វើប្រតិចារិកកិច្ចសម្ភាសន៍**

ដោយបំប្លែងសំឡេងពីកិច្ចសម្ភាសន៍ និងការពិភាក្សាក្រុមគោលដៅ ទៅជាអត្ថបទ សម្រាប់ធ្វើការវិភាគ។

**ជំហាន ២** | **ស្វែងយល់ពីទិន្នន័យឱ្យបានច្បាស់**

ដោយអានប្រតិចារិកនៃកិច្ចសម្ភាសន៍ឱ្យបានច្រើនដង។

**ជំហាន ៣** | **ដាក់កូដទិន្នន័យ**

កំណត់រក និងដាក់ស្លាកសម្គាល់គំនិត ឥរិយាបថ ឧប្បត្តិហេតុ រចនាសម្ព័ន្ធ តម្លៃ ជំនឿ និងអារម្មណ៍សំខាន់ៗ។

**ជំហាន ៤** | **ចាត់ថ្នាក់កូដ**

ដើម្បីសម្រួលដល់ការវិភាគ។

**ជំហាន ៥** | **កំណត់រកប្រធានបទ**

(ប្រធានបទ គំនិត លំនាំដែលកើតឡើងដដែលៗ)។

**ជំហាន ៦** | **បកស្រាយការវិភាគតាមប្រធានបទ**

ដើម្បីជួយឆ្លើយសំណួរស្រាវជ្រាវ។

## ការធ្វើឱ្យដំណើរការវិភាគទិន្នន័យកាន់តែមានលក្ខណៈបរិយាបន្ន

- បែងចែកទិន្នន័យតាមជាតិពន្ធុ យេនឌ័រ អាយុ ស្ថានភាពសង្គម ពិការភាព និងគំរូអត្តសញ្ញាណដែលពាក់ព័ន្ធផ្សេងទៀត ព្រមទាំងទិដ្ឋភាពដែលទាក់ទងនឹងវិសមភាពដែលប្រសព្វគ្នា។
- ព្យាយាមប្រើប្រាស់វិធីសាស្ត្រសហការ និងស្វែងរកធាតុចូលពីអ្នកចូលរួមក្នុងការស្រាវជ្រាវ និងអ្នកពាក់ព័ន្ធនឹងការស្រាវជ្រាវ ដើម្បីពិនិត្យរកភាពសមហេតុផល និងផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវ។
- ដាក់កូដសម្គាល់ចម្លើយដោយប្រើពាក្យពេចន៍ផ្ទាល់របស់អ្នកចូលរួម មុននឹងប្រើប្រាស់ប្រភេទ ឬការបកស្រាយទូទៅ ។
- អញ្ជើញអ្នកស្រាវជ្រាវច្រើននាក់ឱ្យចូលរួមក្នុងការដាក់កូដ និងប្រើប្រាស់បច្ចេកទេសព្រមព្រៀងរវាងអ្នកដាក់កូដ (intercoder agreement) ដើម្បីត្រួតពិនិត្យភាពស៊ីសង្វាក់គ្នា។
- ឆ្លុះបញ្ចាំងពីបរិបទផ្ទាល់ខ្លួនរបស់អ្នក និងថាតើវាអាចជះឥទ្ធិពលដល់ការបកស្រាយរបស់អ្នក យ៉ាងដូចម្តេច។
- ផ្ទៀងផ្ទាត់ទិន្នន័យពីប្រភពផ្សេងៗគ្នា ដោយប្រៀបធៀបលទ្ធផលស្រាវជ្រាវដែលទទួលបានពីវិធីសាស្ត្រផ្សេងៗគ្នា (ឧទាហរណ៍៖ កិច្ចសម្ភាសន៍ ឯកសារ ការសង្កេត)។

## ឯកសារយោង

- ការធ្វើការស្រាវជ្រាវគុណវិស័យសម្រាប់កម្មវិធីអភិវឌ្ឍន៍ https://asiafoundation.org/publication/doing-qualitative-research-for-developmentprogramming-a-step-by-step-guide/
- ការបង្រៀនជាមូលដ្ឋានអំពីការវិភាគទិន្នន័យគុណវិស័យ ១០១៖វិធីសាស្ត្រវិភាគចំនួន៦+ ឧទាហរណ៍៖ វីដេអូរយៈពេល២៥នាទីដែលណែនាំអំពីការវិភាគគុណវិស័យចំនួនប្រាំមួយប្រភេទនិងពេលណាដែលត្រូវប្រើប្រាស់វាជាការល្អបំផុតសម្រាប់ស្វែងយល់ពីវិធីសាស្ត្រក្រៅពីការវិភាគតាមប្រធានបទ
- ការបង្រៀនអំពីការដាក់កូនទៅទិន្នន័យគុណវិស័យ៖របៀបដាក់កូដទិន្នន័យគុណវិស័យសម្រាប់ការវិភាគ(៤ជំហាន+ឧទាហរណ៍៖ វីដេអូរយៈពេល២៧នាទីដែលបង្ហាញពីជំហានសំខាន់ៗនៃការដាក់កូដទិន្នន័យគុណវិស័យជាមួយនឹងគន្លឹះអនុវត្តជាក់ស្តែង ជម្រើសវិធីសាស្ត្រសម្រាប់ដណាក់កាលនីមួយៗនៃដំណើរការ។

# ៨. ការសរសេររបាយការណ៍ស្រាវជ្រាវ

របាយការណ៍ស្រាវជ្រាវ ពន្យល់អំពីដំណើរការស្រាវជ្រាវ ការរកឃើញនៃការស្រាវជ្រាវ និងភាពពាក់ព័ន្ធនៃការរកឃើញទាំងនោះ។ របាយការណ៍ស្រាវជ្រាវ ជាឯកសារផ្លូវការសម្រាប់ផ្សព្វផ្សាយការរកឃើញនៃការស្រាវជ្រាវ ទៅកាន់ភាគីពាក់ព័ន្ធ អ្នកផ្តល់មូលនិធិ អ្នករៀបចំគោលនយោបាយ និងក្រុមគោលដៅដទៃទៀត។ បន្ថែមពីលើរបាយការណ៍គោល អ្នកស្រាវជ្រាវអាចជ្រើសរើសរៀបចំសម្ភារផ្សព្វផ្សាយបន្ថែមទៀត ដូចជា សង្ខេបគោលនយោបាយ វីដេអូ និងបទបង្ហាញជាដើម។

## ៨.១ ធាតុសំខាន់ៗនៃរបាយការណ៍ស្រាវជ្រាវ [7]

| | ផ្នែក | អត្ថន័យ |
|---|---|---|
| ១ | ចំណងជើង | ចំណងជើងខ្លី និងជាក់លាក់ដែលឆ្លុះបញ្ចាំងពីប្រធានបទស្រាវជ្រាវ |
| ២ | សេចក្តីសង្ខេប/សង្ខេបរួម | សេចក្តីសង្ខេបខ្លីនៃរបាយការណ៍ទាំងមូល |
| ៣ | សេចក្តីផ្តើម/សាវតារ | រៀបរាប់ពីបរិបទនៃការសិក្សា |
| ៤ | ការពិនិត្យឯកសារពាក់ព័ន្ធ | ទិដ្ឋភាពទូទៅនៃការស្រាវជ្រាវដែលមានស្រាប់ |

## អ្វីដែលត្រូវដាក់បញ្ចូល

- សរសេរឱ្យខ្លី (អតិបរមា ១៥ ពាក្យ)
- បញ្ចូលពាក្យគន្លឹះ ឬទីតាំង
- ជៀសវាងចំណងជើងដែលមិនច្បាស់លាស់ ឬទូទៅពេក

- គោលបំណង វិធីសាស្ត្រ ការរកឃើញសំខាន់ៗ និងអនុសាសន៍ (១៥០-៣០០ ពាក្យ)
- សង្ខេបរួម រៀបចំតម្រូវតាមអ្នកអានដែលជាអ្នករៀបចំគោលនយោបាយ

- សង្ខេបរួមអំពីបញ្ហា និងមូលហេតុដែលបញ្ហានេះមានសារសំខាន់
- សំណួរស្រាវជ្រាវ ឬវត្ថុបំណងនៃការស្រាវជ្រាវ

- តើអ្វីខ្លះដែលគេបានដឹងរួចហើយ?
- ចន្លោះប្រហោង ដែលការសិក្សារបស់អ្នកនឹងបំពេញ
- ទ្រឹស្តីពាក់ព័ន្ធ ឬលទ្ធផលស្រាវជ្រាវពីមុន

| | | |
|---|---|---|
| ៥ | វិធីសាស្ត្រស្រាវជ្រាវ | របៀបដែលការស្រាវជ្រាវត្រូវបានធ្វើឡើង |
| ៦ | លទ្ធផល/ការរកឃើញ | ការពិត ឬទិន្នន័យដែលអ្នកបានរកឃើញ |
| ៧ | ការពិភាក្សា | អត្ថន័យនៃការរកឃើញ |
| ៨ | សេចក្តីសន្និដ្ឋាន និងអនុសាសន៍ | សង្ខេបចំណុចសំខាន់ៗ និងអ្វីដែលគួរកើតឡើងបន្ទាប់ |
| ៩ | បញ្ជីឯកសារយោង | បញ្ជីនៃប្រភពដែលបានដកស្រង់ក្នុងរបាយការណ៍ |
| ១០ | ឧបសម្ព័ន្ធ | ឯកសារគាំទ្រដែលមិនមាននៅក្នុងអត្ថបទគោល |

## ការពិនិត្យដោយអ្នកជំនាញដូចគ្នា (peer review) និងមូលហេតុដែលការពិនិត្យបែបនេះមានសារសំខាន់[8]

ការពិនិត្យដោយអ្នកជំនាញដូចគ្នា គឺជាដំណើរការដែលអ្នកស្រាវជ្រាវដាក់ស្នើការសិក្សាស្រាវជ្រាវរបស់ពួកគេទៅកាន់អ្នកជំនាញក្នុងវិស័យស្រាវជ្រាវពាក់ព័ន្ធ ដើម្បីទទួលបានមតិកែលម្អ និងការវាយតម្លៃ ប្រកបដោយភាពស៊ីជម្រៅ។ ជាទូទៅ ដំណើរការនេះ ធ្វើឡើងមុនពេលបោះពុម្ពផ្សាយ ដើម្បីធានាបាននូវសុពលភាព ភាពត្រឹមត្រូវ និងគុណភាព។ ការពិនិត្យបែបនេះមានសារសំខាន់ព្រោះវាជាដំណើរការដើម្បីធានាថា ការស្រាវជ្រាវដែលក្លែងបន្លំ និងមិនគួរឱ្យទុកចិត្ត មិនត្រូវបានបោះពុម្ពផ្សាយ ហើយព័ត៌មានមានភាពច្បាស់លាស់ និងងាយស្រួលយល់សម្រាប់អ្នកដែលមិនមែនជាអ្នកស្រាវជ្រាវ ឬសាធារណជនទូទៅ។

7 សម្រាប់ការពន្យល់លំអិតអំពីធាតុនីមួយៗនៅក្នុងរបាយការណ៍ស្រាវជ្រាវសូមយោងទៅកាន់ University of Melbourne, "Research Reports," Academic Skills, ចូលមើលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥៖ https://students.unimelb.edu.au/academic skills/resources/reading,-writing-and-referencing/reports/research reports#:~:text=It%20should%20be%20brief%2C%20written,the%20findings %3B%20and%20recommendations%20made.

៨ សម្រាប់ព័ត៌មានលម្អិតអំពីការត្រួតពិនិត្យដោយអ្នកជំនាញដូចគ្នានិងសារសំខាន់របស់វាសូមចូលទៅកាន់៖ https://www.scribbr.com/methodology/peer-review/

- គ្រោងការសិក្សា ការជ្រើសរើសសំណាក ឧបករណ៍ ការប្រមូលទិន្នន័យ និងវិធីសាស្ត្រវិភាគ
- ការពិចារណាផ្នែកសីលធម៌

- ប្រើតារាង ក្រាហ្វិក និងការបរិយាយឱ្យបានច្បាស់លាស់
- បង្ហាញទិន្នន័យដោយមិនបកស្រាយ

- បកស្រាយលទ្ធផល
- ភ្ជាប់ត្រឡប់ទៅសំណួរស្រាវជ្រាវវិញ
- ប្រៀបធៀបជាមួយការសិក្សាពីមុនៗ ប្រសិនបើមានការសិក្សាពាក់ព័ន្ធ

- សង្ខេបរកឃើញចម្បងៗ
- អនុសាសន៍ដែលអាចយកទៅអនុវត្តបានសម្រាប់អ្នករៀបចំគោលនយោបាយ អ្នកផ្តល់មូលនិធិ ឬអ្នកអនុវត្ត

- បញ្ចូលប្រភពទិន្នន័យ និងឯកសារទាំងអស់ដែលបានដកស្រង់
- ប្រើទម្រង់ដកស្រង់ដែលស្របគ្នាតែមួយ

- ឧបករណ៍ (ឧ. កម្រងសំណួរ) ទម្រង់យល់ព្រម តារាងបន្ថែម ការដកស្រង់ទិន្នន័យដើម ។ល។

## ការធ្វើឱ្យរបាយការណ៍កាន់តែមានលក្ខណៈបរិយាបន្ន

- វិភាគពីរបៀបដែលការរកឃើញនៃការស្រាវជ្រាវជះឥទ្ធិពលលើក្រុមមនុស្សផ្សេងៗគ្នា និងកំណត់រកឱ្យឃើញនូវបញ្ហាជាប្រព័ន្ធនានា។ ពិភាក្សាអំពីភាពពាក់ព័ន្ធ សម្រាប់ការលើកកម្ពស់បរិយាបន្ន ការតតាំងនឹងការរើសអើង ឬការផ្លាស់ប្តូរទម្លាប់ដែលបង្កគ្រោះថ្នាក់។ ជៀសវាងចាត់ទុកបញ្ហា GEDSI (សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម) ជាប្រធានបទបន្ទាប់បន្សំ។ ផ្ទុយទៅវិញ ចាត់ទុកបញ្ហា GEDSI ថាជាផ្នែកសំខាន់ នៃការបកស្រាយការរកឃើញនៃការស្រាវជ្រាវ។
- ធានាថាអនុសាសន៍មានភាពជាក់លាក់ មានភាពប្រាកដនិយម និងពាក់ព័ន្ធទៅនឹងតួអង្គផ្សេងៗ (ឧ. អ្នករៀបចំគោលនយោបាយ អ្នកផ្តល់សេវា សង្គមស៊ីវិល សហគមន៍)។ ផ្តោតការយកចិត្តទុកដាក់លើកត្តាជំរុញឱ្យមានវិសមភាពជាប្រព័ន្ធ។ ក្នុងករណីដែលអាចធ្វើទៅបាន រៀបចំអនុសាសន៍រួមគ្នាជាមួយក្រុមដែលរងផលប៉ះពាល់។
- ស្នើសុំឱ្យអ្នកចូលរួមពិនិត្យ និងផ្ទៀងផ្ទាត់ការបកស្រាយរបស់អ្នកលើធាតុចូលរបស់ពួកគេ។
- អញ្ជើញឱ្យអ្នកជំនាញដូចគ្នា ឬភាគីពាក់ព័ន្ធ ចូលរួមពិនិត្យឡើងវិញការរកឃើញនៃការស្រាវជ្រាវ ដើម្បីពិនិត្យលើការសន្មត ឬការយល់ឃើញដែលត្រូវបានមើលរំលង។
- បង្ហាញឱ្យឃើញពីដែនកំណត់នានា ដោយតម្លាភាព។ ទទួលស្គាល់កន្លែងដែលអាចនៅមានភាពលម្អៀង និងរបៀបដែលភាពលម្អៀងនោះត្រូវបានកាត់បន្ថយ។

# ៨.២ ការផ្សព្វផ្សាយការរកឃើញនៃការស្រាវជ្រាវ

**១** ចាប់ផ្តើមជាមួយគោលដៅស្រាវជ្រាវរបស់អ្នក។

**២** កំណត់វត្ថុបំណងនៃការផ្សព្វផ្សាយរបស់អ្នក ដោយសួរថាតើអ្នកចង់ឃើញការផ្លាស់ប្តូរអ្វីខ្លះ ចេញពីការចែករំលែកការរកឃើញនៃការស្រាវជ្រាវទាំងនេះ។ តើអ្នកចង់ឱ្យភាគីពាក់ព័ន្ធធ្វើអ្វីខ្លះ បន្ទាប់ពីបានអានឯកសារស្រាវជ្រាវរបស់អ្នក? តើអ្នកចង់ឱ្យពួកគេយល់កាន់តែច្បាស់អំពីប្រធានបទណាមួយ (ការបង្កើនការយល់ដឹង) ចាត់វិធានការ (ជះឥទ្ធិពលលើគោលនយោបាយ) ឬផ្លាស់ប្តូរឥរិយាបថ (កែលម្អការអនុវត្ត)?

**៣** កំណត់អ្នកអាន/អ្នកស្តាប់របស់អ្នក។ តើអ្នកណានឹងអាន/ពិនិត្យមើលលទ្ធផល និងអនុសាសន៍ស្រាវជ្រាវរបស់អ្នក?

**៤** សម្រិតសម្រាំងសាររបស់អ្នក។ តើអ្វីជាចំណុចគន្លឹះដែលអ្នកអាន/អ្នកស្តាប់នីមួយៗរបស់អ្នកគួរទទួលបាន? ប្រើប្រាស់ការរកឃើញនៃការស្រាវជ្រាវរបស់អ្នក ដើម្បីរៀបរាប់ជារឿង តាមរយៈ៖

ក. ការពិពណ៌នា ឬកំណត់បញ្ហា និងដំណោះស្រាយដែលអាចមាន ឬទាំងពីរ

ខ. ការភ្ជាប់អង្គហេតុ ទៅនឹងបរិបទ ដោយពន្យល់ពីមូលហេតុដែលបញ្ហា ឬដំណោះស្រាយនោះមានសារសំខាន់ និង

គ. ការផ្តល់អនុសាសន៍អំពីសកម្មភាពដែលត្រូវចាត់វិធានការ។

**៥** រៀបចំ និងអនុវត្តផែនការផ្សព្វផ្សាយ/ការចូលរួម

**៦** តាមដានវឌ្ឍនភាពនៃកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយរបស់អ្នក និងធ្វើការកែតម្រូវតាមការចាំបាច់។

## ឯកសារយោង

- គំរូផែនការផ្សព្វផ្សាយ៖ https://guides.library.vcu.edu/c.phpg=480243&p=6785181
- ការណែនាំអំពីការរៀបចំផែនការទំនាក់ទំនង៖ https://www.researchretold. com/communications-plan-for-disseminating-research-findings/
- ការរៀបចំផែនការទំនាក់ទំនងសម្រាប់ការស្រាវជ្រាវ៖ https://www.reading.ac.uk/research/-/media/discover/files/pdfs/9435290e50904cc9b8e623d5ddb13602.pdf

## ឧទាហរណ៍នៃការផ្សព្វផ្សាយការស្រាវជ្រាវ

- សេចក្តីសង្ខេប (សង្ខេបគោលនយោបាយ សង្ខេបបញ្ហា និងក្រាហ្វិកព័ត៌មាន)
- កញ្ចប់ឧបករណ៍
- វីដេអូ ការផ្សាយផ្ទាល់
- ការគាំទ្រដល់អ្នកសារព័ត៌មានដែលសរសេរអត្ថបទព័ត៌មានពិស្តារ
- ល្ខោន របាំ និងការបង្ហាញសោតទស្សន៍ផ្សេងទៀត
- គេហទំព័រខ្នាតតូច
- ការបង្ហោះលើបណ្តាញសង្គម

## គន្លឹះនៃការសរសេរការផ្សព្វផ្សាយការស្រាវជ្រាវ

- ប្រើភាសាច្បាស់លាស់ និងងាយយល់, ប្រើពាក្យសន្ទនាប្រចាំថ្ងៃ
- ប្រើពាក្យពេចន៍ជាក់ស្តែង ជាជាងពាក្យអរូបី
- ប្រើកិរិយាស័ព្ទសកម្ម (Active voice)
- ប្រើប្រយោគខ្លីៗដែលគ្មានពាក្យបច្ចេកទេស
- ប្រើចំណងជើង និងចំណងជើងរង ដែលមានលក្ខណៈពិពណ៌នា
- ប្រើអក្សរកាត់ក្នុងកម្រិតសមរម្យ ហើយសរសេរពាក្យពេញ នៅពេលប្រើលើកដំបូង
- កំណត់និយមន័យពាក្យបច្ចេកទេសឱ្យបានច្បាស់លាស់ នៅពេលប្រើលើកដំបូង
- ដាក់ឯកសារយោងនៃប្រភពទិន្នន័យជានិច្ច
- ស្នើសុំឱ្យមិត្តរួមការងារ ឬមិត្តភក្តិដែលមិនមែនជាអ្នកបច្ចេកទេសពិនិត្យអត្ថបទរបស់អ្នក

## គន្លឹះសម្រាប់ការរៀបចំការផ្សព្វផ្សាយការស្រាវជ្រាវ

- មនុស្សមិនសូវអានទេ  ពួកគេគ្រាន់តែអានរំលងៗ
- ដាក់ចំណុចសំខាន់ជាងគេនៅខាងដើម ("BLUF")
- ធ្វើឱ្យការរកឃើញនៃការស្រាវជ្រាវមានភាពពាក់ព័ន្ធទៅនឹងភាគីពាក់ព័ន្ធនានា
- ធានាថាសារសំខាន់ៗមានភាពលេចធ្លោ (ប្រើអក្សរដិត ប្រើសញ្ញាចំណុច ។ល។)
- ចែករំលែកការស្រាវជ្រាវរបស់អ្នក នៅកន្លែងដែលមានអ្នកអាន/អ្នកស្តាប់របស់អ្នកកំពុងទទួលព័ត៌មានស្រាប់។ ជ្រើសរើសទម្រង់ និងបណ្តាញផ្សព្វផ្សាយសមស្របផ្អែកលើអ្នកអាន/អ្នកស្តាប់គោលដៅរបស់អ្នក។ (ឧទាហរណ៍ សង្ខេបគោលនយោបាយ ១ ទៅ២ ទំព័រសម្រាប់អ្នករៀបចំគោលនយោបាយ ការសន្ទនាសហគមន៍ សម្រាប់អ្នកចូលរួមក្នុងការស្រាវជ្រាវ និងទិនានុប្បវត្តិ និងសិក្ខាសាលាតាមអនឡាញសម្រាប់អ្នកសិក្សាស្រាវជ្រាវ)
- ធានាថាអ្នកអាន/អ្នកស្តាប់របស់អ្នកដឹងពីរបៀបតាមដានបន្ត/អ្នកដែលត្រូវទំនាក់ទំនង
- បកប្រែលទ្ធផលស្រាវជ្រាវទៅជាភាសាក្នុងស្រុកដែលពាក់ព័ន្ធ

## ការធ្វើការជាមួយភាគីពាក់ព័ន្ធចម្រុះ

បញ្ចូលអ្នកឆ្លើយសំណួរទាំងអស់ រួមទាំងក្រុមដែលត្រូវបានផាត់ចេញ ឬក្រុមដែលមិនសូវមានតំណាងនៅក្នុងព្រឹត្តិការណ៍ផ្សព្វផ្សាយ ការពិភាក្សា និងវេទិកានានា។ ចែករំលែកលទ្ធផលស្រាវជ្រាវក្នុងទម្រង់ដែលងាយស្រួលយល់ និងមានលក្ខណៈបរិយាបន្ន (ឧ. ជាភាសាក្នុងស្រុក និងតាមរយៈការប្រើប្រាស់សំឡេង/វីដេអូ)។



# ៩. ការតាមដាននិងវាយតម្លៃផលជះនៃការស្រាវជ្រាវ

ការយល់ដឹង និងការមានផែនការត្រឹមត្រូវ ដើម្បីតាមដាន និងវាយតម្លៃផលប៉ះពាល់នៃការស្រាវជ្រាវតាំងពីពេលចាប់ផ្ដើមនៃកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវណាមួយ គឺជារឿងសំខាន់ ដើម្បីធានាឱ្យមានការរៀបចំផែនការសមស្រប រួមជាមួយការបែងចែកធនធាន ការតាមដានវឌ្ឍនភាពនិងសមិទ្ធផល ក្នុងលក្ខណៈជាប្រព័ន្ធ និងការរៀនសូត្រពីការស្រាវជ្រាវ។

| ការតាមដានការស្រាវជ្រាវគោលនយោបាយ | |
|---|---|
| **វត្ថុបំណង** | ដើម្បីវាយតម្លៃជាបន្តបន្ទាប់លើគុណភាព និងការប្រើប្រាស់លទ្ធផលស្រាវជ្រាវ |
| **លក្ខណៈវិនិច្ឆ័យ** | ១. **គុណភាព៖** តើការស្រាវជ្រាវបានបំពេញតាមស្តង់ដារគុណភាព ដូចជាសុពលភាព ភាពអាចជឿទុកចិត្តបាន ភាពជាក់លាក់ សុចរិតភាព និងភាពទាន់ពេលវេលាដែរឬទេ?<br>២. **ការទៅដល់៖** តើការស្រាវជ្រាវត្រូវបានចែករំលែក ឬចូលមើលដោយអ្នកអាន/អ្នកស្ដាប់គោលដៅរបស់ខ្លួនហើយឬនៅ? |
| **វិធីសាស្ត្រ** | ការតាមដានការដកស្រង់ជាឯកសារយោង ការតាមដានចំនួនអ្នកមើល និងទាញយកការបោះពុម្ពផ្សាយ ការត្រួតពិនិត្យការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយ មតិត្រឡប់ពីអ្នកអាន/អ្នកស្ដាប់ |
| **ពេលវេលា** | ធ្វើឡើង នៅគ្រប់ដំណាក់កាលនៃការស្រាវជ្រាវ រួមទាំងការប្រមូលទិន្នន័យ ការព្រាងរបាយការណ៍ និងការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ |
| **ការប្រើប្រាស់ការរកឃើញនៃការស្រាវជ្រាវ** | បង្កើនគុណភាពស្រាវជ្រាវ កែលម្អយុទ្ធសាស្ត្រចូលរួម ពង្រីកវិសាលភាពនៃការផ្សព្វផ្សាយនិងផ្ដល់ព័ត៌មានសម្រាប់រៀបចំគម្រោងការស្រាវជ្រាវនាពេលអនាគត |



ខណៈដែលទាំងការតាមដាន ទាំងការវាយតម្លៃ សុទ្ធតែធ្វើការវាយតម្លៃលើលទ្ធផលនៃការស្រាវជ្រាវ ការតាមដាន និងការវាយតម្លៃបម្រើគោលបំណងផ្សេងគ្នា ប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នា និងត្រូវបានអនុវត្តនៅដំណាក់កាលផ្សេងៗគ្នា។ តារាងខាងក្រោមបង្ហាញពីទិដ្ឋភាពផ្សេងៗគ្នានៃការតាមដាន និងការវាយតម្លៃលើការស្រាវជ្រាវគោលនយោបាយ។

| ការវាយតម្លៃការស្រាវជ្រាវគោលនយោបាយ |
|---|
| ដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅអំពីរបៀប និងមូលហេតុដែលការស្រាវជ្រាវបាន ឬមិនបាននាំទៅរកឥទ្ធិពលលើគោលនយោបាយ ឬការផ្លាស់ប្តូរគោលនយោបាយ |
| ១.ភាពពាក់ព័ន្ធ៖ តើការស្រាវជ្រាវបានដោះស្រាយបញ្ហាដែលពាក់ព័ន្ធដែរឬទេ?<br>២.ស័ក្តិសិទ្ធភាព៖ តើការស្រាវជ្រាវបានសម្រេចវត្ថុបំណងរបស់ខ្លួនដែរឬទេ?<br>៣.ផលប៉ះពាល់៖ តើការស្រាវជ្រាវបានបង្កើតឱ្យមានភាពខុសប្លែកអ្វីខ្លះ? តើមានការផ្លាស់ប្តូរអ្វីខ្លះជាលទ្ធផលនៃការស្រាវជ្រាវនេះ?<br>៤.ប្រសិទ្ធភាព៖ តើការស្រាវជ្រាវត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាពចំណាយដែរឬទេ? |
| ការប្រមូលព័ត៌មានអំពីលទ្ធផល ការវិភាគការរួមចំណែក ការតាមដានដំណើរការ ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងករណីសិក្សា |
| ភាគច្រើនធ្វើឡើងបន្ទាប់ពីការបោះពុម្ពផ្សាយ និងការរៀបចំព្រឹត្តិការណ៍ ផ្សព្វផ្សាយការរកឃើញនៃការស្រាវជ្រាវរួច |
| កំណត់ និងបង្ហាញឱ្យឃើញពីភាពពាក់ព័ន្ធនឹងគោលនយោបាយ និងកែលម្អការស្រាវជ្រាវគោលនយោបាយនាពេលអនាគត |

# ១០. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ក៖ ស្តង់ដារគុណភាពនៃការស្រាវជ្រាវ

| ដំណាក់កាលស្រាវជ្រាវ | ស្តង់ដារសំរីទ្ធ (មូលដ្ឋាន) |
|---|---|
| រៀបចំគ្រោងការស្រាវជ្រាវ | • ចំណោទបញ្ហានៃការស្រាវជ្រាវត្រូវបានកំណត់ – សំណួរស្រាវជ្រាវច្បាស់លាស់ ប៉ុន្តែ វិសាលភាពអាចនៅមានកម្រិត<br>• ការពិនិត្យលើឯកសារពាក់ព័ន្ធមានកម្រិត<br>• មានការពិពណ៌នាអំពីវិធីសាស្ត្រ ប៉ុន្តែខ្វះព័ត៌មានលម្អិតស៊ីជម្រៅ<br>• ការជ្រើសរើសសំណាកផ្អែកលើភាពងាយស្រួល ឬតាមស្ថានភាពជាក់ស្តែង |
| ធានាថាការស្រាវជ្រាវអនុវត្តតាមគោលការណ៍ណែនាំអំពីក្រមសីលធម៌ | • ស្វែងរកការយល់ព្រមដោយផ្ទាល់មាត់<br>• ការយល់ដឹងទូទៅអំពីការស្រាវជ្រាវ ដែលគោរពតាមក្រមសីលធម៌ |
| ប្រមូលទិន្នន័យ | • ការធ្វើតេស្តសាកល្បង ដើម្បីសម្រិតសម្រាំងឧបករណ៍នៅមានកម្រិត<br>• អាចប្រើប្រាស់ឧបករណ៍ដែលមានស្រាប់ ដោយមានការកែសម្រួលតិចតួច ទៅតាមបរិបទស្រាវជ្រាវ<br>• ការត្រួតពិនិត្យគុណភាពទិន្នន័យ ធ្វើឡើងទៅតាមស្ថានភាពជាក់ស្តែង ដោយគ្មានផែនការត្រឹមត្រូវ |

## ឯកសារយោង

- Research Quality Plus (RQ+) វិធីសាស្ត្ររួមក្នុងការវាយតម្លៃការស្រាវជ្រាវ៖ https://idl-bnc-idrc.dspacedirect.org/server/api/core/bitstreams/26d17914-e289-467a-b45e-2e139085156c/content
- ឧបករណ៍វាយតម្លៃ Research Quality Plus (RQ+)៖ https://idrc-crdi.ca/sites/default/files/sp/Documents%20EN/idrc_rq_assessment_instrument_september_2017.pdf

| ស្តង់ដារប្រាក់ (ល្អ) | ស្តង់ដារមាស (គុណភាពខ្ពស់ និងមានលក្ខណៈបរិយាបន្ន) |
|---|---|
| • សំណួរ និងវត្ថុបំណងនៃការស្រាវជ្រាវមានភាពច្បាស់លាស់ ផ្អែកលើឯកសារពាក់ព័ន្ធ<br>• វិធីសាស្ត្រ និងឧបករណ៍ សមស្របសម្រាប់គ្រោងការស្រាវជ្រាវមានការពន្យល់ពីការរៀបចំឧបករណ៍ និងផែនការវិភាគ<br>• យុទ្ធសាស្ត្រជ្រើសរើសសំណាកត្រូវបានពន្យល់ច្បាស់លាស់ និងមានបញ្ចូលអ្នកចូលរួមចម្រុះ | • សំណួរ និងវត្ថុបំណងនៃការស្រាវជ្រាវមានភាពច្បាស់លាស់ដែលរៀបចំឡើងរួមគ្នា ដោយមានធាតុចូលពីសហគមន៍គោលដៅ/អ្នកតាក់តែងគោលនយោបាយ<br>• សំណួររងត្រូវបានកំណត់<br>• ការពិនិត្យលើឯកសារពាក់ព័ន្ធមានភាពគ្រប់ជ្រុងជ្រោយ<br>• វិធីសាស្ត្រត្រូវបានរៀបចំតម្រូវតាមបរិបទ មានលក្ខណៈហ្មត់ចត់ និងផ្អែកលើទ្រឹស្តី និងឧត្តមានុវត្តន៍<br>• ប្រើប្រាស់យុទ្ធសាស្ត្រជ្រើសរើសសំណាកម៉ត់ចត់ (ឧ. ការជ្រើសរើសសំណាកដោយចៃដន្យតាមស្រទាប់), មានការពន្យល់ពីការគណនាសំណាក, មានយុទ្ធសាស្ត្រសម្រាប់ករណីមិនឆ្លើយតប, និងមានការពន្យល់ពីមូលហេតុនៃការជ្រើសរើសវិធីសាស្ត្រសំណាក |
| • ការយល់ព្រមត្រូវបានកត់ត្រាជាឯកសារ<br>• មានការវាយតម្លៃហានិភ័យ<br>• អនុវត្តតាមស្តង់ដារក្រុមសីលធម៌ក្នុងស្រុក | • ទទួលបានការពិនិត្យផ្នែកក្រុមសីលធម៌ជាផ្លូវការ (ពី IRB/NECHR)<br>• មានពិធីសារលម្អិត ដើម្បីទទួលបានការយល់ព្រម<br>• មានផែនការគ្រប់គ្រងទិន្នន័យ |
| • មានការធ្វើតេស្តសាកល្បង និងសម្រិតសម្រាំងឧបករណ៍ស្រាវជ្រាវ<br>• អ្នកប្រមូលទិន្នន័យចូលរួមវគ្គបណ្តុះបណ្តាលជាមូលដ្ឋានអំពីរបៀបប្រមូលទិន្នន័យឱ្យបានម៉ត់ចត់<br>• មានការត្រួតពិនិត្យគ្រប់គ្រងគុណភាពទិន្នន័យជាមូលដ្ឋាន | • ឧបករណ៍មានគុណភាពខ្ពស់ និងបានធ្វើតេស្តសាកល្បង<br>• អ្នកប្រមូលទិន្នន័យឆ្លងកាត់ការបណ្តុះបណ្តាលយ៉ាងហ្មត់ចត់<br>• មានការត្រួតពិនិត្យ និងតាមដានគុណភាពទិន្នន័យក្នុងលក្ខណៈជាប្រព័ន្ធ |

| | |
|---|---|
| **វិភាគទិន្នន័យ** | • ការវិភាគបែបពិពណ៌នាត្រឹមកម្រិតមូលដ្ឋាន<br>• ការយល់ដឹង ដើម្បីឆ្លើយតបនឹងសំណួរស្រាវជ្រាវនៅមានកម្រិត |
| **សរសេររបាយការណ៍ និងរៀបចំអនុសាសន៍** | • លទ្ធផលស្រាវជ្រាវត្រូវបានសរសេរឡើង ដោយមានការពិភាក្សា ឬពិចារណាតិចតួចពីបរិបទ<br>• អនុសាសន៍មានលក្ខណៈទូទៅ |
| **ការពិនិត្យកែសម្រួលដោយអ្នកជំនាញដូចគ្នា** | • ពិនិត្យដោយក្រុមការងារផ្ទៃក្នុងតែប៉ុណ្ណោះ |
| **ផ្សព្វផ្សាយលទ្ធផល** | • លទ្ធផលត្រូវបានចែករំលែកតែក្នុងក្រុមការងារផ្ទៃក្នុង ឬជាមួយម្ចាស់ជំនួយប៉ុណ្ណោះ |
| **ការតាមដាន និងវាយតម្លៃ** | • សកម្មភាពតាមដានមានតិចតួចបំផុត ឬមានកម្រិត<br>• ខ្វះផែនការតាមដាន<br>• គ្មានការកំណត់សូចនាករទុកជាមុន<br>• គ្មានផែនការវាយតម្លៃច្បាស់លាស់ ឬជាក់លាក់ |

| | |
|---|---|
| • ការវិភាគស្របតាមគ្រោងការស្រាវជ្រាវ<br>• មានការផ្ទៀងផ្ទាត់ទិន្នន័យ និងការបញ្ជាក់សុពលភាពខ្លះៗ | • បច្ចេកទេសវិភាគហ្មត់ចត់<br>• ការផ្ទៀងផ្ទាត់ទិន្នន័យពេញលេញ<br>• លទ្ធផលត្រូវបានបញ្ជាក់ផ្ទៀងផ្ទាត់ជាមួយធាតុចូលពីសហគមន៍/ភាគីពាក់ព័ន្ធ<br>• មានការពន្យល់ច្បាស់លាស់អំពីការសន្មត និងដែនកំណត់ |
| • របាយការណ៍ រួមមាន ការរកឃើញនៃការស្រាវជ្រាវ ដែនកំណត់ និងភាពពាក់ព័ន្ធ<br>• មានការតម្រូវខ្លះៗទៅតាមអ្នកអាន/អ្នកស្តាប់គោលដៅ | • របាយការណ៍មានភាពច្បាស់លាស់ មានភាពពាក់ព័ន្ធនឹងគោលនយោបាយ និងបញ្ចូលអនុសាសន៍ស៊ីជម្រៅ<br>• ត្រូវបានកែសម្រួលស្របតាមអ្នកអាន/អ្នកស្តាប់គោលដៅ ជាមួយនឹងសារច្បាស់លាស់ |
| • ពិនិត្យដោយសហការី ឬដៃគូខាងក្រៅ | • ដំណើរការពិនិត្យដោយអ្នកជំនាញដូចគ្នាជាផ្លូវការ (ឧ. គណៈអ្នកជំនាញ ឬទិនានុប្បវត្តិ), ការកែសម្រួលត្រូវបានកត់ត្រាច្បាស់លាស់ |
| • ការផ្សព្វផ្សាយទៅកាន់បណ្តាញ និងភាគីពាក់ព័ន្ធ<br>• មានការធ្វើបទបង្ហាញ ឬកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលសង្ខេប | • មានយុទ្ធសាស្ត្រផ្សព្វផ្សាយច្បាស់លាស់<br>• មានការអនុវត្តផែនការផ្សព្វផ្សាយជាសាធារណៈ<br>• លទ្ធផលស្រាវជ្រាវត្រូវបានចែករំលែកជាមួយសហគមន៍ និងអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងទម្រង់ងាយស្រួលយល់<br>• មានផែនការសកម្មភាពតាមដាន ដើម្បីបង្កើនលទ្ធភាពនៃការយកលទ្ធផលស្រាវជ្រាវទៅប្រើប្រាស់ |
| • មានផែនការតាមដានកម្រិតមូលដ្ឋាន ដែលផ្តល់ការតម្រង់ទិសអំពីសកម្មភាពតាមដាន<br>• មានសូចនាករដែលបានកំណត់ទុកជាមុន<br>• អាចមានការចងក្រងឯកសារអំពីមេរៀននានា ប៉ុន្តែមិនត្រូវបានអនុវត្តតាមប្រធានបទ | • មានផែនការតាមដានគ្រប់ជ្រុងជ្រោយតាំងពីដំបូង<br>• សូចនាករស្របតាមវត្ថុបំណងនៃការស្រាវជ្រាវ និងមានការតាមដានជាប្រចាំ<br>• ផែនការវាយតម្លៃត្រូវបានកំណត់ទុកជាមុន និងត្រូវបានអនុវត្ត។<br>• វត្ថុបំណងនៃការរៀនសូត្រត្រូវបានកំណត់ ហើយមេរៀន និងបទពិសោធនានាត្រូវបានប្រើប្រាស់ដើម្បីធ្វើការកែសម្រួល<br>• លទ្ធផលស្រាវជ្រាវត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ជាព័ត៌មានសម្រាប់ការស្រាវជ្រាវនាពេលអនាគត |

# ឧបសម្ព័ន្ធ ខ៖ បញ្ជីត្រួតពិនិត្យការវាយតម្លៃគុណភាពស្រាវជ្រាវ

អ្នកស្រាវជ្រាវអាចប្រើបញ្ជីខាងក្រោម ដើម្បីវាយតម្លៃនិងវាស់វែងគុណភាពនៃការស្រាវជ្រាវរបស់ពួកគេ។

| | សំណួរគន្លឹះ | បាទ/ចាស | ទេ | បានខ្លះ | មិនពាក់ព័ន្ធ |
|---|---|---|---|---|---|
| | **គ្រោងការស្រាវជ្រាវ** | | | | |
| ១. | តើមានការកំណត់ប្រធានបទស្រាវជ្រាវច្បាស់លាស់ដែរឬទេ? តើវត្ថុបំណង និងសម្មតិកម្មមានភាពច្បាស់លាស់ដែរឬទេ? | ○ | ○ | ○ | ○ |
| ២. | តើសំណួរស្រាវជ្រាវ ស្របនឹងវត្ថុបំណងនៃការស្រាវជ្រាវដែរឬទេ? | ○ | ○ | ○ | ○ |
| ៣. | តើការស្រាវជ្រាវមានក្របខ័ណ្ឌទ្រឹស្តី ដែលត្រូវបានរៀបរាប់យ៉ាងច្បាស់លាស់ដែរឬទេ? | ○ | ○ | ○ | ○ |
| ៤. | តើគ្រោងការស្រាវជ្រាវ សមស្របទៅនឹងសំណួរ និងប្រភពទិន្នន័យដែរឬទេ? | ○ | ○ | ○ | ○ |
| ៥. | តើមានការឡើងវិញឯកសារពាក់ព័ន្ធយ៉ាងហ្មត់ចត់ដែរឬទេ? | ○ | ○ | ○ | ○ |
| ៦. | តើមានការពិភាក្សាច្បាស់លាស់អំពីដែនកំណត់ និងភាពលម្អៀងដែលអាចកើតមានដែរឬទេ? | ○ | ○ | ○ | ○ |
| ៧. | តើមានការពិនិត្យផ្នែកក្រមសីលធម៌ ឬទទួលបានការយល់ព្រមពីស្ថាប័នដែរឬទេ? | ○ | ○ | ○ | ○ |
| ៨. | តើមានការចាត់ចែងសុំការយល់ព្រមពីអ្នកចូលរួម ការពារឯកជនភាព និងទិន្នន័យ បានគ្រប់គ្រាន់ដែរឬទេ? | ○ | ○ | ○ | ○ |
| ៩. | តើមានផែនការគ្រប់គ្រងទិន្នន័យ ដើម្បីគ្រប់គ្រងការប្រមូល ការរក្សាទុក ការដំណើរការ និងការថែរក្សាទិន្នន័យដែរឬទេ? | ○ | ○ | ○ | ○ |

## ការពិនិត្យលើឯកសារពាក់ព័ន្ធ

១០. តើការពិនិត្យលើឯកសារពាក់ព័ន្ធធ្វើឡើងយ៉ាងហ្មត់ចត់ដែរឬទេ ?

១១. តើការពិនិត្យលើឯកសារពាក់ព័ន្ធបង្ហាញពីចន្លោះប្រហោងនៃការស្រាវជ្រាវ និងសារសំខាន់នៃការសិក្សានេះដែរឬទេ ?

១២. តើមានការដកស្រង់ព័ត៌មានពីប្រភពឯកសារអាចជឿទុកចិត្តបាន ត្រឹមត្រូវដែរឬទេ ?

## ការប្រមូលទិន្នន័យ

១៣. តើប្រភពទិន្នន័យមានភាពពាក់ព័ន្ធ និងគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងសំណួរស្រាវជ្រាវដែរឬទេ ?

១៤. តើវិធីសាស្ត្រប្រមូលទិន្នន័យត្រូវបានពិពណ៌នាច្បាស់លាស់ និងអាចអនុវត្តតាមបានដែរឬទេ ?

១៥. តើទិន្នន័យមានគុណភាពខ្ពស់ (អាចជឿទុកចិត្តបាន មានសុពលភាព ពាក់ព័ន្ធ និងត្រឹមត្រូវ) ដែរឬទេ ?

## ការវិភាគទិន្នន័យ

១៦. តើការវិភាគទិន្នន័យបញ្ចូលទាំងលទ្ធផលអំពីសារសំខាន់ផ្នែកស្ថិតិ (statistical significance) និងទំហំឥទ្ធិពល (effect sizes) (សម្រាប់ការសិក្សាបែបបរិមាណវិស័យ) ដែរឬទេ ?

១៧. តើវិធីសាស្ត្រវិភាគមានភាពសមស្រប និងត្រូវបានអនុវត្តយ៉ាងហ្មត់ចត់ដែរឬទេ ? តើការរកឃើញនៃការស្រាវជ្រាវមានទិន្នន័យសម្រាប់បញ្ជាក់ផ្ទៀងផ្ទាត់ដែរឬទេ ?

## ការសរសេររបាយការណ៍

១៨. តើការសិក្សានេះត្រូវបានសរសេរឡើង តាមរបៀបដែលបញ្ជាក់ច្បាស់អំពីគោលនយោបាយ ឬការអនុវត្តការងារអភិវឌ្ឍន៍ ដែលមានភាពស្មុគស្មាញដែរឬទេ ?

| | | | | | |
|---|---|---|---|---|---|
| ១៩. | តើតារាង និងក្រាហ្វិកមានភាពច្បាស់លាស់ ត្រឹមត្រូវ និងអាចយល់បាន ជាមួយនឹងការដាក់ស្លាកតម្លៃទិន្នន័យសមស្របដែរឬទេ ? | ◯ | ◯ | ◯ | ◯ |
| ២០. | តើការស្រាវជ្រាវរួមបញ្ចូលឯកសារយោង (ការដកស្រង់) ដែលអាចជឿទុកចិត្តបានគ្រប់គ្រាន់ដែរឬទេ ? | ◯ | ◯ | ◯ | ◯ |

## ការត្រួតពិនិត្យដោយអ្នកជំនាញដូចគ្នា និងការគ្រប់គ្រងគុណភាព

| | | | | | |
|---|---|---|---|---|---|
| ២១. | តើមានដំណើរការត្រួតពិនិត្យដោយអ្នកជំនាញដូចគ្នា ដើម្បីធានាគុណភាពខ្លឹមសារ និងដោយអ្នកពិនិត្យកែសម្រួល (editors) ដើម្បីធានាថាមានការប្រើប្រាស់ភាសាងាយយល់ដែរឬទេ ? | ◯ | ◯ | ◯ | ◯ |

## ការផ្សព្វផ្សាយ

| | | | | | |
|---|---|---|---|---|---|
| ២២. | តើការរកឃើញនៃការស្រាវជ្រាវពាក់ព័ន្ធនឹងការជជែកដេញដោលអំពីគោលនយោបាយ ឬដំណើរការធ្វើសេចក្តីសម្រេចចិត្តបច្ចុប្បន្នដែរឬទេ ? | ◯ | ◯ | ◯ | ◯ |
| ២៣.. | តើការស្រាវជ្រាវបានបញ្ចូលអនុសាសន៍ ដែល អ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្តការងារ អាចយកទៅអនុវត្តបានដែរឬទេ ? | ◯ | ◯ | ◯ | ◯ |
| ២៤. | តើមានការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយ ឬជម្រុញការទទួលយកការរកឃើញនៃការស្រាវជ្រាវដែរឬទេ ? | ◯ | ◯ | ◯ | ◯ |

## ការតាមដាន និងវាយតម្លៃ

| | | | | | |
|---|---|---|---|---|---|
| ២៥. | តើមានសូចនាករ ឬយន្តការ ដើម្បីវាយតម្លៃការទទួលយក ឬឥទ្ធិពលនៃការស្រាវជ្រាវដែរឬទេ ? | ◯ | ◯ | ◯ | ◯ |
| ២៦. | តើមានផែនការតាមដាន ឬប្រព័ន្ធ ដើម្បីត្រួតពិនិត្យលទ្ធផលរយៈពេលវែង ដែលកើតចេញពីការអនុសាសន៍ស្រាវជ្រាវដែរឬទេ ? | ◯ | ◯ | ◯ | ◯ |

# ឧបសម្ព័ន្ធ គ៖ បញ្ជីត្រួតពិនិត្យសម្រាប់ការពិភាក្សាក្រុមគោលដៅប្រកបដោយបរិយាបន្ន

| សំណួរគន្លឹះ | បាទ/ចាស | ទេ | បានខ្លះ | មិនពាក់ព័ន្ធ |
|---|---|---|---|---|
| **ការជ្រើសរើសអ្នកចូលរួម** | | | | |
| តើអ្នកបានបញ្ចូលអ្នកចូលរួមចម្រុះ (ឧ. ស្ត្រី ជនមានពិការភាព ជនជាតិភាគតិច យុវជន) ដែរឬទេ? | | | | |
| តើអ្នកបានពិចារណា ថាតើក្រុមមួយចំនួននឹងមានអារម្មណ៍ស្រួលជាង ប្រសិនបើពួកគេបានក្នុងការពិភាក្សាក្រុមគោលដៅដាច់ដោយឡែកពីគ្នាដែរឬទេ? | | | | |
| **ទីតាំង និងការរៀបចំ** | | | | |
| តើទីតាំងផ្ដល់ផាសុកសមរម្យ ឬបង្កភាពងាយស្រួលក្នុងការចេញចូលសម្រាប់អ្នកចូលរួមទាំងអស់ដែរឬទេ? | | | | |
| តើទីកន្លែងមានសុវត្ថិភាព ងាយស្រួលរក និងមានផាសុកភាពដែរឬទេ? | | | | |
| តើអ្នកបានរៀបចំការធ្វើដំណើរ ការមើលថែក្មេង ឬអាហារសម្រន់ ប្រសិនបើចាំបាច់ដែរឬទេ? | | | | |
| **ភាសា និងការប្រាស្រ័យទាក់ទង** | | | | |
| តើឯកសារ និងសំណួរនានាត្រូវបានសរសេរជាភាសាសាមញ្ញ និងច្បាស់លាស់ដែរឬទេ? | | | | |
| តើអ្នកបានរៀបចំការបកប្រែឯកសារ ឬការបកប្រែផ្ទាល់មាត់ក្នុងករណីចាំបាច់ដែរឬទេ? | | | | |
| **ការសម្របសម្រួល** | | | | |
| តើអ្នក និងអ្នកសម្របសម្រួលផ្សេងទៀតបានទទួលការបណ្ដុះបណ្ដាលអំពីការសម្របសម្រួលប្រកបដោយបរិយាបន្ននិងការគោរពដែរឬទេ? | | | | |
| តើអ្នក និងអ្នកសម្របសម្រួលផ្សេងទៀតបានត្រៀមខ្លួនរួចជាស្រេចដើម្បីគ្រប់គ្រង អំណាចគ្របដណ្ដប់ និងធានាឱ្យមានការចូលរួមដោយស្មើភាពដែរឬទេ? | | | | |
| តើមានផែនការលើកទឹកចិត្តអ្នកចូលរួមដែលមិនសូវនិយាយឱ្យមានមតិដែរឬទេ? | | | | |

ឧបសម្ព័ន្ធ គ

## បរិយាកាស និងសុវត្ថិភាព

| | | | | |
|---|---|---|---|---|
| តើអ្នកបានបង្កើតបរិយាកាសសុវត្ថិភាព និងមិនមានការរើសអើង ដែលអ្នកចូលរួមអាចចែករំលែកមិតិដោយបើកចំហដែរឬទេ ? | ◯ | ◯ | ◯ | ◯ |
| តើមានការកំណត់គោលការណ៍មូលដ្ឋាន ដើម្បីជំរុញការសន្ទនាប្រកបដោយការគោរពដែរឬទេ ? | ◯ | ◯ | ◯ | ◯ |

## ការពិចារណាផ្នែកសីលធម៌

| | | | | |
|---|---|---|---|---|
| តើអ្នកបានទទួលការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ពីអ្នកចូលរួមទាំងអស់ដែរឬទេ ? | ◯ | ◯ | ◯ | ◯ |
| តើអ្នកមានផែនការការពារឯកជនភាព និងការសម្ងាត់របស់អ្នកចូលរួមដែរឬទេ ? | ◯ | ◯ | ◯ | ◯ |

# ឧបសម្ព័ន្ធ ឃ៖ បញ្ជីត្រួតពិនិត្យសម្រាប់កិច្ចសម្ភាសន៍ប្រកបដោយបរិយាបន្ន

| សំណួរគន្លឹះ | បាទ/ចាស | ទេ | បានខ្លះ | មិនពាក់ព័ន្ធ |
|---|---|---|---|---|
| **ការជ្រើសរើសអ្នកចូលរួម** | | | | |
| តើអ្នកបានបញ្ចូលអ្នកចូលរួមចម្រុះ (ឧ. ស្ត្រី ជនមានពិការភាព ជនជាតិភាគតិច យុវជន) ដែរឬទេ? | ○ | ○ | ○ | ○ |
| តើអ្នកបានសុំឱ្យដៃគូ ឬបណ្តាញក្នុងមូលដ្ឋានជួយរក និងទាក់ទងទៅក្រុមដែលមិនសូវមានតំណាងដែរឬទេ? | ○ | ○ | ○ | ○ |
| **ទីតាំង និងការរៀបចំ** | | | | |
| តើទីតាំងអាចចូលទៅដល់បានដោយងាយស្រួលសម្រាប់អ្នកតបសម្ភាសន៍ដែរឬទេ? | ○ | ○ | ○ | ○ |
| តើអ្នកបានផ្តល់ជម្រើសអំពីរបៀបដែលកិច្ចសម្ភាសន៍នឹងត្រូវធ្វើដែរឬទេ (ដូចជាការជួបដោយផ្ទាល់ តាមទូរសព្ទ តាមអនឡាញ ឬការចុះទៅដល់ផ្ទះ)? | ○ | ○ | ○ | ○ |
| តើទីកន្លែងមានសុវត្ថិភាព ងាយស្រួលរក និងមានផាសុកភាពដែរឬទេ? | ○ | ○ | ○ | ○ |
| តើអ្នកបានរៀបចំការធ្វើដំណើរ ការមើលថែក្មេង ឬអាហារសម្រន់ ប្រសិនបើចាំបាច់ដែរឬទេ? | ○ | ○ | ○ | ○ |
| **ភាសា និងការប្រាស្រ័យទាក់ទង** | | | | |
| តើកិច្ចសម្ភាសន៍នឹងធ្វើឡើងដោយប្រើភាសាដែលអ្នកចូលរួមចង់ប្រើ ឬភាសាដែលផ្តល់ភាពងាយស្រួលបំផុតដល់ពួកគេដែរឬទេ? | ○ | ○ | ○ | ○ |
| តើអ្នកបានរៀបចំការបកប្រែឯកសារ ឬការបកប្រែផ្ទាល់មាត់ក្នុងករណីចាំបាច់ដែរឬទេ? | ○ | ○ | ○ | ○ |
| តើអ្នកបានបកប្រែមគ្គុទ្ទេសក៍សម្ភាសន៍ និងទម្រង់សុំការយល់ព្រម បានយ៉ាងច្បាស់លាស់ និងត្រឹមត្រូវ ដោយជៀសវាងការប្រើប្រាស់ពាក្យបច្ចេកទេស ឬពាក្យពេចន៍ដែលនាំឱ្យមានការភាន់ច្រឡំដែរឬទេ? | ○ | ○ | ○ | ○ |

## ទំនាក់ទំនងអំណាច

| | | | | |
|---|---|---|---|---|
| តើអ្នកបានទុកពេលវេលា ដើម្បីបង្កើតភាពស្និទ្ធស្នាល មុនពេលចាប់ផ្តើមសួរសំណួរផ្លូវការដែរឬទេ ? | ○ | ○ | ○ | ○ |
| តើសំណួររបស់អ្នកប្រកបដោយការគោរព មិនមានលក្ខណៈវិនិច្ឆ័យ និងត្រូវបានរៀបចំឡើងក្នុងន័យផ្តល់តម្លៃដល់ចំណេះដឹងរបស់អ្នកចូលរួមដែរឬទេ ? | ○ | ○ | ○ | ○ |
| តើកិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងនៅកន្លែងដែលមានសុវត្ថិភាព អាចរក្សាឯកជនភាព ដែលអ្នកចូលរួមអាចនិយាយដោយសេរីបានដែរឬទេ ? | ○ | ○ | ○ | ○ |

## ការពិចារណាផ្នែកក្រមសីលធម៌

| | | | | |
|---|---|---|---|---|
| តើអ្នកបានទទួលការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ហើយឬនៅ ? | ○ | ○ | ○ | ○ |
| តើអ្នកមានផែនការ ដើម្បីការពារភាពឯកជន និងការសម្ងាត់ដែរឬទេ ? | ○ | ○ | ○ | ○ |

# ឧបសម្ព័ន្ធ ខ៖ បញ្ជីត្រួតពិនិត្យការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់របស់អង្គការមូលនិធិអាស៊ី (ភាសាខ្មែរ)

**បញ្ជីពិនិត្យសម្រាប់ «ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ - Informed Consent»**
នៅពេលព្រាង ឬពិនិត្យឯកសារ«ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ - Informed Consent» អ្នកត្រូវប្រាកដថាពាក្យពេចន៍ក្នុងឯកសារ ឆ្លើយតបនឹងចំណុចខាងក្រោម៖

**○ តើទិន្នន័យ ឬព័ត៌មានអ្វីខ្លះដែលនឹងត្រូវបានប្រមូល ?**

តើអ្នកកំពុងប្រមូលទិន្នន័យផ្ទាល់ខ្លួន ឬព័ត៌មានរសើប ដែរឬទេ ?សូមពន្យល់ឱ្យបានច្បាស់លាស់ អំពីប្រភេទទិន្នន័យដែលអ្នកនឹងប្រមូល។

**○ តើទិន្នន័យនឹងត្រូវបានចែករំលែកជាមួយនរណាខ្លះ ?**

សូមសរសេរបញ្ជាក់អំពីសមាសភាពភាគីដែលអ្នកមានគម្រោងនឹងចែករំលែកទិន្នន័យជាមួយ។ តើអ្នកមានកាតព្វកិច្ចក្នុងការចែករំលែកទិន្នន័យជាមួយរដ្ឋាភិបាល ឬម្ចាស់ជំនួយដែរឬទេ ? តើទិន្នន័យអ្វីខ្លះដែលនឹងត្រូវបានចែករំលែក ?

**○ តើអ្នកណាកំពុងប្រមូលទិន្នន័យ ?**

សូមបង្ហាញភាពស្មោះត្រង់ អំពីអ្នកដែលកំពុងប្រមូល ទិន្នន័យ។ រួមមាន អង្គការមូលនិធិអាស៊ី ឬ/និងដៃគូណាមួយដែលពាក់ព័ន្ធ និងប្រហែលជាម្ចាស់ជំនួយផងដែរ។

**○ តើទិន្នន័យផ្ទាល់ខ្លួន ឬ ទិន្នន័យរសើបនឹងត្រូវបានរក្សាទុកយូរប៉ុណ្ណា ?**

សូមកត់សម្គាល់ថាតើអ្នកមានគម្រោង រក្សាទុកទិន្នន័យផ្ទាល់ខ្លួន ឬរសើបណាមួយក្នុងរយៈពេលយូរប៉ុណ្ណា។ តើទិន្នន័យ នឹងត្រូវបានប្រមូល បូកសរុប និងរក្សាទុកដោយមិនបញ្ចេញឈ្មោះដែរឬទេ ?

**○ តើទិន្នន័យត្រូវបានប្រមូលដោយរបៀបណា ?**

សូមពន្យល់អំពីវិធីសាស្ត្រនៃការប្រមូលទិន្នន័យ។ តើការប្រមូលទិន្នន័យប្រើប្រាស់ក្រដាស ឬតាមឧបករណ៍ឌីជីថល ឬប្រើប្រាស់កម្មវិធីទូរស័ព្ទ ឬតាមការសន្ទនាតាមទូរស័ព្ទ ឬក៏តាមកម្មវិធីបណ្ដាញសង្គម ?

**○ តើសិទ្ធិទាក់ទងនឹងទិន្នន័យរបស់សហគមន៍ និងបុគ្គលមានអ្វីខ្លះ ?**

សូមផ្ដល់នូវការពន្យល់ច្បាស់លាស់អំពី សិទ្ធិទិន្នន័យរបស់ប្រជាជន ដូចដែលបានចែងដោយច្បាប់ឯកជនភាព ( ឧ. GDPR ច្បាប់ឯកជនភាពជាតិ ឬច្បាប់ប្រចាំតំបន់ដែលពាក់ព័ន្ធ )។

| | |
|---|---|
| ○ **ហេតុអ្វីទិន្នន័យទាំងនេះត្រូវបានប្រមូល ?**<br><br>សូមកត់ត្រាមូលហេតុនៃការប្រមូលទិន្នន័យ និងអត្ថប្រយោជន៍សម្រាប់បុគ្គល ឬសហគមន៍។ | ○ **តើអ្នកផ្តល់កិច្ចសម្ភាស ឬផ្តល់ការឆ្លើយតបជាទិន្នន័យអាចទាក់ទងអ្នកណាដើម្បីស្វែងយល់ព័ត៌មានបន្ថែម ?**<br><br>សូមផ្តល់លេខទូរស័ព្ទ អាសយដ្ឋាន និងអ៊ីម៉ែល របស់អង្គការមូលនិធិអាស៊ី ឬដៃគូសហការណ៍ របស់យើងសម្រាប់សុំព័ត៌មានបន្ថែម។ |
| ○ **តើទិន្នន័យទាំងនោះនឹងត្រូវបានប្រើយ៉ាងដូចម្តេច ? និងប្រើប្រាស់ដោយអ្នកណា ?**<br><br>តើអ្នកណាជាអ្នកប្រើប្រាស់ទិន្នន័យទាំងនោះ ? តើ អង្គការមូលនិធិអាស៊ី អង្គការដៃគូ រាជរដ្ឋាភិបាល និងម្ចាស់ជំនួយនឹងប្រើប្រាស់ ទិន្នន័យទាំងនោះយ៉ាងដូចម្តេច ? | ○ **តើអ្នកផ្តល់កិច្ចសម្ភាស ឬផ្តល់ការឆ្លើយតបជាទិន្នន័យអាចផ្លាស់ប្តូរចិត្ត មិនផ្តល់កិច្ចសម្ភាសវិញ ដោយរបៀបណា ?**<br><br>អ្នកផ្តល់កិច្ចសម្ភាសផ្លាស់ប្តូរចិត្ត ឬបញ្ឈប់ ការយល់ព្រម( consent )ឬកែតម្រូវ ទិន្នន័យ របស់ពួកគេ ? |
| ○ **តើអ្វីទៅជាផលប៉ះពាល់អវិជ្ជមាន ?**<br><br>សូមរៀបរាប់អំពីផលជះអវិជ្ជមាន ដែលអាចមាន ចំពោះបុគ្គល ឬក្រុមណាមួយអំពីការបាត់បង់ ឯកជនភាព និងភាពសម្ងាត់បុគ្គល។ | ○ **តើអ្នកកំពុងធ្វើការជាមួយកុមារ និង មនុស្សវ័យជំទង់ដែរឬទេ ?**<br><br>សូមបញ្ចូលពាក្យពេចន៍ដែលអាចអោយមនុស្ស ពេញវ័យផ្តល់ការយល់ព្រម( consent )ជំនួស កុមារ និងមនុស្សវ័យជំទង់បាន ព្រមទាំង បន្ថែមនូវចំណុច ដែលមនុស្សវ័យជំទង់អាច ផ្តល់ ការយល់ព្រមដោយខ្លួនគេបាន។ តើភាសាដែល ប្រើប្រាស់អាចអោយមនុស្ស វ័យជំទង់ងាយយល់ដែរ ឬទេ ? |

# ឧបសម្ព័ន្ធ ចៈ គំរូការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់របស់អង្គការមូលនិធិអាស៊ី (ភាសាខ្មែរ)

## ឯកសារគំរូសម្រាប់ការស្នើសុំ «ការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់»

ជម្រាបសួរ

ខ្ញុំឈ្មោះ ____________ មកពី [ស្ថាប័នដែលទទួលខុសត្រូវលើការប្រមូលទិន្នន័យ] [ការពិពណ៌នាសង្ខេបអំពីសាវតាស្ថាប័ន]។ ក្នុងភាពជាដៃគូជាមួយអង្គការមូលនិធិអាស៊ី យើងកំពុងប្រមូលព័ត៌មាននិងទិន្នន័យក្នុងការ [គោលបំណងនៃការប្រមូលទិន្នន័យ]។

ការសិក្សាស្រាវជ្រាវនេះទទួលបានការគាំទ្រពី [ម្ចាស់ជំនួយ] ។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺសម្រាប់ [គោលបំណងនៃការប្រមូលទិន្នន័យ] ។

លោកអ្នកត្រូវបានជ្រើសរើសក្នុងការផ្តល់បទសម្ភាសផ្ទាល់/តាមទូរស័ព្ទ/បទសម្ភាសតាមអនឡាញនេះដោយចៃដន្យ។ យើងនឹងប្រមូលទិន្នន័យអំពីអ្នក។ [ទោះជាយ៉ាងណាក៏ដោយ] ក្នុងអំឡុងពេលសម្ភាសន៍នេះ ខ្ញុំនឹងសួរអ្នកអំពីព័ត៌មានផ្ទាល់ខ្លួនមួយចំនួនដូចជា........... ខ្ញុំក៏អាចនឹងសួរអំពី [ប្រធានបទរសើបខ្លះ] ផងដែរ។ កិច្ចសម្ភាសនឹងប្រើពេលប្រមាណ[ X ] នាទី។ ក្នុងកិច្ចសម្ភាស ឬការស្ទង់មតិនេះ អ្នកមានសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នក ហើយមតិទាំងនោះមិនត្រូវបានចាត់ទុកថាត្រឹមត្រូវ ឬ ខុសនោះឡើយ។ អ្នកអាចបញ្ចប់ការសម្ភាសនៅពេលណាក៏បាន។ ប្រសិនបើមានសំណួរដែលអ្នកមិនចង់ឆ្លើយ អ្នកមិនចាំបាច់ឆ្លើយនោះទេ។

[សូមពន្យល់អំពីវិធីប្រមូលទិន្នន័យ ការរក្សាទុកទិន្នន័យ និងភាគីពាក់ព័ន្ធដែលនឹងទទួលបានទិន្នន័យកទៅប្រើប្រាស់]។

ឧទាហរណ៍៖ ចម្លើយរបស់អ្នក នឹងត្រូវបានកត់ត្រានៅក្នុងកម្រងសំណួរលើឧបករណ៍ឌីជីថល ដូចជា ថេបប្លេត/ កុំព្យូទ័រ /ទូរស័ព្ទដៃទំនើប។ ចម្លើយរបស់អ្នក នឹងត្រូវបានរក្សាទុកនៅកន្លែងមានសុវត្ថិភាពមួយក្នុងរយៈពេល [ x ចំនួនពេលវេលា ]។ បន្ទាប់ពីរយៈពេលនោះ យើងនឹងលុបឈ្មោះរបស់អ្នកចេញពីកំណត់ត្រា ឬ បំផ្លាញកំណត់ត្រាណាមួយដែលអាចប្រើដើម្បីកំណត់អត្តសញ្ញាណរបស់អ្នក។ មានតែបុគ្គលិកដែលទទួលសិទ្ធិអនុញ្ញាតពី [ស្ថាប័នដៃគូ] និងអង្គការមូលនិធិអាស៊ីប៉ុណ្ណោះដែលនឹងអាចចូលពិនិត្យមើលទិន្នន័យ និងចម្លើយរបស់អ្នក។ យើងនឹងប្រើទិន្នន័យពីចម្លើយរបស់អ្នកដើម្បី [សូមពន្យល់ពីវិធីដែលទិន្នន័យនឹងត្រូវបានប្រើ]។

ឧបសម្ព័ន្ធ ៦

យើងនឹងមិនចែករំលែកឈ្មោះរបស់អ្នក នៅពេលយើងនិយាយ ឬពិភាក្សាអំពីការសិក្សាស្រាវជ្រាវនេះទេ ដូច្នេះចម្លើយផ្ទាល់របស់អ្នក នឹងនៅតែទទួលបានការរក្សាការសម្ងាត់ ។

បើសិនជាអ្នកចង់ឲ្យយើងដកឬលុបព័ត៌មានពីចម្លើយរបស់អ្នកចេញពីឯកសាររបស់យើង ឬអ្នកចង់ផ្លាស់ប្តូរព័ត៌មានពីចម្លើយរបស់អ្នក ឬអ្នកចង់សួរសំណួរបន្ថែមអំពីការសិក្សាស្រាវជ្រាវនេះ ឬបើសិនជាអ្នកមានមតិយោបល់ត្រឡប់ ឬបណ្តឹងណាមួយអំពីការសិក្សាស្រាវជ្រាវនេះ សូមទាក់ទងមកកាន់៖

[CONTACT NAME AND ADDRESS]: (សូមបញ្ចូល
អាសយដ្ឋានរបស់ការិយាល័យដៃគូ/អង្គការមូលនិធិអាស៊ី លេខទូរស័ព្ទ។ ប្រសិនបើមានពាក់ព័ន្ធ
សូមបញ្ចូល អាសយដ្ឋានអ៊ីម៉ែល ឈ្មោះអ្នកទំនាក់ទំនង។ ប្រសិនបើអាច សូមសូមផ្តល់
ព័ត៌មានសម្រាប់ទាក់ទងទូទៅ ក្នុងករណីមានការផ្លាស់ប្តូរបុគ្គលិក។

តើអ្នកយល់ព្រមចូលរួមផ្តល់កិច្ចសម្ភាសសម្រាប់ការសិក្សាស្រាវជ្រាវនេះដែរឬទេ ?

- ព្រម
- មិនព្រម

---

## ការយល់ព្រមរបស់មនុស្សវ័យជំទង់

ខ្ញុំបានយល់ពីព័ត៌មានខាងលើ ហើយខ្ញុំយល់ព្រមចូលរួម។ ព្រម/មិនព្រម

ខ្ញុំពេញចិត្តដោយអនុញ្ញាតឱ្យ [អង្គការដៃគូ] និង/ឬ អង្គការមូលនិធិអាស៊ី ទាក់ទងមកខ្ញុំ នៅពេលអនាគត បើគេត្រូវការ។ ព្រម/មិនព្រម

ឈ្មោះពេញ៖ ...........................................................

ហត្ថលេខា៖...............................................................

កាលបរិច្ឆេទ៖...........................................................

---

## ការយល់ព្រមពីឪពុកម្ដាយចំពោះកុមារ/មនុស្សវ័យជំទង់អាយុក្រោម១៨ឆ្នាំ

ខ្ញុំសូមបញ្ជាក់ថាខ្ញុំពិតជាឪពុក ម្ដាយ/អាណាព្យាបាល របស់.......................................

ខ្ញុំបានអាន និងយល់ព័ត៌មានខាងលើ ហើយអាចបញ្ជាក់ថាខ្ញុំយល់ព្រមឲ្យកូន/កុមាររបស់ខ្ញុំ ចូលរួមក្នុងការ [បញ្ជាក់ពីសកម្មភាព]។ ព្រម/មិនព្រម

ឈ្មោះពេញ៖ .........................................................

ហត្ថលេខា៖.............................................................

កាលបរិច្ឆេទ៖ .........................................................

លេខទូរស័ព្ទ និង/ឬអាសយដ្ឋាន៖...................................

# ឧបសម្ព័ន្ធ ច៖ គំរូការយល់ព្រមបន្ទាប់ពីប្រាបព័ត៌មានសព្វគ្រប់ របស់អង្គការមូលនិធិអាស៊ី ( ភាសាខ្មែរ )

## INFORMED CONSENT CHECKLIST

**When drafting of reviewing consent protocol, make sure the language answers:**

○ **What data or information is being collected?**
- Are you collecting personal or sensitive data? Explain in clear language exactly what kind of data is being collected.

○ **Who is collecting it?**
- Be transparent about who is collecting the data. Include TAF, any partners involved, and possibly the donor funding the data collection.

○ **How is it collected?**
- Explain how data is being collected. Is it on paper? Digital? Using an app? Over the phone? Through social media?

○ **Why is it being collected?**
- Note why data is being collected and any foreseeable benefits for the individual or community.

○ **How will it be used? by whom?**
- Who are the intended users of the data? How will the data be used by TAF, our partners, host governments, and donors?

○ **What are the potential negative effects?**
- Include a reasonable description of any potential harm to individuals or groups from loss of privacy and confidentiality.

○ **With whom will it be shared?**
- Include any and all parties with whom you plan to share the data. Are you contractually obligated to share data with the government or a donor? What types of data will be shared?

○ **How long will personal or sensitive data be retained?**
- Note how long you plan to store any personal or sensitive data. Will data be aggregated and retained anonymously?

○ **What are the individual's or community's rights related to their data?**

- Provide a clear explanation of people's data rights as outlined by relevant privacy laws (i.e., GDPR, national privacy laws, regional laws).

○ **Who can they contact for more information?**

- Provide a phone number, address, and possibly an email address where people can contact TAF or our partners for more information.

○ **How can they withdraw consent?**

- What is the process for revoking consent or correcting data that is held about an individual?

○ **Are you working with children and adolescents?**

- Include language for adults to consent for children and adolescents, and a place where adolescents can assent. Is the consent/assent language child friendly?

# ឧបសម្ព័ន្ធ ៥៖ គំរូការយល់ព្រមបន្ទាប់ពីប្រាប់ព័ត៌មានសព្វគ្រប់របស់អង្គការមូលនិធិអាស៊ី ( ភាសាអង់គ្លេស )

[local greeting],

I am ____________ from [organisation responsible for data collection], [brief description of the organisation]. In partnership, with The Asia Foundation, we are collecting information to [purpose of data collection]. This study is supported by funding from [donor(s)]. The objective of the study is [objective of the data collection]

You have been randomly selected for this face-to-face/phone/online interview. Data will be collected [however]. During this interview, I will ask you some personal information about…. I might also ask you to tell me about [sensitive topic]. The interview will take about [X] minutes. In this survey, you are free to express your opinion and there are no right or wrong answers. You can end the interview at any time, and if there are questions you prefer not to answer, that is fine.
[provide explanation for how data is collected, stored, and with whom it will be shared].

**Example:** Your responses will be recorded in a digital questionnaire on a tablet/laptop/smartphone. The responses will be stored in a secure place for [x amount of time]. After that time, we will either remove your name from the records or destroy any records that could be used to identify you. Only authorised staff from [partner] and The Asia Foundation will have access to your information and your responses. We will use your responses to [how the data will be used]. We will not share your name when we talk about this research, so your individual answers will remain confidential.

If you would like us to remove your information from our files, change the information that we hold about you, ask any questions about this research, or if you have complaints or feedback about the research process, please contact:

[CONTACT NAME AND ADDRESS: (physical address of partner office/TAF, phone number, if relevant, email address, name of contact person, if possible, but ensure that there is general information in case of staff turnover]

Do you agree to participate in the study by sitting for this interview?

- Yes
- No

---

## ADOLESCENT'S ASSENT

I have understood the above information and I agree to take part

Yes / No

I am happy for [partner org] and/or TAF to contact me in the future if they need to   Yes / No

Printed Name: ..............................................................

Signature: ....................................................................

Date:...............................................................................

---

## PARENTAL CONSENT FOR CHILDREN/ASOLESCENTS UNDER THE AGE OF 18

I confirm that I am the parent/guardian of....................................

I have read and understood the above information and confirm that   Yes / No   I consent for my child to take part in this [activity].

Printed Name: ..............................................................

Signature: ....................................................................

Date:...............................................................................

Phone Number and/or Address:.....................................

# ឧបសម្ព័ន្ធ ឈ៖ ឯកសារយោង


Bhattacherjee, Anol. *Social Science Research: Principles, Methods, and Practices.* Textbooks Collection, no. 3. Tampa: University of South Florida, 2012. https://digitalcommons.usf.edu/oa_textbooks/3.

International Development Research Centre (IDRC). *Research Quality Plus (RQ+) Assessment Instrument*. September 2017. https://idrc-crdi.ca/sites/default/files/sp/Documents%20EN/idrc_rq_assessment_instrument_september_2017.pdf

Colorado Department of Education. *Definitions and Characteristics of High Quality Research.*

International Development Research Centre (IDRC). *Research Quality Plus (RQ+): A Holistic Approach to Evaluating Research.* Ottawa: International Development Research Centre, 2017. https://idl-bnc-idrc.dspacedirect.org/server/api/core/bitstreams/26d17914-e289-467a-b45e-2e139085156c/content.

Judith Bell. Doing Your Research Project: *A Guide for First Time Researchers in Education, Health and Social Science*. 5th ed. Maidenhead: Open University Press/McGraw Hill Education, 2010. ISBN 978 0 335 23582 7.

National Center for the Dissemination of Disability Research (NCDDR). *What Are the Standards for Quality Research?* FOCUS Technical Brief No. 9. Austin, TX: Southwest Educational Development Laboratory, June 2005. PDF, 4 pages. Accessed June 01, 2025. https://ktdrr.org/ktlibrary/articles_pubs/ncddrwork/focus/focus9/Focus9.pdf.

Tegan George, “Types of Interviews in Research | Guide & Examples,” *Scribbr,* June 22, 2023, https://www.scribbr.com/methodology/interviews-research/.

University of Melbourne. “Research Reports.” *Academic Skills*. Accessed June 02, 2025. https://students.unimelb.edu.au/academic-skills/resources/reading,-writing-and-referencing/reports/research-reports#:~:text=It%20should%20be%20brief%2C%20written,the%20findings%3B%20and%20recommendations%20made.

University of Southern California Libraries. “Social Science Research Guide: Purpose.” Accessed June 05, 2025. https://libguides.usc.edu/writingguide/purpose.



CDPO

CDRI
Cambodia Development Resource Institute

CAMBODIAN INSTITUTE FOR COOPERATION AND PEACE

CPS
for Cambodia development

មជ្ឈមណ្ឌលខេមរសិក្សា
CENTER FOR KHMER STUDIES
CENTRE D'ÉTUDES KHMÈRES

FUTURE FORUM

GADC

WOMEN PEACE MAKERS